ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



លេខ៩០ ខែមិថុនា ឆ្នាំ២០០៧

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៤២ ខែមិថុនា ឆ្នាំ២០០៣


## មាតិកា


- សំបុត្រ៖ ទិដ្ឋភាពទូទៅនៃឯកសារភ័ស្តុតាង ..........១

**ផ្នែកឯកសារ**

- ឡេង ស៊ីមហាក់ ..........២
- មិនអាចបំភ្លេចបានសោះឡើយពេញមួយជីវិតរបស់ខ្ញុំ ..........៦
- សហករណ៍នៅសម័យបដិវត្តន៍ ..........៩
- ទូរលេខសុំជម្រាបគណៈ៨៧០ ..........១០
- បញ្ជីឈ្មោះជនរងគ្រោះបរទេស ..........១១
- ប្រព័ន្ធសន្តិសុខភូមិភាគពិសេស ម-១៣ ..........១៣
- បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ ..........២៤

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

- អហោសិកម្មនឹងគ្នាទៅចុះ ..........២៥
- សុខចិត្តធ្វើការលំបាកគ្រប់យ៉ាង ..........២៨
- ជម្លោះវវាងចិននិងកម្ពុជា ..........៣០

**ផ្នែកច្បាប់**

- ពិចារណាឡើងវិញនូវអនុសញ្ញាក្រុងហ្សឺណែវ ..........៣៦

**វេទិកាពិភាក្សាសាធារណៈ**

- ខ្ញុំសូមសន្យានៅចំពោះមុខព្រលឹងរបស់អ្នក ..........៣៩
- តើយើងបានធ្វើអ្វីខ្លះហើយដើម្បីបញ្ឈប់អំពើយង់ឃ្នង ..........៤១
- ផលប្រយោជន៍ត្រីកោណ ..........៤៤
- បញ្ហាលំបាកដែលគណៈកម្មការស្វែងរកការពិត ..........៤៩
- មនុស្សកាឡៃសត្វ ..........៥២

**ទំព័រស្រាវជ្រាវរកក្រួសារ**

- រស់ទាំងអស់សង្ឃឹម ..........៥៤
- រងាទាំងកាយ រងាទាំងចិត្ត ..........៥៦
- ដើម្បីផ្សះផ្សាជាតិឈានទៅរកភាពរីកចម្រើន ..........៥៩
- ខ្ញុំដឹងអំពីអ្វីៗដែលកើតមានឡើងក្នុងសម័យនោះ ..........៦១

**សិល្បៈខ្មែរក្រហម**

- រូបថតខ្មែរក្រហម ..........ក្របក្រោយ





រូបថតដោយៈ ហេង ស៊ីនិត


**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩


រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


**ស្នាលេខនេះ៖** យិន នាន, ផេង ពង្សរ៉ាស៊ី, ជួង សុភារិទ្ធ, ឈាំង ចៃ, លី សុខឃាង, ព្រុំ ផល្លា, លឹម ស្រីផល្លា, ទុម ទិវា, យិន ណូត, អាជូនី វីកឃីន **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, សើ សាយព្រណា **ជំនួយការនិពន្ធនាយកៈ** សាន់ កល្យាណ **និពន្ធនាយករងៈ** សួ ប៊ុនស៊ូ **អ្នកបកប្រែៈ** អេង កុកថាយ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្រ្ត **គ្រប់គ្រងការចែកផ្សាយៈ** មាស ប៊ុនថាន

*សំបុត្រៈ*

# និរន្តរភាពទូទៅនៃឯកសារភ័ស្តុតាងតម្កល់ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា

ចាប់តាំងពីការចាប់បដិសន្ធិនៅឆ្នាំ១៩៩៥មក មជ្ឈមណ្ឌលឯកសារកម្ពុជាបានខិតខំប្រមែប្រមូលយ៉ាងសកម្មនូវឯកសារនានាពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រសម័យកម្ពុជាប្រជាធិបតេយ្យ ។ មកដល់សព្វថ្ងៃនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាប្រមូលបានឯកសារប្រមាណ៦សែនទំព័រដែលបន្សល់ទុកពីរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងញត្តិនិងឯកសារកិច្ចសម្ភាសន៍ជាមួយជនរងគ្រោះដែលរួចចាកផុតរបបខ្មែរក្រហមនិងភ័ស្តុតាងឯកសារជាច្រើនប្រភេទទៀត ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមិនមានសិទ្ធិផ្តាច់មុខចំពោះឯកសារដែលទាក់ទងនឹងឧក្រិដ្ឋកម្មរបស់មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាទេ ប៉ុន្តែមជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងតម្កល់ឯកសារមានលក្ខណៈបែបនេះច្រើនជាងគេបង្អស់ ។ បណ្ណសារទួលស្លែងជាកន្លែងតម្កល់ឯកសារភ័ស្តុតាងសំខាន់ទីពីរ ។ ឯកសារទាំងនេះធ្លាប់តម្កល់ទុកនៅមន្ទីរឧក្រិដ្ឋកម្មទួលស្លែងស្ថិតនៅទីក្រុងភ្នំពេញ ហៅម្យ៉ាងទៀតថា “មន្ទីរស-២១” ដែលជាមន្ទីរសន្តិសុខមជ្ឈិមរបស់បក្សកុម្មុនិស្តកម្ពុជា(សន្តិបាល) ។ បណ្ណសារមានលក្ខណៈបុគ្គលរបស់អ្នកកាសែតល្បីៗ និងឯកសារកិច្ចសម្ភាសន៍របស់អ្នកស្រាវជ្រាវជាន់ខ្ពស់ជាមួយមន្ត្រីបក្សកុម្មុយនិស្តកម្ពុជា ជនរងគ្រោះនិងជាមួយជនដែលរួចចាកផុតពីសម័យខ្មែរក្រហម ពិតជាប្រភពព័ត៌មានភ័ស្តុតាងឯកសារដ៏មានសារសំខាន់ ។

ឯកសារមានស្រាប់ដែលអាចប្រើប្រាស់ប្រឆាំងនឹងមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាអាចចែកជាពីរប្រភេទសំខាន់ៗ ។ ប្រភេទទីមួយរួមមានឯកសារផលិតនៅក្នុងសម័យប៉ុលពត ។ កម្មាភិបាលនិងថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យជាអ្នករៀបចំឯកសារស្ទើរតែទាំងអស់ចាប់ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ប៉ុន្តែក៏មានចម្លើយសារភាពរបស់អ្នកទោសបក្សកុម្មុយនិស្តកម្ពុជានិងឯកសារមកពីបរទេសផងដែរ ។ ប្រភេទឯកសារសំខាន់ទីពីររួមមានឯកសារផលិតឡើងក្រោយរបបកម្ពុជាប្រជាធិបតេយ្យដួលរលំនៅឆ្នាំ១៩៧៩ ។ ឯកសារទាំងនេះភាគច្រើនគឺជាញត្តិនិងបទសម្ភាសន៍ជាមួយអ្នករស់រានមានជីវិតចាកផុតពីរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែក៏មានរបាយការណ៍ផែនទីផងដែរដែលរៀបរាប់អំពីភ័ស្តុតាងរូបវ័ន្ត ។ ជាការពិតណាស់មានឯកសារផ្សេងៗទៀត ក្រៅពីប្រភេទឯកសារដែលរៀបរាប់ខាងលើ ។ ប្រការនេះតម្រូវឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជានិងអ្នកអង្កេតជាលក្ខណៈប្រវត្តិសាស្ត្រនិងជាលក្ខណៈច្បាប់ខិតខំរុករក និងប្រមែប្រមូលទុកបន្តទៀត ។

ឯកសារទាំងនេះរួមមានឯកសារទាក់ទងគ្នារបស់បក្សកុម្មុយនិស្តកម្ពុជា ឯកសារចម្លើយសារភាព កំណត់ហេតុ និងរបាយការណ៍របស់គណៈកម្មាធិការបក្ស ប្រវត្តិរូបរបស់មេដឹកនាំបក្សកុម្មុនិស្តកម្ពុជា ឯកសារបរទេស ឯកសារឃោសនាការ កំណត់ហេតុនិងសៀវភៅសរសេរដៃ ញត្តិរបស់អ្នករស់រានមានជីវិត ឯកសារតុលាការឆ្នាំ១៩៧៩ ឯកសារបទសម្ភាសន៍និងរបាយការណ៍ផែនទី ។

របាយការណ៍ផែនទីដែលរៀបចំឡើងដោយនាយកនិងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាឯកសារភ័ស្តុតាងសំខាន់ទីពីរដែលផលិតឡើងនៅក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ ។ របាយការណ៍ផែនទីរៀបចំឡើងដោយមានការផ្តល់យោបល់ពីសំណាក់អ្នកជំនាញការបច្ចេកទេសនិងប្រើប្រាស់បច្ចេកវិទ្យាកំណត់កូអរដោណេភូមិសាស្ត្រ ។ ឯកសារទាំងនេះប្រមូលបានតាមរយៈការចុះទៅសិក្សាស្រាវជ្រាវតាមមូលដ្ឋានភូមិឃុំដោយស្វែងរកអដ្ឋិធាតុនិងធ្វើកិច្ចសម្ភាសន៍ ។ របាយការណ៍ផែនទីនិយាយលម្អិតអំពីទីតាំងនិងសណ្ឋានរណ្តៅសាកសពរួមចំនួន១៩៤៤០ នៅទូទាំងប្រទេសកម្ពុជា ។ ឯកសារផែនទីក៏ប្រាប់ពត៌មានអំពីគ្រោងអដ្ឋិធាតុរាប់មិនអស់ និងទីតាំងគុកចំនួន១៦៧កន្លែង និងមន្ទីរឃុំឃាំងកាលពីរបបកម្ពុជាប្រជាធិបតេយ្យដែលមួយចំនួនធំបន្សល់ទុកនូវឧបករណ៍សួរចម្លើយនៅឡើយ ។ **(តទៅទំព័រ២២)**

(អត្ថបទសង្ខេបចេញពីឯកសារចម្លើយសារភាព)

# ឡេង ស៊ឹមហាក់

ក្នុងរយៈកាលនៃការកាន់អំណាចរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) មានសាស្ត្រាចារ្យជាច្រើនរូបត្រូវបានចាប់ខ្លួននិងសម្លាប់ចោល ។

ឡេង ស៊ឹមហាក់ ដែលជាអតីតសាស្ត្រាចារ្យម្នាក់នៅក្នុងរបបសង្គមរាស្ត្រនិយម ក៏មានវាសនាមិនខុសពីសាស្ត្រាចារ្យមួយចំនួនទៀតដែរ ។ ស៊ឹមហាក់ បានចូលរួមបម្រើបដិវត្តន៍នៅក្នុងរបបខ្មែរក្រហម មានមុខងារជាប្រធានពេទ្យនារីព-១៧ (ពេទ្យ១៧ មេសា) ។ ស៊ឹមហាក់ ត្រូវអង្គការផ្អាកការងារមួយរយៈពីបទថាប្តីរបស់គាត់បានចូលប្រជាចលនា និងបម្រើសេ.អ៊ី.អា ។ បន្ទាប់ពីឃុំឃាំងខ្លួនអស់រយៈពេលជាច្រើនខែមក ស៊ឹមហាក់ ក៏ត្រូវអង្គការយកទៅសម្លាប់ចោល ។

ឡេង ស៊ឹមហាក់ ហៅ សី គឺជាភរិយារបស់ ទីវ អុល ។ ទីវ អុល មានតួនាទីជាគណៈក្រសួងឃោសនាការនៃរបបកម្ពុជាប្រជាធិបយ្យេ ។ ក្រោយមក ទីវអុល ត្រូវបានចាប់ខ្លួន ហើយយកទៅសម្លាប់ចោល ។

### ១) របបសង្គមរាស្ត្រនិយម

នៅឆ្នាំ១៩៥៨-៥៩ ស៊ឹមហាក់ និងមិត្តភក្តិម្នាក់ឈ្មោះ សាន់ សំអាត (ឈ្មោះបដិវត្តន៍ វ៉ែន) បានចូលរៀននៅសាលាគរុកោសល្យភ្នំពេញរយៈពេលមួយឆ្នាំ ។ តាមរយៈការអានកាសែតមួយចំនួនដូចជាកាសែតឯកភាព កាសែតចំរើន កាសែតមិត្តភាពនិងកាសែតប្រជាជន ស៊ឹមហាក់ បានយល់អំពីបដិវត្តន៍ខ្លះៗរួចមកហើយ ។ ស៊ឹមហាក់ និង សំអាត ក៏មានទំនាក់ទំនងជាមួយ ទីវ អុល ដែរ ប៉ុន្តែ ស៊ឹមហាក់ ពុំទាន់មានទំនាក់ទំនងស្នេហានៅឡើយទេ ។

បន្ទាប់ពីបានបញ្ចប់វគ្គបណ្តុះបណ្តាល ស៊ឹមហាក់ និង សំអាត បានទៅបង្រៀននៅអនុវិទ្យាល័យស្ទួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ ដែលនៅទីនោះ កុយ ធួន (រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ) ជាអ្នកដឹកនាំអ្នកទាំងពីរ ។ ស៊ឹមហាក់ និង សំអាត បានដើរប្រមូលកម្លាំងបដិវត្តតាមរូបភាពនានាដូចជានាំសិស្សជប់លៀងនិងដើរកម្សាន្តតាមកន្លែងផ្សេងៗ ។ ក្នុងចំណោមសិស្សទាំងនោះ ស៊ឹមហាក់ អប់រំសិស្សបានពីរនាក់ឈ្មោះ តាំង ហ្គេកការ(ស្រី) និង អេង ម៉េងហ៊ាង(ប្រុស) ។ ឆ្នាំ១៩៦០ ស៊ឹមហាក់ បានសម្រេចចូលក្នុងប្រជាចលនាក្រោមការបញ្ចុះបញ្ចូលរបស់ កុយ ធួន អំពីប្រជាចលនាដែលមានអត្ថន័យថា ប្រជាចលនាគឺជាក្រុមរបស់អ្នកស្នេហាជាតិដែលមានគោលការណ៍ប្រឆាំងនឹងពួកចក្រពត្តិដូចអង្គការបដិវត្តដែរ ។ ប៉ុន្តែក្រុមនេះមិនបានចូលរួមជាមួយអង្គការបដិវត្តទេ ព្រោះថាបើដើរតាមអង្គការបដិវត្ត ថ្ងៃក្រោយច្បាស់ជាកសាងប្រទេសទៅជារបបសង្គមនិយមនិងកុម្មុយនិស្តនិយម ។ ហើយក្រុមនេះនឹងយកលំនាំតាមសហរដ្ឋអាមេរិក ព្រោះជាអ្នកមានជាងគេក្នុងសកលលោក តាំងរបៀបរបបរស់នៅមានភាពហ៊ឺហាសប្បាយជាងគេ ។ ឯវិទ្យាសាស្ត្របច្ចេកទេសនៅក្នុងប្រទេសអាមេរិកក៏ជឿនលឿនជាងប្រទេសនានាលើសកលលោកដែរ... ។

នៅឆ្នាំ១៩៦១ ស៊ឹមហាក់ បានរៀបការជាមួយ ទីវ អុល រស់នៅភ្នំពេញ ។ មុនរៀបការបន្តិច ស៊ឹមហាក់ បានចូលសមាជិកបក្ស ដែលមាន អៀង សារី, កុយ ធួន លេខាភូមិភាគឧត្តរ និង ស៊ាន អតីតគ្រូបង្រៀននៅព្រៃទទឹង ជាអ្នកទទួលស្គាល់ ។ កាលណោះបក្សមានឈ្មោះជាបក្សពលករនៅឡើយ ក្រោយមកបានប្តូរមកជាបក្សកុម្មុយនិស្តកម្ពុជា ។ បន្ទាប់ពីកសាងគ្រួសាររួចមក ទីវ អុល បាននាំប្រពន្ធរបស់គាត់(ស៊ឹមហាក់) ចូលជាសមាជិកសេ.អ៊ី.អា ។ ស៊ឹមហាក់ បានទទួលប្រាក់ខែចំនួន៥០០០រៀល ចំណែក ទីវ អុល ទទួលបាន៧០០០រៀលក្នុងមួយខែពីឈ្មោះ ហង់ ធុនហាក់ ។ ស៊ឹមហាក់ ស្គាល់ខ្សែខាងសាស្ត្រាចារ្យមួយចំនួនតាមការណែនាំរបស់ ទីវ អុល ប៉ុណ្ណោះដែលមានៈ ១) ខេក ប៉ែន ២) កែ គឹមហួត ៣) សាំង រិន ៤) គង់ សុគុន ៥) ពីង សយ ៦) ស៊ីង ភាត់ ៧) លន់ ៨) សេង ប៊ុនថន ៩) ម៉ៃ លន់ ១០) រៀម

យស់សា និង ១១) តាន់ អ៊ីម ។

ឆ្នាំ១៩៦២-៦៣ ស៊ឹមហាក់ បង្រៀននៅវិទ្យាល័យ ខ្មែរ-អង់គ្លេស ភ្នំពេញ ។ ឆ្នាំ១៩៦៣-១៩៦៧ ស៊ឹមហាក់ បានចាប់ផ្តើមសង្កេតពិនិត្យនិងឃោសនាអប់រំកម្លាំងមួយចំនួន ដូចជា ១) ព្រំ សំអារ ជាសាស្ត្រាចារ្យនៅសាលាខ្មែរ-អង់គ្លេស ២) ហុង ៣) ប្រពន្ធ ម៉ៅជឿន (ម៉ៅ ជឿន ធ្វើពេទ្យនៅសង្កម ចាស់) និង ៤) ហាក់ ចាន់ដារា ជាយុវជននៅសាលានេះដែរ ។

ដើមឆ្នាំ១៩៦៧ ស៊ឹមហាក់ បានមកបំប៉នវិជ្ជានៅសាលាគរុ-កោសល្យមួយឆ្នាំទៀត ។ ចំណែក ទីវ អុល ចេញទៅចលនានៅព្រៃដឹកនាំដោយ ជា ហួន គណៈភូមិភាគពាយ័ព្យ ។ ឆ្នាំ១៩៦៨ ស៊ឹមហាក់ បានទៅបង្រៀននៅខេត្តកំពង់ចាមអស់រយៈពេល៤ខែ បន្ទាប់មកបានចេញទៅព្រៃ ប៉ុន្តែមិនបានសម្រេចជាលទ្ធផលក៏ត្រឡប់មកវិញ ។

ដើមឆ្នាំ១៩៦៩ ស៊ឹមហាក់ បានទៅរស់នៅជាសម្ងាត់ នៅខេត្តក្រចេះអស់រយៈពេលមួយខែ រួចធ្វើដំណើរបន្តទៅភាគឦសានក្នុងខេត្តរតនគិរី ហើយបានជួបប្តីរបស់គាត់(ទីវអុល) នៅទីនោះ ។ ២ខែក្រោយ ស៊ឹមហាក់ បានមកនៅមន្ទីរបង្កបង្កើនផលក-១៧ ក្នុងនាមជាសមាជិកធម្មតា ប៉ុន្តែមិនមានសកម្មភាពអ្វីទេ ព្រោះថាបងប្អូនជនជាតិភាគតិចនៅមានជំហររឹងមាំស្មោះត្រង់ដាច់ខាតចំពោះបក្សកុម្មុយនិស្តកម្ពុជានៅឡើយ ។ នៅចុងឆ្នាំនេះ អង្គការបានចាត់តាំង ស៊ឹមហាក់ ឲ្យធ្វើជាប្រធានមន្ទីរសេដ្ឋកិច្ចមួយដែលមានឈ្មោះ ឆាំ ជាលេខាសាខាមន្ទីរនិងជនជាតិខ្មែរម្នាក់ឈ្មោះ ចិត្ត ធ្វើការនៅទីនោះដែរ ។

## ២) របបសាធារណរដ្ឋខ្មែរ

នៅក្នុងរបបសាធារណរដ្ឋខ្មែរ ខេត្តរតនគិរីបានទទួលរងនូវការទម្លាក់គ្រាប់បែកប៥២យ៉ាងដំណំ ។ អង្គការបានជម្លៀសប្រជាជនឲ្យទៅរស់នៅស្រុក វ៉ឹនសៃ ដើម្បីបង្កបង្កើនផល ។ ស៊ឹមហាក់ និងឈ្មោះ ចិត្ត ក៏ត្រូវជម្លៀសខ្លួនទៅជាមួយដែរ ។

ខែសីហា ឆ្នាំ១៩៧០ អៀង ធីរិទ្ធ (ប្រពន្ធ អៀង សារី) បានហៅ ស៊ឹមហាក់ ឲ្យមកនៅមន្ទីរអង្គការវិញ ហើយម្យ៉ាងទៀតដោយសារកម្មាភិបាលនៅក្នុងអង្គការត្រូវទៅបំពេញបេសកកម្មនៅតាមតំបន់នានា ស៊ឹមហាក់ ក៏ត្រូវ សុន សេន ដែលនៅពេលនោះគឺជាលេខាភូមិភាគឦសាន ចាត់តាំងឲ្យធ្វើជាប្រធានមន្ទីរភូមិភាគ ។ ស៊ឹមហាក់ បានធ្វើការនៅមន្ទីរភូមិភាគអស់រយៈពេលមួយឆ្នាំក្រោមការគ្រប់គ្រងរបស់ ឆាំ (ជំនួស តំណែង ទីវ អុល) ។

ចុងឆ្នាំ១៩៧១ ស៊ឹមហាក់ បានចុះធ្វើការតាមមូលដ្ឋានជាមួយ នារីយឹម ហៅ ខៀវ ប៉ុណ្ណារី(ប្រពន្ធរបស់ ប៉ុល ពត) អស់រយៈពេលមួយខែនៅភូមិភាគឧត្តរ ។ ដើមឆ្នាំ១៩៧២ ទើបអង្គការចាត់តាំង ស៊ឹមហាក់ ទៅគ្រប់គ្រងនៅមន្ទីរកុមាររយៈពេល៦ខែ ដែលមាននារី យាត (ប្រពន្ធរបស់ ហ៊ូ យន់) ជាអនុប្រធាន ប៉ុន្តែស្ថិតនៅក្រោមការដឹកនាំរបស់ ខៀវ ប៉ុណ្ណារី ។ នៅមន្ទីរនេះមានទាំងកុមារនិងនារី ។ ស៊ឹមហាក់ មានតួនាទីគ្រប់គ្រងនារី៤នាក់ ១) នារីយាត កូនដង្ហោយឈើខេត្តកំពង់ចាម ២) នារីគី កូនអ្នកលក់ថ្នាំពេទ្យ ៣) នារី ទូច ប្រពន្ធរបស់ តូច ភឿន (ក្រសួងសាធារណការនៅក្នុងរបបខ្មែរក្រហម) និង ៤) នារី ថា ជាប្រពន្ធរបស់មិត្ត ថុន ធ្វើការនៅរោងពុម្ពរដ្ឋរបស់អង្គការ ។

នៅចុងឆ្នាំ១៩៧២ អង្គការបានចាត់តាំង ស៊ឹមហាក់ ឲ្យធ្វើការនៅមូលដ្ឋានភូមិ-ឃុំ ។ ស៊ឹមហាក់ បានក្តាប់នារីឃុំស-៤៥ ក្នុងស្រុកស៊ឹងត្រង់ ដោយមាន តាន់ ទ្រី ហៅ ឈឿន ជាអ្នកក្តាប់ពីលើ និងឈ្មោះ ហង់ ប្រធានឃុំនៅក្នុងភូមិភាគឧត្តរនេះ ។ ភារកិច្ចចម្បងនៅពេលនោះគឺ ស៊ឹមហាក់ ត្រូវកសាងកម្លាំងមូលដ្ឋាន និងអនុវត្តតាមការណែនាំចំហរបស់ភូមិភាគឧត្តរ ដោយណែនាំប្រជាជនឲ្យដាំស្រូវ ដំឡូងឈើ ចេក ធ្វើផ្លូវ របងជាដើម ។ ជាមួយនឹងការងារនេះ ស៊ឹមហាក់ កសាងបាននារីពីរនាក់ឈ្មោះ យ៉ិន ប្រធាននារីភូមិគីឡូ១០ និងនារីស៊ាន ប្រធានភូមិហុងត្បែង ។

ឆ្នាំ១៩៧៣ ស៊ឹមហាក់ បានទៅបំពេញភារកិច្ចនៅភូមិព្រះអណ្តូង ឃុំព្រះអណ្តូងស្រុក៦៥ តំបន់៣៣ ដែលឈ្មោះ ឈឿន ជាលេខាតំបន់ ។ ចំណែក ទីវ អុល អង្គការចាត់តាំងឲ្យទៅជួយបើកវគ្គអប់រំនៅភូមិភាគបូព៌ា ។ នៅពេលដែលមានការជម្លៀសប្រជាជនចេញពីទីក្រុងកំពង់ចាម កុយ ធួន បានដាក់ភារកិច្ចឲ្យ ឈឿន កសាងកម្លាំងក្បត់ដោយប្រមូលបញ្ញាជនទាំងអស់ដែលភាគច្រើនជាគ្រូបង្រៀនមកអប់រំជាវគ្គដោយឡែកពីគ្នា ។ ដើមឆ្នាំ១៩៧៤ ស៊ឹមហាក់ បានចូលរួមសន្និបាតនារី

នៅភូមិភាគឧត្តរ រួចបន្តមកស្នាក់នៅមន្ទីរកុមារវិញ ប៉ុន្តែមិនបានធ្វើសកម្មភាពអ្វីឡើយ ។ ខែមីនា ឆ្នាំ១៩៧៤ អង្គការបានបង្កើតមន្ទីរមួយទៀតសម្រាប់ដាក់បញ្ញាជនដែលមកពីបរទេសដើម្បីលត់ដំខ្លួន (រួមមានដូចជា សៀង ប៉ោសែ ហៅនាគ និង សេរីវុធ ជាដើម) ។ ពេលនោះ ស៊ឹមហាក់ ត្រូវបានចាត់តាំងឲ្យធ្វើជាអនុប្រធានមន្ទីរសមមិត្ត វ៉ាន់ ជាលេខា ។ សេរីវុធ ហៅវុន ក៏ធ្លាប់ធ្វើការនៅក្នុងព្រៃជាមួយ ទីវ អុល ដែរ ។ នៅចុងខែសីហា ស៊ឹមហាក់ បានផ្លាស់ចេញពីមន្ទីរមកនៅតំបន់១៥ភូមិភាគពិសេសខាងជើង។ ចំណែកនៅមន្ទីរលត់ដំអង្គការចាត់តាំង ហ៊ូ នឹម ឲ្យគ្រប់គ្រងជំនួសវិញ ។ កុយ ធួន បានខទេ្វសនាមឲ្យ ស៊ឹមហាក់ ស្គាល់មនុស្សម្នាក់ទៀតឈ្មោះ កែវ លេខាស្រុក១៥១ ។ តាមរយៈ កែវ នេះដែរ ស៊ឹមហាក់ ក៏បានស្គាល់កម្មាំងក្បត់នៅតំបន់១៥មួយចំនួនដូចជាឈ្មោះ ហំ, នៅ លេខាស្រុក១៥២, ឆាន់ គណៈស្រុក១៥២, ផន កម្មាភិបាលនារីស្រុក១៥២ និង សឿន ប្រធានស្រែប្រាំងរបស់តំបន់១៥ ថែមទៀត ។

អង្គការបានចាប់ផ្តើមបំផុសផែនការជាយុទ្ធសាស្ត្រមួយចំនួនដោយឲ្យប្រជាជនដាំដំឡូងឈើនិងដំឡូងជ្វាបន្ថែមពីលើការដាំស្រូវទៀត។ ពេលនោះ កែវ បានឲ្យ ស៊ឹមហាក់ រារាំងប្រជាជនមិនឲ្យដាំដំណាំទាំងនោះសម្រេចបានតាមផែនការបានឡើយ ។ ស៊ឹមហាក់ មិនត្រឹមតែរារាំងការដាំដំណាំប៉ុណ្ណោះទេ ថែមទាំងបំផុសឲ្យនារីនិងកុមារជំទង់បម្រើក្នុងចលនាជួរតាមរយៈកម្មាភិបាលនារីភូមិ-ឃុំ បានចំនួនពីរនាក់ឈ្មោះ វ៉ាត់ ជាកម្មាភិបាលស្រុក១៥១ និងនារី ខុំ ជាប្រធាននារីឃុំត្រាចទង ក្នុងស្រុក១៥១តំបន់១៥ ទៀតផង ។

### ៣) សកម្មភាពនៅមន្ទីរពេទ្យខ្មែរក្រហម

បន្ទាប់ពីថ្ងៃជ័យជម្នះ១៧ មេសា ១៩៧៥ ស៊ឹមហាក់ បានក្លាយទៅជាកម្មាភិបាលពេទ្យមួយរូបនៅមន្ទីរពេទ្យព-១៧ ។ មន្ទីរព-១៧ ជាការបញ្ចូលគ្នារវាងមន្ទីរពេទ្យព-២៧និងព-២៨ ដែលមន្ទីរពេទ្យទាំងពីរនេះជាពេទ្យរបស់ភូមិភាគពិសេសខាងជើងក្នុងពេលមានសង្គ្រាម ។ (មន្ទីរពេទ្យព-១៧ បច្ចុប្បន្នគឺមន្ទីរពេទ្យរុស្ស៊ី ភ្នំពេញ) ។ គណៈកម្មាធិការនៃមន្ទីរពេទ្យនេះមាន ស៊ឹមហាក់, ហុង ជាអនុប្រធាន ឡា ជាបក្ខជន, ឈុនលី ជាយុវកក, សាន់ ជាអនុគណៈកម្មាធិការផ្នែកធ្មេញ, យន ជាប្រធាននារីក្នុងមន្ទីរពេទ្យព-១៧, ៦) វ៉ាន់, ៧) នារីសង្វាត ប្រធានផ្នែកវិទ្យាសាស្ត្រ និង នារី រឹម ប្រធានផ្នែកព្យាបាលភ្នែកនៅព-១៧ ។ ក្រៅអំពីការងាររបស់បក្ស ស៊ឹមហាក់ នារីហុង និង ឡា បានពិភាក្សាសម្រេចយកមន្ទីរធ្វើជាកន្លែងទាក់ទងគ្នា ។ ទីវ អុល ក៏យល់ស្របនឹងគំនិតនេះដែរ ។ មុនមកកាន់មន្ទីរពេទ្យព-១៧ ស៊ឹមហាក់ ធ្លាប់ធ្វើសកម្មភាពនៅមន្ទីរពេទ្យព-១,ព-២និងព-៣ កសាងកម្លាំងបាន១៨នាក់និងឈ្មោះមួយចំនួនទៀតដែលប្តីរបស់គាត់(ទីវអុល) បានខទេ្វសនាមប្រាប់ ។ ក្រោយពីនោះទៀត ស៊ឹមហាក់ បានធ្វើសកម្មភាពមួយចំនួនប៉ះពាល់ដល់បដិវត្តដូចជាមិនអនុវត្តតាមផែនការដែលអង្គការបដិវត្តន៍កំណត់ឲ្យធ្វើនិងបង្កបាតុភាពមួយចំនួនដូចជាបាតុភាពពុលអាហាររបស់សិក្ខាកាម ចាក់ថ្នាំខុសបណ្តាលឲ្យអ្នកជំងឺស្លាប់ ដាក់ខិត្តប័ណ្ណនៅបន្ទប់វះកាត់ដែលខ្លឹមសាររបស់ខិត្តប័ណ្ណនោះគឺ ឃោសនាមិនឲ្យជឿលើបក្សកុម្មុយនិស្តកម្ពុជា និងបាតុភាពសម្លាប់ខ្លួនរបស់សមមិត្ត ហួត (បន្ទាប់ពី ស៊ឹមហាក់, សាត, ពឿន និង ម៉ៅ ណែនាំឲ្យកែប្រែអំពីកំហុសរបស់ខ្លួនជាមួយ នារីភាព) ជាដើម ។

នៅឆ្នាំ១៩៧៦ ស៊ឹមហាក់ បានទទួលដំណឹងពី សល់ និង សាន ថា នឹងមានផែនការត្រៀមធ្វើរដ្ឋប្រហារនៅខែ៣ ឆ្នាំ១៩៧៧ តាមរយៈឈ្មោះ គាន់ទ្រី ហៅ ឈឿន, សល់ និង សាន កម្មាភិបាលក្នុងតំបន់៤១ (ភូមិភាគឧត្តរ) បានមកសម្រាកនៅមន្ទីរពេទ្យពី-១៧ ។ ជារូបភាព អ្នកទាំងនេះមកសម្រាកព្យាបាលជំងឺជាសម្ងាត់ដើម្បីទាក់ទងជាមួយខ្សែរបស់ខ្លួន និងក្តាប់សភាពការណ៍អំពីផែនការបំផ្លិចបំផ្លាញបក្សបដិវត្តន៍ ។

បន្ទាប់មក តូចភឿន បានមកទំនាក់ទំនងជាមួយ ទីវអុល និង ស៊ឹមហាក់ ដោយថែមទាំងអូសទាញ អ៊ិន សូកាន(ពេទ្យព-១៧) ដែលទើបមកពីបរទេសឲ្យចូលសេ.អ៊ី.អាដែរ ។ ប៉ុន្តែ អ៊ិន សូកាន មិនទាន់មានសកម្មភាពអ្វីឡើយ ពីព្រោះថា ខ្លួននៅតែជឿជាក់លើអង្គការបដិវត្ត ។ ចុងឆ្នាំ១៩៧៦ ទីវ អុល និង ហ៊ូ នឹម បានមកសម្រាកមន្ទីរពេទ្យនៅអគារជាមួយគ្នា ។ ស៊ឹមហាក់ ដឹងថា ហ៊ូ នឹម បានសរសេរអត្ថបទបំភ្លៃមាគ៌ាបក្សយ៉ាងច្រើនតាមរយៈសំបុត្រមួយច្បាប់ដែលផ្ញើមកឲ្យប្តីរបស់ខ្លួន ដូចជាផែនការដឹក

ទំនប់ប្រឡាយបានផលតិចថាច្រើននិងខ្លឹមសារចម្រៀងបដិវត្ត និយាយតែអំពីការតស៊ូឲ្យទៅជាលក្ខណៈទន់ជ្រាយទៅវិញ ។ ដើមឆ្នាំ១៩៧៧ តាមរយៈ ឡា, ស៊ឹមហាក់ បានឲ្យដឹងថា បុគ្គលិកពេទ្យម្នាក់នៅព-១៧ បានប្រាប់ថាឲ្យប្រុងប្រយ័ត្ន ព្រោះថាអ្នកដែលធ្លាប់ធ្វើការជាមួយគាត់ម្នាក់ឈ្មោះ សិទ្ធិ ត្រូវអង្គការចាប់បាត់ទៅហើយ ។

ទោះបីជាផែនការរដ្ឋប្រហារខែ៣ ឆ្នាំ១៩៧៧ ត្រូវបរាជ័យ ហើយមេដឹកនាំកម្លាំងក្បត់ត្រូវអង្គការចាប់ខ្លួនជាបន្តបន្ទាប់ក៏ដោយ ក៏ ស៊ឹមហាក់ និង ទីវ អុល និងកម្លាំងក្បត់ដែលនៅសេសសល់ នៅតែបន្តគ្រោងនឹងអនុវត្តតាមផែនការនេះដដែល ។ ស៊ឹមហាក់ បានសារភាពថា គាត់និងប្តីមានគម្រោងបំបែកបក្សពលករពីបក្សកុម្មុយនិស្តកម្ពុជា ដើម្បីដណ្តើមយកតួនាទីដឹកនាំពីបក្សកុម្មុយនិស្តកម្ពុជា បង្កើតមាគ៌ាជាយុទ្ធសាស្ត្រថ្មីរបស់បក្សពលករ កែទម្រង់សង្គមកម្ពុជាទៅជារបបឯកជនវិញ ហើយផ្សព្វផ្សាយមាគ៌ានេះឲ្យប្រជាជនជ្រួតជ្រាបដើម្បីឈានទៅរកការប្រមូលកម្លាំងឲ្យបានច្រើនទប់ទល់នឹងបក្ស ម៉ាក្ស ឡេនីន ក្នុងសកលលោក ដែលមាន កុយ ធួន ជាលេខា ដឿន អនុលេខា លីន និងស្រេង សមាជិក ។

ខែមេសា ឆ្នាំ១៩៧៧ ខ្សែកម្លាំងក្បត់ត្រូវអង្គការចាប់ស្ទើរតែអស់ ។ នៅមន្ទីរពេទ្យព-១៧ លែងមានសកម្មភាពអ្វីទៀតហើយ ។ ទីវ អុល ក៏ត្រូវចាប់ខ្លួននៅពេលនោះដែរ ។ ចុងខែមិថុនា សាយ ដែលជាកម្មាភិបាលខាងខស្បៀងហកម្មបានសុំ ស៊ឹមហាក់ ភ្ជាប់ខ្សែជាមួយ ពីព្រោះថាខ្សែរបស់គាត់ (សាយ ធ្វើការនៅមូលដ្ឋានតំបន់៣១ ជាខ្សែរបស់ កុយធួន) ត្រូវគាត់ផ្តាច់ការទាក់ទងអស់ទៅហើយ ។ ស៊ឹមហាក់ បានជួប សាយ តែពីរដងប៉ុណ្ណោះ ។ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ស៊ឹមហាក់ ត្រូវអង្គការដកឲ្យមកនៅផ្ទះសម្ងាត់មួយក្នុងមន្ទីររបស់ ឆាន ជាមួយកុមារបដិវត្តពីរនាក់ ។ ស៊ឹមហាក់ បានសរសេរថា "ខ្ញុំបានចូលបម្រើការជាប្រធានពេទ្យ១៧ មេសា គឺមានរយៈពេល២ឆ្នាំ ២ខែ ។ រហូតដល់ថ្ងៃទី៣០ ខែកក្កដា១៩៧៧ អឿង ធិរិទ្ធ បានប្រាប់គាត់ថា ប្តីរបស់គាត់បានចូលប្រជាចលនានៅឆ្នាំ១៩៥១ និងចូល សេ.អ៊ី.អា នៅឆ្នាំ១៩៥៦ អង្គការសម្រេចថាដកសមមិត្តមួយរយៈសិន ។ ស៊ឹមហាក់ ត្រូវបានឃុំខ្លួនឲ្យនៅផ្ទះមួយដែលមានកុមារបដិវត្តពីរនាក់ចាំឃ្លាំមើល និងពុំមានសិទ្ធិដើរទៅណាមកណាទេ រហូតដល់ថ្ងៃ១៧ មេសា ១៩៧៧ ទើបអង្គការចាប់ខ្លួននិងសម្លាប់នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៧៨ ។

**អំពីបងប្អូនៈ**

ឡេង ស៊ឹមហាក់ មានបងប្រុសម្នាក់និងប្អូនប្រុស៥នាក់ ។

◆បងប្រុសឈ្មោះ ឡេង ប៊ុនសា ឆ្នាំ១៩៦៨ ធ្វើការនៅតម្រួតនៅខេត្តកំពង់ចាម ។

◆ប្អូនទី១ ឈ្មោះ ឡេង ប៊ុនសុង ជាខ្សែរបស់ កុយ ធួន ហើយត្រូវវណ្ណៈកាន់អំណាចជិនាន់នោះ សម្លាប់នៅឆ្នាំ១៩៦៨ ។

◆ឡេង ប៊ុនស៊ាន អង្គការបានចាប់ខ្លួនមួយរយៈពេលខ្លី ។ ក្រោយមកអង្គការឲ្យមកធ្វើការនៅចម្ការកៅស៊ូវិញ ។ ភារកិច្ចជាគណនេយ្យករ ។

◆ឡេង យិនម៉ុង នៅជាមួយឈ្មោះ លាន លេខាតំបន់៣០ ភូមិភាគឧត្តរ ជាសេ.អ៊ី.អា ។ ក្រោយមក លាន បានស្លាប់ យិនម៉ុង បានមកនៅមន្ទីរជាមួយ ស្រេង លេខាតំបន់៤០ ភូមិភាគឧត្តរ ឋានៈជានីរសា ។ បច្ចុប្បន្នអង្គការចាប់ខ្លួន ។

◆ឡេង ប៊ុនសាត ជាសេ.អ៊ី.អា អង្គការចាប់ ។ ឡេង សុខុំ នៅមន្ទីរជាមួយ កុយ ធួន រហូត ។ ក្រោយពីអង្គការចាប់ខ្លួនមក កុយធួន សុខុំ ត្រូវអង្គការចាត់តាំងឲ្យទៅបង្កបង្កើនផលនៅតាឡី ។ បច្ចុប្បន្នមិនដឹង ។

◆ឡេង វ៉ាន់នី ចូលជួរបដិវត្តតាំងពីអាយុ១១ឆ្នាំ ដំបូងនៅមន្ទីរកុមារ ក្រោយមកនៅមន្ទីបង្កបង្កើនផល ចុងក្រោយមកនៅមន្ទីរអង្គការ ។ បច្ចុប្បន្នមិនដឹង ។ **លី សុផល**

## ពាក្យស្លោកខ្មែរក្រហម

◆ **ខ្លះខ្មែងកម្មេចកម្លាំងខ្មាំង ថែរក្សានិងបំប៉នកម្លាំងយើង កាន់តែខាយកាន់តែខ្លាំង កាន់តែខាយកាន់តែឈ្នះ។**

◆ **ប្រយុទ្ធនឹងចលនាធាហានខ្មាំង ហើយបំផុសមហាជន ឱ្យក្រោកឡើងខាយដណ្តើមសិទ្ធិអំណាច ធ្វើម្ចាស់ទឹកដី។**

***(ដកស្រង់ពីសៀវភៅកំណត់ហេតុលេខ២០០)***

# មិនអាចបំភ្លេចបានសោះឡើយពេញមួយជីវិតរបស់ខ្ញុំ
# BMD និងចម្លើយរបស់ព្រះករុណាសម្តេចព្រះនរោត្តមសីហនុ

*BMD គឺជាព្រឹត្តិប័ត្រឯកសារប្រចាំខែនៃព្រះរាជអគ្គលេខាធិការដ្ឋានឯកជនរបស់ព្រះករុណា ព្រះបាទ សម្តេច នរោត្តម សីហនុ ។*

**ទីក្រុងប៉េកាំង, ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៣**

**BMD:** “សម្តេចជាម្ចាស់! ជនជាតិខ្មែរមួយចំនួនបានចោទព្រះអង្គថា គ្មានជ្រើសអ្នកធ្វើការណាក្រៅពីពួកខ្មែរក្រហមឡើយ ដើម្បីដឹកនាំអគ្គលេខាធិការដ្ឋាននិងខុទ្ទកាល័យរបស់ព្រះអង្គចាប់តាំងពីសាធារណរដ្ឋប្រជាមានិតចិនបានរំដោះព្រះអង្គពីក្រញាំ ប៉ុល ពត នាខែមករា ឆ្នាំ១៩៧៩ មក ។ ចំណែកពួកមិនមែនខ្មែរក្រហមមិនភ្លេចនឹងកត់សម្គាល់ថា បន្ទាប់ពីការរំដោះព្រះអង្គនៅឆ្នាំ១៩៧៩ ព្រះអង្គបានបន្តរក្សាទំនាក់ទំនងដ៏ល្អប្រសើរជាមួយពួកបញ្ញវន្តខ្មែរក្រហមល្បីៗទៀត ដោយចាប់ផ្តើមពីសមាជិកប្រុសស្រីនៃគ្រួសារ ជួន ដែលនិរទេសខ្លួនដោយខ្លួនឯងនៅបរទេស” ។

សម្តេចព្រះនរោត្តម សីហនុ គ្រាន់តែនាងស្តាប់ឬការប្រកាសរបស់ខ្ញុំដើម្បីធ្វើការតស៊ូប្រឆាំងចក្រពត្តិនិយមអាមេរិក និងពួកបរិវាររបស់វាក្លាម លោកស្រី ខូ វ៉ានី (ភរិយារបស់លោក ឈន ហៃ) បានផ្ញើមកថ្វាយខ្ញុំនូវសាលិខិតមួយដោយអះអាងថា នាងនិងអ្នកស្នេហាជាតិមាតុភូមិមួយក្រុម(បញ្ញវន្តទាំងពីរភេទ ដែលនាងបានផ្តល់ឈ្មោះនិងវិជ្ជាជីវៈផ្ទាល់ខ្លួនម្នាក់ៗផង) ដែលមានស្មារតីភក្តីចំពោះប្រទេសកម្ពុជាឯករាជ្យ និងចំពោះព្រះប្រមុខរដ្ឋស្របច្បាប់និងជាទីស្រឡាញ់របស់ប្រជារាស្ត្របានសម្រេចចិត្តចូលព្រៃម៉ាគី ដោយគ្មានរួញរានិងគ្មានបង្អង់ ដើម្បីធ្វើការរំដោះជាតិក្នុងក្របខ័ណ្ឌនៃរណសិរ្សរួបរួមជាតិកម្ពុជានិងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។ របៀបសរសេរនៃសាលិខិតរបស់លោកស្រី ខូ វ៉ានី និងភាសារបស់នាងពុំមែនជាភាសានៃ“ពួកកុម្មុយនិស្ត” ឬ“ពួកខ្មែរក្រហម”ទេ ប៉ុន្តែជាភាសានៃ “ពួកជាតិនិយម” ។

១៩៧៥ - ១៩៧៦: ជា“អន្តេវាសិក”នៃពួកខ្មែរក្រហមនៅប្រាសាទខេមរិន្ទនិងរហូតដល់ថ្ងៃមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ប្រកាសប្រាប់ប្រជាជាតិខ្មែរនិងពិភពលោកថា គេព្រមទទួលការសុំលាលែងដោយស្ម័គ្រព្រះទ័យពីមុខតំណែងប្រធានគឺប្រមុខរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ ខ្ញុំមានភ័ព្វសំណាង (ខ្ញុំមិនបំផ្លើសទេ) បានទទួលលោក ឈន ហៃ ដែលឋានៈគាត់ក្នុងកម្ពុជាប្រជាធិបតេយ្យគឺ “ស្នងការនយោបាយ”មកនៅធ្វើការជាមួយខ្ញុំព្រោះគាត់ជា“មនុស្សដែលចេះបំពេញកិច្ចការគ្រប់បែបយ៉ាង” ។

លោក ឈន ហៃ (ជាអ្នកមានសញ្ញាប័ត្រជាន់ខ្ពស់និងជាវិស្វករ) គឺជា(ហើយនៅតែជា)ស្វាមីរបស់លោកស្រី ខូ វ៉ានី ដដែល(ស្ត្រីអ្នកមានសញ្ញាប័ត្រជាន់ខ្ពស់និងជាឱសថការិនី) ។ ពេញរយៈពេលដែលគាត់មានករណីយកិច្ច “គិតគូរពីសុខុមាលភាពរបស់ខ្ញុំ” ជាមួយក្រុមស្ត្រីចុងភៅដ៏ឆ្នើមរបស់គាត់និងពួកខ្មែរក្រហមផ្សេងទៀតដែលកំពុង“បម្រើខ្ញុំ” លោក ឈន ហៃ មិនដែលសាកល្បងបញ្ចុះបញ្ចូលព្រះរាជវង្សានុវង្ស ឬអ្នកនៅជុំវិញខ្ញុំដែលជា “អ្នកសីហនុនិយម” នៅប្រាសាទខេមរិន្ទឲ្យមានជំនឿដូចគាត់ទាល់តែសោះ ។ ផ្ទុយទៅវិញ គាត់បានសម្រេចលាក់កំបាំងនឹងខ្មែរក្រហមដទៃទៀត ទាំងស៊ីវិល ទាំងកងទ័ព“ដែលធ្វើការនៅអតីតព្រះរាជវាំង” ហើយជាពិសេសលាក់នឹងអង្គការនូវពាក្យសម្តីទាំងឡាយរបស់ សីហនុ និងពួកមនុស្សរបស់គាត់ផ្ទាល់ ព្រោះសម្តីទាំងនោះមានលក្ខណៈមិនជាទីគាត់ចិត្តប៉ុន្មានទេសម្រាប់របបកម្ពុជាប្រជាធិបតេយ្យ ។ បើសិនជាលោក ឈន ហៃ បាននាំសម្តីប្រឆាំងខ្មែរក្រហមរបស់យើងទៅប្រាប់អង្គការនោះយើងច្បាស់ជាត្រូវស្លាប់យ៉ាងប្រាកដ បន្ទាប់ពីការធ្វើទារុណកម្មដ៏សាហាវបំផុត ។

លោក ឈន ហៃ បានយកសៀវភៅធម៌ជាច្រើនក្បាល កម្រងសៀវភៅ *Assimil* (ជាភាសាអង់គ្លេស អាល្លឺម៉ង់

អ៊ីតាលី អេស្ប៉ាញ និង រុស្ស៊ី) ម្ហូបកំប៉ុង និង«របស់មានប្រយោជន៍» ជាច្រើនទៀតមកឲ្យខ្ញុំនិងមហេសីខ្ញុំ ដែលរបស់ទាំងនោះបានមកពីការបន្សល់ទុកក្នុងបណ្ដាផ្ទះអ្នកមានៗ នៅទីក្រុងភ្នំពេញ ដែលអង្គការបានជម្លៀសឲ្យទៅនៅតាមជនបទ ។

នៅថ្ងៃដែលអង្គការយល់ព្រមទទួលការសុំលាលែងដោយស្ម័គ្រព្រះទ័យពីមុខតំណែងជាប្រមុខរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ អង្គការបានសម្រេចរបៀបជាកាយវិការនៃ«ការដាក់ទណ្ឌកម្មដំបូង» ប្រឆាំងនឹងខ្ញុំដោយ«បញ្ឈប់» គ្មានបន្ទន់នូវបេសកកម្មធ្វើការអមខ្ញុំរបស់លោក ឈន ហៃ និងក្រុមស្រ្តីចុងភៅឆ្នើមរបស់គាត់ ព្រមទាំងអ្នកបម្រើទាំងអស់ ។ល។ អ្នកបម្រើស្ទើរតែទាំងអស់បានចាកចេញពីអតីតព្រះរាជវាំង ដោយមិនឃើញត្រឡប់មកក្រាបថ្វាយបង្គំលាខ្ញុំឡើយ ។ ប៉ុន្តែអ្នកបម្រើម្នាក់ក្នុងចំណោមអ្នកទាំងនោះឈ្មោះ សេង មានសេចក្ដីក្លាហានត្រឡប់ចូលមកក្នុងបន្ទប់របស់ខ្ញុំដើម្បីក្រាបថ្វាយបង្គំខ្ញុំដោយទូលខ្ញុំថា «ខ្ញុំព្រះអង្គមានទុក្ខក្រៀមក្រំណាស់ដែលត្រូវចាកចេញពីព្រះករុណា ។ សម្ដេចជាម្ចាស់ ទូលបង្គំសូមថ្វាយព្រះពរឲ្យព្រះអង្គមានព្រះជន្មាយុយឺនយូរ» ។-sic- ។ នេះជាឱកាសមួយក្នុងចំណោមឱកាសជាច្រើនដែលធ្វើឲ្យខ្ញុំញាប់ញ័រក្នុងព្រះទ័យនិងដែលនាំឲ្យឈឺចាប់បំផុតនៃជីវិតរបស់ខ្ញុំ (សេង ជាទីស្រឡាញ់ និងជាយុវជនម្នាក់បានត្រូវ«កម្ទេច» ក្រោយនោះបន្តិចតាមបញ្ជារបស់អង្គការ) ។

ចំណែកលោក ឈន ហៃ ដែលមកមុន សេង បានមកគោរពសំពះខ្ញុំ «តាមរបៀបខ្មែរ មុនជ័យជម្នះរបស់ពួកខ្មែរក្រហម» ។ គាត់បានយកចិត្តទុកដាក់ផ្ដល់ដំបូន្មានដល់ខ្ញុំ ព្រមទាំងព្រះញាតិវង្សនិងអ្នកហែហមរបស់ខ្ញុំដែលជា«អ្នកសីហនុនិយម» ផងដែរថា ត្រូវចៀសវាងជាដាច់ខាតកុំនិយាយអាក្រក់ពីរបបនិងអង្គការ ព្រោះថាប្រការនេះនឹងធ្វើឲ្យយើងពើបប្រទះគ្រោះថ្នាក់មួយរហូតដល់ស្លាប់ ។

សេចក្ដីសន្និដ្ឋានរបស់ខ្ញុំៈ ខ្ញុំនឹងមិនអាចបំភ្លេចបានសោះឡើយពេញមួយជីវិតរបស់ខ្ញុំ នូវអ្វីដែលលោក ឈន ហៃ បានធ្វើដើម្បីជួយស្រោចស្រង់ខ្ញុំ ស្រោចស្រង់ព្រះញាតិវង្សនិងអ្នកហែហមខ្ញុំដែល«និយមសីហនុ» ហើយដែលកំពុងរស់នៅនៅអតីតព្រះបរមរាជវាំងក្រោមរបប ប៉ុល ពត ។

ការប្រៀបធៀបមួយៈ លន់ ណុល, សិរិមតៈ, ទ្រិញ វ៉ាញ និង«ឥស្សរជនធំៗ» ជាច្រើនទៀត«របស់របបសាធារណរដ្ឋខ្មែរ» សុទ្ធតែជំពាក់គុណខ្ញុំទាំងអស់ក្នុងបណ្ដាទសវត្សរ៍១៩៤០-១៩៥០និង១៩៦០ ។ តើអ្នកទាំងនោះបានធ្វើអ្វីខ្លះ«ចំពោះ» ខ្ញុំ ហើយតមកទៀត ចំពោះព្រះមាតាខ្ញុំ ដែលធ្លាប់ជួយជ្រោមជ្រែងពួកគេនិងរបបរាជាធិបតេយ្យខ្មែរ(១៩៧០-១៩៧៥) ។

**លោក កែ គឹមសែៈ** ក្នុងយុវវ័យរបស់គាត់ គាត់ជាអ្នកសីហនុនិយមនិងនៅតែជាអ្នកសីហនុនិយម ក្នុងចិត្តនិងឧត្ដមគតិជាតិនិយមដដែល ទោះជាគាត់ក្លាយជា«ខ្មែរក្រហម»ក៏ដោយ ។

**លោក ស្រីណូរីៈ** នៅទីក្រុងប៉េកាំង ស្ថានទូតកម្ពុជាប្រជាធិបតេយ្យបានប្រគល់គាត់ឲ្យខ្ញុំប្រើប្រាស់ដើម្បីជួយធ្វើកិច្ចការរបស់ខ្ញុំបម្រើប្រទេសកម្ពុជា ព្រោះថាខ្ញុំត្រូវការបញ្ញវន្តនិងអ្នកវាយអង្គុលីលេខដ៏ចំណាប់ម្នាក់ព្រមគ្នា ។ លោក ស្រីណូរី ចេះភាសាបារាំងច្រើន ហើយភាសាអង់គ្លេសក៏ពូកែឥតទាស់ ។ តាំងពីជំនាន់នោះ ដែលយើងមានក្រុមអ្នកតំណាងការទូតមួយនៃកម្ពុជាប្រជាធិបតេយ្យនៅទីក្រុងប៉េកាំង(សាធារណរដ្ឋប្រជាមានិតចិន) នៅឡើយរហូតមកដល់បច្ចុប្បន្ន (ខែឧសភា ឆ្នាំ២០០៣) លោក ណូរី នៅតែស៊ូព្យាយាមធ្វើការទាំងយប់ទាំងថ្ងៃដើម្បីខ្ញុំ ។

ខ្ញុំសូមជម្រាប«ក្រៅសាច់រឿង»ថា ភាគច្រើនលើសលប់នៃអ្នកទាំងឡាយ ទាំងប្រុសទាំងស្រី (ជនស៊ីវិល ទាហាន ឬប៉ូលិស ...។ល។) ដែលធ្វើការសម្រាប់ព្រះមហាក្សត្រនិងព្រះមហាក្សត្រិយានី (នៅព្រះបរមរាជវាំងនៃប្រទេសកម្ពុជា) ក្នុងសម័យព្រះរាជាណាចក្រទី២ គឺសុទ្ធតែជាអ្នកនិយមគណបក្សប្រជាជនកម្ពុជា ។

ក្រៅពី«ខ្មែរក្រហម»ទាំងបីដូចមានរៀបរាប់ខាងលើនិងភាគច្រើនលើសលប់នៃពួកអ្នកនិយមគណបក្សប្រជាជននេះក៏មានអ្នកនិយម សីហនុ «អព្យាក្រឹត្យ»មួយចំនួនតូចដែរ (គឺអ្នកពុំមែននិយមគណបក្សប្រជាជនកម្ពុជា ពុំមែនខ្មែរក្រហម ពុំមែនអ្នកនិយមគណបក្សហ្វ៊ុនស៊ិនប៉ិច ពុំមែនអ្នកនិយមគណបក្សសមរង្ស៊ី) ។

**គ្រួសារត្រកូល ជូន**

ឯកឧត្តមសម្តេចចៅហ្វ៊ាវាំង ជួន ក្នុងឋានៈគាត់ជានាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីព្រះបរមរាជវាំងនៃព្រះរាជាណាចក្រកម្ពុជាទីមួយធ្លាប់បានបម្រើការងារក្រោមរជ្ជកាលស្តេចបីព្រះអង្គ គឺព្រះបាទស៊ីសុវត្ថិ ព្រះបាទមុនីវង្សនិងព្រះបាទនរោត្តម សីហនុ ។

ចៅៗរបស់គាត់បានទទួលអាហារូបករណ៍សិក្សារបស់ព្រះបរមរាជវាំងកម្ពុជាសម្រាប់ការរៀនសូត្រផ្នែកមធ្យមសិក្សារបស់ពួកគេនៅទីក្រុងព្រៃនគរ នៅដាឡាត់...និងការសិក្សាថ្នាក់ឧត្តមរបស់ពួកគេ នៅប្រទេសបារាំងទៀត ។

“ចៅៗ” នៃគ្រួសារត្រកូល ជួន ដែលជាអភិជនដ៏ថ្លៃថ្នូរ ក្រោយមកបានសម្រេចចិត្តធ្វើខ្លួនជាខ្មែរក្រហមជាជាងធ្វើជាអ្នកនិយមគណបក្សសង្គម ។

ប៉ុន្តែទំនាក់ទំនងការងារដើម្បីជាតិមាតុភូមិរបស់ពួកគេជាមួយខ្ញុំក្នុងក្របខ័ណ្ឌនៃការតស៊ូទាំងពីរលើករបស់យើង (១៩៧០-១៩៧៥ បន្ទាប់មក១៩៨២-១៩៨៩) ហើយក្រោយមក(គឺថារហូតមកដល់ឥឡូវនេះ) មានលក្ខណៈល្អប្រសើរបំផុត ។

វេជ្ជបណ្ឌិត ជួន ជឿនៈ ជាគ្រូពេទ្យវះកាត់ខ្មែរម្នាក់ក្នុងចំណោមវេជ្ជបណ្ឌិតវះកាត់ឆ្នើមៗរបស់យើង (ពុំនោះទេ ជាគ្រូពេទ្យប្រសើរលើសគេ) ។

នៅវិទ្យាល័យ ស្វាស៊ីលូ-ឡូបាត់ គាត់រៀនពូកែណាស់ខាងមុខវិជ្ជាវិទ្យាសាស្ត្រនិងគណិតសាស្ត្រ ។ គាត់បានជួយខ្ញុំយ៉ាងសម្បើមដោយ“ធ្វើឲ្យកាន់តែប្រសើរជាងមុន”បន្តិចនូវចំនួនពិន្ទុរបស់ខ្ញុំខាងមុខវិជ្ជាដ៏គួរឲ្យខ្លាចនេះ ។

បន្ទាប់មក ក្រោមការគ្រប់គ្រងរបស់ ប៉ុល ពត នៅកម្ពុជា វេជ្ជបណ្ឌិត ជួន ជឿន ត្រូវបានចាត់តាំងដោយអង្គការដើម្បីថែទាំសុខភាពខ្ញុំ ។

**ឯកឧត្តម ជួន ប្រសិទ្ធៈ** គាត់បានជួយខ្ញុំយ៉ាងច្រើនប្រកបដោយប្រសិទ្ធភាពដ៏ធំមួយ និងទទួលបានលទ្ធផលយ៉ាងប្រសើរបំផុតនៅលើឆាកអន្តរជាតិសម្រាប់ការងាររបស់ខ្ញុំនៅអង្គការសហប្រជាជាតិក្នុងឋានៈខ្ញុំជាប្រមុខរដ្ឋប្រធានកម្ពុជាប្រជាធិបតេយ្យ ។

ឯកឧត្តម ជួន ជុំ និងភរិយារបស់គាត់បានសម្រេចចិត្តរស់នៅជាមួយខ្ញុំពេញរយៈពេលនៃការនិរទេសរបស់ខ្ញុំនៅទីក្រុងប៉េកាំង បន្ទាប់ពីសាធារណរដ្ឋប្រជាមានិតចិនរំដោះខ្ញុំពីឲ្យផុតពីក្រញាំ ប៉ុល ពត ។

លោកស្រី ឈាន វ៉ម (ហៅ ជួន ជឿម) ស្វាមីគាត់គឺឯកឧត្តម ឈាន វ៉ម (ជាប្រធានគណបក្សប្រជាធិបតេយ្យនិងជានាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាកាលពីអំឡុងឆ្នាំ១៩៤០) បានសហការពេញទំហឹងជាមួយព្រះមហាក្សត្ររបស់គាត់ (នរោត្តម សីហនុ) និងបានជួយខ្ញុំយ៉ាងច្រើនក្នុងការធ្វើឲ្យសម្រេចសមិទ្ធផលដ៏ធំគឺ “គេហដ្ឋានរបស់កម្ពុជា” (MAISON DU CAMBODGE) នៅក្នុងបុរីសកលវិទ្យាល័យក្រុងប៉ារីសសម្រាប់ពួកនិស្សិតខ្មែរយើងស្នាក់នៅ ។

អ្វីដែលទាក់ទងនឹងទំនាក់ទំនងផ្សេងៗរបស់ខ្ញុំជាមួយបងប្អូនត្រកូល ជួន ទាំងនេះ ដែលជាមនុស្សត្រឹមត្រូវស្នេហាជាតិមាតុភូមិមានចំណេះវិជ្ជាខ្ពង់ខ្ពស់និងមានសមត្ថភាពបំផុតក្នុងការងាររបស់គេ ដើម្បីប្រទេសកម្ពុជា ខ្ញុំតោងតែរៀបរាប់បញ្ចូល ជួន ម៉ុំ ផងដែរ ដែលជាខ្មែរដំបូងម្នាក់ទទួលបានជោគជ័យពេញលេញ នៅសាលាពហុបច្ចេកទេសប្រទេសបារាំង ហើយជាមនុស្សដំបូងគេម្នាក់ក្នុងចំណោមមនុស្សដំបូងៗ ដែលទៅរួបរួមនឹងខ្ញុំនៅទីក្រុងប៉េកាំងក្នុងឋានៈជាសមាជិករណសិរ្សរួបរួមជាតិកម្ពុជានិងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។ ទំនាក់ទំនងផ្សេងៗរបស់យើងអាចត្រឹមតែអនុញ្ញាតឲ្យយើងរស់នៅដោយសុខដុមរមនាប្រកបដោយមិត្តភាពដ៏ជ្រាលជ្រៅនៃជីវិតផ្ទាល់ខ្លួនម្នាក់ៗរបស់យើងដែលនៅសល់ប៉ុណ្ណោះ ។

បកប្រែក្រៅផ្លូវការ

**ឌេព ម៉េងឃាន**

# ពន្យល់ពាក្យខ្មែរក្រហម

◆ **ការបដិវត្តន៍:** ការបំបះបំបោរឡើងដើម្បីផ្លាស់របៀបចាស់ទៅជាថ្មី ។

◆ **សង្គមកិច្ចៈ** អំពើធ្វើឡើងជាប្រយោជន៍ដល់ជនរួមជាតិ ។

***(ដកស្រង់ពីសៀវភៅកំណត់ហេតុអ៊ីវ)***

# សហករណ៍នៅសម័យបដិវត្តប្រជាជាតិ-ប្រជាធិបតេយ្យ និងរយៈកាលបដិវត្តសង្គមនិយម

**សហករណ៍** *នៅក្នុងសៀវភៅវចនានុក្រមខ្មែរបោះពុម្ពផ្សាយដោយពុទ្ធសាសន៍បណ្ឌិតឆ្នាំ១៩៦៧ បានឲ្យនិយមន័យថា «ការងារដែលរួមគ្នាធ្វើដំណើររួមគំនិតគ្នាធ្វើការ» ។ ដោយយោងទៅតាមនិយមន័យនេះ ហើយយើងក្រឡេកមើលទៅអតីតកាលវិញឃើញថា ពាក្យសហករណ៍នេះត្រូវបានយកមកប្រើប្រាស់និងអនុវត្តនៅក្នុងដំណាក់មួយនៃការបដិវត្តប្រជាជាតិ-ប្រជាធិបតេយ្យ ពិសេសនៅក្នុងសង្គ្រាមរំដោះជាតិកម្ពុជា ។ សហករណ៍នេះបានដើរតួនាទីរបស់ខ្លួន រហូតដល់ដណ្តើមមហា-ជ័យជម្នះនាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។*

*របបសាធារណរដ្ឋខ្មែរបានផ្លាស់ប្តូរទៅជារបបកម្ពុជាប្រជាធិបតេយ្យវិញ ក្រោមការគ្រប់គ្រងរបស់ ប៉ុល ពត, អៀង សារី និងបណ្តាមេដឹកនាំធំៗមួយចំនួនទៀត ។ ជាគោលការណ៍ដើម្បីស្តាបនាប្រទេសឡើងវិញ និងដើម្បីឲ្យប្រជាជនទាំងអស់រស់នៅមានសិទ្ធិស្មើៗគ្នា គ្មានការបែងចែកវណ្ណៈ ពណ៌សម្បុរ គ្មានអ្នកមាន គ្មានអ្នកក្រ គ្មានការជិះជាន់ រំលោភបំពានដូចរបបមុនៗនោះ មេដឹកនាំខ្មែរក្រហមបានប្រើគោលនយោបាយមួយដោយច្របាច់បញ្ចូលគ្នារវាងអ្នកទីក្រុងនិងជនបទ អ្នកមាននិងអ្នកក្រ (ដែលអ្នកទីក្រុងត្រូវបានចាត់ទុកថា ជាប្រជាជនថ្មីឬពួក១៧មេសា ចំណែកអ្នកស្រុកភូមិ ជាប្រជាជនចាស់ឬអ្នកមូលដ្ឋាន) ដោយធ្វើការជម្លៀសប្រជាជនដែលរស់នៅទីក្រុងឲ្យទៅរស់នៅជាមួយប្រជាជននៅតាមជនបទ ។ បន្ទាប់ពីច្របល់គ្នារួច ខ្មែរក្រហមបានអនុវត្តជំហានមួយទៀត គឺបង្កើតជាសហករណ៍ ហើយចាប់ផ្តើមបំបែកប្រជាជនក្មេងចាស់ប្រុសស្រីចេញពីគ្រួសារឲ្យទៅនៅសហករណ៍ផ្សេងៗតាមការចាត់តាំងរបស់អង្គការ ចំណែកទ្រព្យសម្បត្តិដែលមានជារបស់ផ្ទាល់ខ្លួនត្រូវយកមកដាក់ក្នុងសហករណ៍ធ្វើជាកម្មសិទ្ធិរួម ។ នៅក្នុងសហករណ៍នីមួយៗគឺត្រូវតែមានប្រធានសម្រាប់ដឹកនាំសមាជិកឲ្យទៅធ្វើការរួមគ្នា ហូបរួម ដេករួម បង្កបង្កើនផលរួម ចំណែកឯផលិតផលដែលបានមកពីការធ្វើរួមគ្នានោះគឺត្រូវប្រមូលមកដាក់រួមគ្នាដែរ ។ នៅក្នុងសៀវភៅយុវជននិងយុវនារីបដិវត្តបានអះអាងថា «សហករណ៍នៅក្នុងសម័យកាលបដិវត្តន៍របស់ខ្លួនមានតួនាទីសំខាន់ក្នុងការនាំមុខគេ ក្នុងការពារនិងកសាងសង្គមនិយមនៅកម្ពុជារហូតបានទទួលជ័យជម្នះ១៧ មេសា ១៩៧៥ នេះ» ។*

*ដូចនេះ តើសហករណ៍បានដើរតួនាទីអ្វីខ្លះនៅសម័យបដិវត្ត ប្រជាជាតិប្រជាធិបតេយ្យនិងរយៈកាលបដិវត្តសង្គមកម្ពុជាប្រជាធិបតេយ្យ?*

*នៅក្នុងសៀវភៅយុវជនយុវនារីបដិវត្តលេខ៦ ខែមិថុនា ឆ្នាំ១៩៧៦ បានសរសេរថាសហករណ៍មានតួនាទីសំខាន់ៗបួនៈគឺ*

*ទី១ៈ សហករណ៍ គឺជាអ្នកកម្ចាត់របបទាក់ទងផលិតកម្មជិះជាន់របស់ពួកសក្តិភូមិម្ចាស់ដីនិងនាយទុន ព្រោះថាមុនពេលចាត់តាំងឲ្យមានសហករណ៍ សេដ្ឋកិច្ចស្ថិតនៅក្នុងកណ្តាប់ដៃពួកនាយទុននិងម្ចាស់ដី មធ្យោបាយផលិតកម្មរបស់ប្រជាជន ដូចជាដីធ្លី គោក្របី និងឧបករណ៍ផលិតកម្មផ្សេងៗគឺស្ថិតនៅក្នុងកណ្តាប់របស់អ្នកទាំងនោះ ។ ទី២ៈ សហករណ៍ បានជំរុញចលនាវាយសម្រុកខ្លាំងនៅសមរភូមិមុខយ៉ាងខ្លាំងក្លាបំផុត ទាំងនយោបាយ ទាំងយោធា និងសេដ្ឋកិច្ចធ្វើការឃោសនាបោកប្រាស់ខាងនយោបាយរបស់សត្រូវឲ្យបរាជ័យ ។ ចំពោះខាងនយោបាយៈ សហករណ៍បានលើកឥទ្ធិពលបដិវត្ត ដូចជាជួយដោះស្រាយជីវភាពប្រជាជនទូទៅ សហករណ៍បានធ្វើឲ្យប្រជាជនកម្ពុជានៅតាមជនបទស្រែចម្ការនិងនៅទីប្រជុំជនផ្សារ... មានជំនឿជឿជាក់លើការដឹកនាំរបស់បក្ស និងមានជំនឿជឿជាក់លើជ័យជម្នះរបស់ចលនាតស៊ូបដិវត្ត ។ ខាងយោធាៈ សហករណ៍គឺជាបង្អែកដ៏រឹងមាំ ទាំងខាងនយោបាយ ខាងកម្លាំងមនុស្ស ខាងស្បៀងអាហារ និងខាងមនោសញ្ចេតនាសម្រាប់បម្រើនៅគ្រប់សមរភូមិមុខទៀតផង ។ ខាងសេដ្ឋកិច្ចៈ សហករណ៍ គឺជាអ្នកបង្កបង្កើនផលជាម្ចាស់ភោគផលស្រូវអង្ករដែលខ្លួនផលិតបាន ពោលគឺជាម្ចាស់*

លើសេដ្ឋកិច្ច ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់បក្ស ។ សហករណ៍អាចគ្រប់គ្រង និងក្តាប់សេដ្ឋកិច្ចតំបន់រំដោះបានយ៉ាងគត់មត់មិនឲ្យស្រូវអង្ករហូរចូលទៅតំបន់ខ្មាំង ដូចពេលមុនចាត់តាំងសហករណ៍ទៀតឡើយ ។ ដូច្នេះសហករណ៍មានតួនាទីវាយខ្មាំងខាងសេដ្ឋកិច្ចបន្ទត់ស្បៀងខ្មាំង រហូតដល់បដិវត្តសម្រេចបានជ័យជម្នះទាំងស្រុង ។ ទី៣ៈ សហករណ៍ ជាកម្លាំងជំរុញចលនាបង្កបង្កើនផលនៅសមរភូមិក្រោយ ។ មុនពេលចាត់តាំងជាសហករណ៍ប្រជាជនយើងមានការលំបាកជាខ្លាំងក្នុងការឧបត្តម្ភខ្លួន ។ ប៉ុន្តែក្រោយពេលដែលចាត់តាំងសហករណ៍ហើយ ការលំបាកនិងការខ្វះខាតមធ្យោបាយផលិតកម្មនិងឧបករណ៍ផ្សេងៗទៀតត្រូវបានដោះស្រាយទាំងអស់ ។ សហករណ៍ ក៏បានវាយសម្រុកលើកទំនប់ ជីកប្រឡាយ ជីកស្រះ ជីកអាងច្រើនស្អេកស្កះដោះស្រាយបញ្ហាទឹកបង្កបង្កើនផលបានមួយកម្រិត ។ ទី៤ៈ សហករណ៍ គឺជាកំផែងនិងជាកម្លាំងការពារពង្រឹងពង្រីករដ្ឋអំណាចបដិវត្តនៅតាមភូមិ-ឃុំ ។ សហករណ៍ជាសម្ព័ន្ធ-ភាពកម្មករ-កសិករដែលចាក់ឫសយ៉ាងជ្រៅនៅតាមគ្រប់មូលដ្ឋានភូមិ-ឃុំនិងជនបទទាំងអស់ ។

ក្រោយពីប្រទេសជាតិបានរំដោះភ្លាម សហករណ៍ បានបន្តពង្រីកតួនាទីរបស់ខ្លួនធ្វើជាអ្នកគ្រប់គ្រងប្រជាជនដែលទើបនឹងរំដោះបានថ្មីៗដែលមានចំនួនជិត២លាននាក់ ។ សហករណ៍ក្រោយមកបានកែប្រែមុខមាត់ជនបទថ្មីឲ្យទៅតំបន់ដែលមានប្រព័ន្ធប្រឡាយភ្លឺស្រែរត់ខ្វាត់ខ្វែង មានទំនប់ទឹក សម្រាប់បញ្ចេញបញ្ចូលធ្វើស្រែទៀតផង ។ ក្រៅពីនោះ សហករណ៍បានជំរុញកសិករវាយសម្រុកបង្កបង្កើនផលទាំងយប់ទាំងថ្ងៃ ដើម្បីសម្រេចទិសដៅបីតោនក្នុងមួយហិកតាជាដាច់ខាត តាមយន្តការមហាលោតផ្លោះ មហាអស្ចារ្យរបស់អង្គការបដិវត្ត ។

ក្រៅពីតួនាទីសំខាន់ៗដែលបានរៀបរាប់ខាងលើនេះនៅមានចំណុចសំខាន់មួយចំនួនដែលនៅក្នុងសៀវភៅនោះបានលើកឡើងថា សហករណ៍ មានគោលជំហរសមូហភាពនិងលះបង់ខ្ពស់ លះបង់នូវទ្រព្យសម្បត្តិ ធនធាន ដីធ្លី គោក្របី ។ល ។ យកមកដាក់ជាកម្មសិទ្ធិរួម ។ សហករណ៍មានគោលជំហរតស៊ូយូរអង្វែងទ្រាំទ្រការលំបាកកម្រិតខ្ពស់រហូតដល់ដណ្តើមបានជ័យជម្នះទាំងស្រុង ។ សហករណ៍ មានវីរភាពបដិវត្តខ្ពង់ខ្ពស់មានគោលជំហរប្រយុទ្ធដាច់ខាត គ្មានរួញរា ឬស្ទាក់ស្ទើរ ទោះបីជាស្ថានការណ៍នោះមានឧបសគ្គឬការលំបាកស្មុគស្មាញយ៉ាងណាក៏ដោយ ក៏សហករណ៍ឈានឆ្ពោះទៅមុខជានិច្ច ឈានពីជ័យជម្នះមួយទៅជ័យជម្នះមួយទៀត ។

**លី សុផល**

## សុំជម្រាបគណៈ៨៧០ ជាទីនឹករឭក

**ឯកសាររបបកម្ពុជាប្រជាធិបតេយ្យ ទូរលេខៈ ១៣, ៣៣០ខ្មែរ**

ខ្ញុំសុំរាយការណ៍បន្ថែមអំពីលទ្ធផលកម្ទេចខ្មាំងនៅថ្ងៃទី៨-៥-៧៨ នៅមុខព្រួញសមមិត្តតាត នឹងសមមិត្តវ៉ាន់ ។

១) មុខព្រួញសមមិត្តតាត មុខព្រួញស្ពានពញ្ញនៅខាងអាគ្នេយ៍ស្ពានពញ្ញយើងវាយអាខ្មាំងធ្វើឲ្យវាស្លាប់នឹងរបួសមួយចំនួននៅខាងកើតកំពង់រកា យើងវាយអាខ្មាំងជាប់កម្លាំងយើងចូលដល់ខាងជើង វាលដំរីស៊ី ត្រង់ចំណុច៧៥៣ ពីលើ០២៦ បាញ់ស្លាប់អាខ្មាំងចំនួន៥ក្បាលមានផ្កាយ២ ពីរក្បាល អត់ផ្កាយបីក្បាល យកបានអាវុធអាកា៥ដើម ឡានហ្ស៊ីបខ្មាំង១គ្រឿង ។

២) មុខព្រួញសមមិត្ត វ៉ាន់ យើងវាយកម្ទេចអាខ្មាំងនៅអូរផ្គាវ ហៅថាស្ពានដែក ស្ពានដែក នេះយើងរំដោះបានទាំងស្រុងហើយ យើងដេញអាខ្មាំងវាបាក់ទ័ពរត់ខ្វាត់ខ្វាយ ហើយយើងកំពុងរៀបចំកម្លាំងវាយដេញវាម្តងទៀត ។ ក្នុងការប្រយុទ្ធនេះយើងរឹបយកបានអាវុធកាំភ្លើងបេ៤០ មួយដើម អាកាមួយដើម គ្រាប់កាំភ្លើងបេ៤០ ៣០គ្រាប់ កាំភ្លើងបេ៤១ ៣០គ្រាប់ គ្រាប់បែកដៃ១០០គ្រាប់ ខ្មាំងត្រូវស្លាប់នឹងរបួសប្រហែល៥០ក្បាល ។ សេចក្តីរាយការណ៍បន្ថែមមានតែប៉ុណ្ណេះ សុំអង្គការជ្រាបជាពត៌មាន ។ ជូនពរសុខសប្បាយនឹងជ័យជម្នះ ។

ថ្ងៃ៩-៥-៧៨ ម៉ោង១១ថ្ងៃត្រង់, សមមិត្ត ពក

ចម្លងជូនៈ អ៊ំ អ៊ំនួន អ៊ំវ៉ន់ អ៊ំវន មន្ទីរឯកសារ

ទទួលថ្ងៃ៩-៥-៧៨ ម៉ោង១៥ៈ៣០នាទី

# បញ្ជីឈ្មោះជនរងគ្រោះជនបរទេសដែលបានកម្ទេចនៅមន្ទីរស-២១

រៀបរៀងដោយៈ យិន ឆាន

(តពីលេខមុន)

| ល.រ | នាម-គោត្តនាម | សញ្ជាតិ | មុខងារ | ចាប់មកពី | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|---|
| ៣៧៤ | ង្វៀង យ៉ាំងង្វៀប | យួន | ចារកិច្ចយួន | កងពលលេខ១៦៤ | ១-៥-៧៨ | ១០-៦-៧៨ |
| ៣៧៥ | ង្វៀង យ៉ាំងហ្កាង | យួន | ? | កំពង់សោម | ២៨-៤-៧៨ | ៦-៥-៧៨ |
| ៣៧៦ | ភ យ៉ាំងតី | យួន | ប្រជាជន | កំពង់សោម | ២៨-៤-៧៨ | ៦-៥-៧៨ |
| ៣៧៧ | ប៉ូយ យ៉ាំងជិន | យួន | ប្រជាជន | កំពង់សោម | ២៨-៤-៧៨ | ៦-៥-៧៨ |
| ៣៧៨ | ង្វៀង យ៉ាំងឌ័ន | យួន | កូនសិស្ស | កំពង់សោម | ១-៥-៧៨ | ៦-៥-៧៨ |
| ៣៧៩ | ង្វៀង ត្រាច | យួន | ប្រជាជន | កំពង់សោម | ១-៥-៧៨ | ៦-៥-៧៨ |
| ៣៨០ | ហូ យ៉ាំងលឿ | យួន | ប្រជាជន | កំពង់សោម | ១-៥-៧៨ | ៦-៥-៧៨ |
| ៣៨១ | ង្វៀង យ៉ាំងកាក | យួន | ប្រជាជន | កំពង់សោម | ១-៥-៧៨ | ៦-៥-៧៨ |
| ៣៨២ | ង្វៀង យ៉ាំងម៉ីង | យួន | ប្រជាជន | កំពង់សោម | ១-៥-៧៨ | ៦-៥-៧៨ |
| ៣៨៣ | ង្វៀង យ៉ាំងឌ៉ុក | យួន | ប្រជាជន | កំពង់សោម | ១-៥-៧៨ | ៦-៥-៧៨ |
| ៣៨៤ | ង្វៀង យ៉ាំងភុក | យួន | បីញញីយៀកកុង | តាកែវ និរតី | ១-៥-៧៨ | ៦-៥-៧៨ |
| ៣៨៥ | ង្វៀង វ៉ាន់វ៉ាង | យួន | ចារកិច្ចយួន | ? | ១៧-១-៧៨ | ២២-៩-៧៨ |
| ៣៨៦ | ម៉ាង ឡាម | យួន | ចារកិច្ចយួន | ត្បូងខ្មុំ | ២២-៧-៧៨ | ២២-៩-៧៨ |
| ៣៨៧ | តុង យ៉ាំងកេ | យួន | ចារកិច្ចយួន | ? | ?-៦-៧៨ | ២២-៩-៧៨ |
| ៣៨៨ | យ៉ាំង វ៉ាន់កាត | យួន | ចារកិច្ចយួន | ? | ១៩៧៨ | ២២-៩-៧៨ |
| ៣៨៩ | ត្រឹង មិញតាយ | យួន | ចារកិច្ចយួន | ? | ៦-១៩៧៨ | ២២-៩-៧៨ |
| ៣៩០ | ង្វៀង យ៉ាំងតេវ | យួន | ហាស៊ី | ? | ១៩៧៨ | ២២-៩-៧៨ |
| ៣៩១ | ហា ទ្រុង | យួន | បីញញី | ភូមិភាគបូព៌ា | ១០-៨-៧៨ | ២២-៩-៧៨ |
| ៣៩២ | ឡេ មិញដាវ | យួន | បីញញី | ភូមិភាគបូព៌ា | ១០-៨-៧៨ | ២២-៩-៧៨ |
| ៣៩៣ | ង្វៀង យ៉ាំងក្រេ | យួន | ចារកិច្ចយួន | ស្វាយរៀង | ២៥-៧-៧៨ | ២២-៩-៧៨ |
| ៣៩៤ | ង្វៀង ថាញ់សឺន | យួន | បីញញី | ភូមិភាគបូព៌ា | ១០-៨-៧៨ | ២២-៩-៧៨ |
| ៣៩៥ | ចូវ គាវ | យួន | ចារកិច្ចយួន | ភូមិភាគបូព៌ា | ២២-៨-៧៨ | ២២-៩-៧៨ |
| ៣៩៦ | ចូវ ដេង | យួន | ចារកិច្ចយួន | ភូមិភាគបូព៌ា | ២២-៨-៧៨ | ២២-៩-៧៨ |
| ៣៩៧ | ដា អឿន | យួន | ចារកិច្ចសៀម | មកពីសៀម | ?-១០-៧៧ | ២២-៩-៧៨ |

ចប់



# ប្រពន្ធ័សន្តិសុខ ភូមិភាគពិសេស ម-១៣

"មន្ទីរសន្តិសុខភូមិភាគពិសេស" ឬហៅថា "មន្ទីរសម្ងាត់ថ្មយោង" មានទីតាំងនៅថ្មយោង ស្ថិតនៅក្នុងព្រៃជ្រៅនៃទឹកដីស្រុកថ្ពង ខេត្តកំពង់ស្ពឺ ចម្ងាយប្រហែល២គីឡូម៉ែត្រពីភូមិប្រជាជនរស់នៅ ។ មន្ទីរសន្តិសុខនេះត្រូវបានបង្កើតឡើងដោយចលនាបដិវត្តន៍ខ្មែរក្រហមតាំងពីឆ្នាំ១៩៧១មកម្ល៉េះ ។ ក្រោយមកដោយមានអ្នកទោសបះបោរប្រឆាំងនឹងកងការពារមន្ទីរនេះយ៉ាងចាស់ដៃរួចមក មន្ទីរសន្តិសុខភូមិភាគពិសេសនេះបានផ្លាស់ប្តូរទីតាំងមកនៅត្រពាំងប្រាប ស្ថិតនៅក្នុងទឹកដី ភូមិថ្មគុប ឃុំអមលាំង ស្រុកថ្ពងវិញ ហើយបានប្តូរឈ្មោះថ្មីមួយទៀតថា "មន្ទីរសន្តិសុខ ម-១៣" ឬហៅថា "មន្ទីរ-១៣" ។ ឌុច (បច្ចុប្បន្នដែលឋិតនៅក្នុងការឃុំឃាំង រង់ចាំការកាត់ទោស) គឺជាអ្នកគ្រប់គ្រងមន្ទីរតាំងពីដំបូងមកម្ល៉េះ រួមជាមួយកម្មាភិបាលជាសមាជិកនិងកងការពារមួយចំនួនទៀតយ៉ាងតឹងតែងបំផុត ។ នៅជុំវិញមន្ទីរខ្មែរក្រហមបានសាងសង់របងយ៉ាងខ្ពស់ (ពីកម្ពស់ពី៥ទៅ៦ម៉ែត្រ) ដែលធ្វើឡើងពីឫស្សីកិននិងឈើក្រាក់ ។ ក្នុងនោះមានផ្ទះលើសពីបួនសម្រាប់ធ្វើជាទីស្នាក់អាស្រ័យរបស់កម្មាភិបាលដឹកនាំមន្ទីរផង កន្លែងសួរចម្លើយផង និងមន្ទីរមួយទៀតសម្រាប់កងការពារស្នាក់នៅ ។ រណ្តៅជាច្រើនត្រូវបានខ្មែរក្រហមជីកសម្រាប់ឃុំឃាំងអ្នកទោស ហើយមានរណ្តៅតែមួយគត់ដែលមានទំហំធំជាងគេក្នុងចំណោមរណ្តៅទាំងនោះសម្រាប់ប្រើជាកន្លែងឃុំឃាំងអ្នកទោសដែលទើបបញ្ជូនមកថ្មី ។

ចាន់ ខន អាយុ៤៧ឆ្នាំ បច្ចុប្បន្នរស់នៅភូមិទេពភិរម្យហៅភូមិក្បាលចិន ឃុំវាលពន់ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ និងជាអតីតកងការពារនៅមន្ទីរម-១៣ បានឲ្យដឹងថា នៅចុងឆ្នាំ១៩៧២និងដើមឆ្នាំ១៩៧៣ អ្នកទោសត្រូវកងសន្តិសុខដាក់ឃុំដូចធម្មតា ប៉ុន្តែបន្ទាប់ពីមានការទម្លាក់គ្រាប់បែកបេ៥២ មកលើបរិវេណមន្ទីរសន្តិសុខនេះ ទើប ឌុច បញ្ជាឲ្យជីករណ្តៅធំៗសម្រាប់ការឃុំឃាំងអ្នកទោសជំនួសវិញ ។ ការបញ្ជាឲ្យជីករណ្តៅសម្រាប់ឃុំឃាំងអ្នកទោសនេះគឺក្នុងបំណងបិទបាំងពីការឃ្លាំមើលរបស់កងទ័ពអាកាសនៃរបបសាធារណរដ្ឋខ្មែរដែលតែងតែហោះឈ្លបយកការណ៍ជាប្រចាំ ។ ស្ទើរតែគ្រប់រណ្តៅ សុទ្ធតែមានធ្វើដំបូលប្រក់ពីលើដោយទម្លាក់សំយាបរហូតស្ទើរដល់ដី ។ នៅជុំវិញបរិវេណមន្ទីរសន្តិសុខម-១៣ គឺមានតែកន្លែងឃុំឃាំងអ្នកទោសទើបនឹងចូលថ្មីមួយប៉ុណ្ណោះដែលមានធ្វើរបងពទ្ធ័ជុំវិញ ចំណែករណ្តៅឯទៀតគ្មានធ្វើរបងពទ្ធ័ឡើយ ។ កងការពារក្មេងៗត្រូវបានដាក់ពង្រាយនៅតាមមាត់រណ្តៅដែលពុំមានរបងដើម្បីការពារការលួចរត់របស់អ្នកទោស ។

## ***សាខានៃមន្ទីរសន្តិសុខ ម-១៣***

សាខាសំខាន់ៗចំនួនបីកន្លែងរបស់មន្ទីរសន្តិសុខភូមិភាគពិសេសម-១៣គឺៈ

ក) មន្ទីរសន្តិសុខនគរបាល មានទីតាំងនៅក្នុងភូមិស្តុកស្អាត ឃុំមានជ័យ ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ ។ មន្ទីរនេះគ្រប់គ្រងដោយកម្មាភិបាល ឈ្មោះ ស៊ុម ។

ខ) មន្ទីរសន្តិសុខភ្នំប្រសិទ្ធិត្រ័យត្រិង្គ មានទីតាំងស្ថិតនៅក្នុងឃុំឈ្យាំង ស្រុកពញាឮ ខេត្តកណ្តាល ។ វ៉ុធ គឺជាកម្មាភិបាលដែលគ្រប់គ្រងមន្ទីរទាំងមូល ។

មន្ទីរសន្តិសុខភ្នំប្រសិទ្ធិត្រ័យត្រិង្គមានបែងចែកគុកឃុំឃាំងអ្នកទោសជា៤ទៀតគឺ ១) នៅក្រោម ដើមម៉ៃសាក់ស្ថិតនៅជាប់នឹងជើងភ្នំត្រ័យត្រិង្គប៉ែកខាងលិច ។ ២) នៅចម្ការស្វាយ ។ ៣) នៅសាលាវត្តភ្នំប្រសិទ្ធិក្រោម និង៤) នៅសាលាវត្តភ្នំប្រសិទ្ធិលើ ។ អ្នកទោសដែលជាប់នៅក្នុងមន្ទីរសន្តិសុខខាងលើនេះត្រូវនាំយកទៅសម្លាប់នៅជើងភ្នំនិងលើភ្នំប្រសិទ្ធិលើ ។ ចំណែកការធ្វើទារុណកម្មវិញ គឺនៅនឹងស្រះទឹកមួយនៅលើកំពូលភ្នំដែលមានទំហំមាត់លើ៨ម៉ែត្រ ជម្រៅជាង១ម៉ែត្រ ។ តាមការស្រាវជ្រាវរបស់ក្រុមដែនទីរណ្តៅសាកសពកាលពីឆ្នាំ១៩៩៨បានឲ្យដឹងថា ការសួរចម្លើយអ្នកទោសបានធ្វើឡើងជារបៀបដាក់ទណ្ឌកម្មមួយ

យ៉ាងសាហាវ អ្នកទោសត្រូវចងជើងព្យួរឡើងលើក្តាប់នឹងបង្គោលមួយ រួចទម្លាក់ក្បាលចុះទៅក្នុងស្រះទឹកប្តូដាក់បញ្ឈរឲ្យធ្វើពលកម្មវាយថ្ម និងជីកស្រះទឹក ។ ការប្រជុំបានធ្វើឡើងរៀងរាល់ពីរទៅបីសប្តាហ៍ម្តង ហើយបន្ទាប់ពីការប្រជុំគឺមានអ្នកទោសយ៉ាងហោចណាស់ពី៥០ទៅ១០០នាក់បានត្រូវសម្លាប់ ដោយសារមូលហេតុចង់វិលត្រឡប់ទៅផ្ទះនិងសហករណ៍ដែលខ្លួនធ្លាប់រស់នៅ ។ តាមរបាយការណ៍ដែលដកស្រង់ចេញពីការស្រាវជ្រាវនៃក្រុមផែនទីរណ្តៅសាកសពឆ្នាំ១៩៩៨ បានឲ្យដឹងថា មានមនុស្សចំនួនជាង៧០០០នាក់បានត្រូវសម្លាប់ ហើយដែលការសម្លាប់នេះបានចាប់ផ្តើមខ្លាំងតាំងពីឆ្នាំ១៩៧៥ រហូតដល់ចុងឆ្នាំ១៩៧៨ ។

ក) មន្ទីរសន្តិសុខម-៩៩ មានទីតាំងស្ថិតនៅក្នុងព្រៃជ្រៅនៃព្រំប្រទល់ឃុំតាសាល និងឃុំរស្មីសាមគ្គី ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ។ មន្ទីរសន្តិសុខនេះមានការផ្លាស់ប្តូរអ្នកគ្រប់គ្រងជាច្រើនដំណាក់កាល ។ការគ្រប់គ្រងមន្ទីរដំបូងគឺសមមិត្ត ឆៃ ជាអ្នកដឹកនាំបន្ទាប់មកសមមិត្ត គុល និងសមមិត្ត ណម ។ មន្ទីរម-៩៩ នេះត្រូវរស់នៅពឹងផ្អែកទាំងស្រុងលើកម្លាំងពលកម្មរបស់អ្នកទោស ។ តាមការស្រាវជ្រាវរបស់ក្រុមផែនទីរណ្តៅសាកសព កាលពីឆ្នាំ២០០១កន្លងទៅបានឲ្យដឹងថា មន្ទីរ ម-៩៩ មានឃុំឃាំងនិងសម្លាប់អ្នកទោសអស់យ៉ាងច្រើនសន្ធឹកសន្ធាប់ ។ នៅឆ្នាំ១៩៧៧ មន្ទីរម-៩៩ ត្រូវរុះរើ និងរំលាយចោលទាំងស្រុង ដោយសារមានព្រឹត្តិការណ៍ឈ្លោះទាស់ទែងគ្នារវាងមេដឹកនាំមន្ទីរ (ណម និងគល់) ថាជាប់ខ្សែក្បត់ និងបានក្បត់នឹងបដិវត្តន៍ ព្រមទាំងបានប្រព្រឹត្តខុសសីលធម៌ជាមួយនឹងអ្នកទោសដែលជាប្រជាជនថ្មី ។

## អ្នកទោសនៅមន្ទីរ ម-១៣

ការឃុំឃាំងអ្នកទោសនៅក្នុងមន្ទីរសន្តិសុខម-១៣ បានចាប់ផ្តើមឡើងតាំងពីការបង្កើតមន្ទីរនេះ ។ អ្នកទោសច្រើននាក់ណាស់ដែលបានមកជាប់នៅក្នុងមន្ទីរសន្តិសុខម-១៣ នេះ ។ កាលពីដំបូង អ្នកទោសច្រើនជាប្រភេទទាហាននិងប្រជាជនមូលដ្ឋានដែលមិនព្រមដើរតាមមាគ៌ាដ៏ភ្លឺស្វាងរបស់បក្ស ។ មន្ទីរសន្តិសុខម-១៣ បានត្រូវពង្រីកនិងបន្ថែមអ្នកទោសរាប់សិបនាក់ទៀត ដែលសុទ្ធសឹងជាប្រជាជនថ្មីនិងអ្នកមកពីទីឆ្ងាយៗ ។ នៅក្នុងឆ្នាំ១៩៧៣ កម្មាភិបាលដែលទើបតែត្រឡប់មកពីក្រុងហាណូយ ប្រទេសវៀតណាមប្រហែលជាង១០នាក់ បានមកធ្វើជាកម្មាភិបាលត្រួតត្រាអ្នកទោសជាមួយនឹងក្រុមរបស់ ឌុច និងជាអ្នកសួរចម្លើយអ្នកទោសផង ។ ប៉ុន្តែមិនយូរប៉ុន្មានអ្នកទាំងជាង១០នាក់នោះបានក្លាយទៅជាអ្នកទោសវិញ ព្រោះថាក្រោយមកត្រូវកងការពារនាំយកទៅសម្លាប់


ហម អ៊ីន

ទាំងអស់ដោយយកលេសថា "ទៅរៀនសូត្របន្ថែម" ។ ហម អ៊ីន ដែលជាអតីតអ្នកទោសនៅក្នុងមន្ទីរម-១៣ បាននិយាយប្រាប់ថា គាត់ជាអ្នកបានឃើញកម្មាភិបាលដែលមកពីទីក្រុងហាណូយដោយផ្ទាល់ភ្នែក តាំងពីទើបមកដល់មន្ទីរដំបូងនិងថ្ងៃចុងក្រោយមុននឹងត្រូវទៅរៀនសូត្របន្ថែម ។ ចំណែកឯអ្នកទោសមួយប្រភេទទៀត គឺយុទ្ធជនខ្មែរក្រហមដើរហើរសេរីនិងកម្មាភិបាលខ្មែរក្រហមដែលមានឋានៈធំៗ ។ ហម អ៊ុន បានជាប់ឃុំនៅមន្ទីរម-១៣ កាលពីខែមិថុនា ឆ្នាំ១៩៧៣ ។ ចាន់ ខន បានប្រាប់ពីឋានៈរបស់កម្មាភិបាលខ្មែរក្រហមទាំងនោះថា ខ្លះមានឋានៈជាប្រធានកងពល ខ្លះជាគណៈស្រុក ខ្លះជាប្រធានវរសេនាតូច ។ គ្មានអ្នកទោសណាម្នាក់បានដឹងពីទោសកំហុសរបស់ខ្លួន


ចាន់ ខន

ឡើយ គឺមានតែអង្គការមួយគត់ដែលអាចមើលឃើញពីទោសកំហុសរបស់មនុស្សម្នាក់ៗបាន ។ អុីន បានប្រាប់ថា គាត់មិនបានដឹងពីទោសកំហុសរបស់គាត់ឡើយ ។ អុីន គ្រាន់តែជាអ្នកកូតវីយូឡុងម្នាក់ស្ថិតនៅក្នុងក្រុមសិល្បៈប្រចាំតំបន់ប៉ុណ្ណោះ ។ ចំណែកអ្នកទោសឯទៀតៗសុទ្ធតែសម្តែងនូវភាពងឿងឆ្ងល់ថា តើខ្លួនមានកំហុសអ្វី? ។ អ្នកទោសទាំងអស់ត្រូវជាប់ឃុំនៅក្នុងរណ្តៅធំជម្រៅប្រហែលពី៤ទៅ៥ម៉ែត្រ ជាបណ្តោះអាសន្នសិនទម្រាំមានបញ្ជាឲ្យធ្វើការបែងចែកប្រភេទអ្នកទោសឡើងវិញ ។ ក្រោយមកការបែងចែកប្រភេទអ្នកទោសបានចាប់ផ្តើមឡើង ។ ឌុច យល់ថាប្រភេទអ្នកទោសធ្ងន់ត្រូវដាក់ខ្នោះជើង ហើយត្រូវបញ្ជូនទៅដាក់រណ្តៅមួយចំនួនដែលក្នុងមួយរណ្តៅអាចដាក់អ្នកទោសបាន២០នាក់ ។ រណ្តៅទាំងនេះស្ថិតនៅក្បែរៗមាត់ស្ទឹងនិងនៅក្បែររណ្តៅមួយដែលធំជាងគេ ។ លើសពីនេះ ឌុច បានបញ្ជាឲ្យជីករណ្តៅជាច្រើនទៀតសម្រាប់ការធ្វើទណ្ឌកម្ម ។ អុីន បានរៀបរាប់ពីរណ្តៅមួយប្រភេទទៀតដែលជារណ្តៅសម្រាប់ធ្វើទារុណកម្មអ្នកទោសថាមានទំហំទទឹងកន្លះម៉ែត្រ បណ្តោយប្រវែងដងខ្លួនមនុស្ស និងជម្រៅ២ម៉ែត្រ ដែលក្នុងរណ្តៅមួយអាចដាក់មនុស្សបានតែម្នាក់ប៉ុណ្ណោះ ។ រណ្តៅរបៀបនេះត្រូវបានជីកជាប់ផ្ទៃគ្នានិងជិតៗគ្នា ។ នៅបាតរណ្តៅមានចោះប្រហោងទម្លុះដីពីរណ្តៅមួយទៅរណ្តៅមួយទៀតសម្រាប់សឺករនុកភ្ជាប់នឹងខ្នោះដែលដាក់នៅជាប់កជើងអ្នកទោស ។ នៅមានរណ្តៅមួយប្រភេទទៀតដែលមានទំហំតែកន្លះម៉ែត្របួនជ្រុងជម្រៅមួយម៉ែត្រកន្លះ ហើយគ្មានប្រក់ដំបូលពីលើទេសម្រាប់ឃុំឃាំងអ្នកទោសដែលអង្គុយមិនអាចកម្រើកខ្លួនរួច ។

### ការសួរចម្លើយ ការធ្វើទារុណកម្មនិងមន្ទីររបស់កម្មាភិបាលជាន់ខ្ពស់នៅមន្ទីរម-១៣

នៅគ្រប់ពេលសួរចម្លើយ ប្រសិនបើអ្នកទោសណាម្នាក់ផ្តល់ចម្លើយមិនត្រឹមត្រូវតាមអ្វីដែលអ្នកសួរចង់បាន គឺពិតជាត្រូវទទួលទណ្ឌកម្មយ៉ាងធ្ងន់ធ្ងររហូតដល់សម្លាប់ចោល ។ ហម អុីន បានប្រាប់ថា នៅពេលគាត់ត្រូវចាប់ខ្លួនបញ្ជូនទៅកាន់មន្ទីរម-១៣ ដំបូងអ្នកទោសដែលជាប់មុនគាត់បានខ្សឹបប្រាប់ថា "ត្រូវតែឆ្លើយថាធ្លាប់ធ្វើនេះធ្វើនោះ បើមិនដូច្នេះទេនឹងត្រូវសម្លាប់ខ្លួនមិនខាន" ។ មិនយូរប៉ុន្មាន អុីន ក៏ត្រូវនាំយកទៅសួរចម្លើយដោយ ឌុច ហើយ អុីន បានធ្វើតាមពាក្យសម្តីដែលអ្នកទោសដូចគ្នានិយាយប្រាប់មែន ។ អុីន បានឆ្លើយសារភាពនៅចំពោះមុខ ឌុច ទាំងកុហកខ្លួនឯងថា "ធ្លាប់ធ្វើជាប៉ូលិសពាក់លឿងបីដាន" ។ ចំណែកបងប្រុសរបស់ អុីន ម្នាក់ដែលពុំបានដឹងរឿងនេះជាមុននោះ បានឆ្លើយសារភាពតាមអ្វីដែលខ្លួនយល់ថាពិតប្រាកដប្រាប់ ឌុច ប៉ុន្តែបែរជាត្រូវទទួលទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរទៅវិញ ហើយក្រោយមកត្រូវកងការពារនាំយកទៅសម្លាប់ចោល ។ អុីន បានរួចខ្លួនពីការធ្វើទារុណកម្មនិងត្រូវបានដោះលែងទៅជាអ្នកទោសប្រភេទស្រាលដែលគ្មានជាប់ខ្នោះ និងធ្វើជាជំនួយការរោងបាយប្រចាំមន្ទីរ ។ អុីន បាននិយាយតាមសម្តីរបស់ ឌុច ថា "អ្នកដែលចាប់មកដាក់នៅក្នុងមន្ទីរនេះគឺសុទ្ធតែអ្នកមានទោសកំហុស ដូច្នេះការឆ្លើយសារភាពត្រូវតែឆ្លើយពីទោសកំហុសរបស់ខ្លួន" ។ ការសួរចម្លើយបានប្រព្រឹត្តទៅជារៀងរាល់ថ្ងៃ ដោយមានការចូលរួមសួរពីសំណាក់កម្មាភិបាលធំៗប្រចាំមន្ទីរដូចជា ឌុច, ចាន់, ប៉ុន, ដល និងមាស ។ ទារុណកម្មនិងការសួរចម្លើយបានធ្វើឡើងនៅក្នុងរណ្តៅដែលមានទំហំ៤ម៉ែត្រការ៉េ ជម្រៅពី៥ទៅ៦ម៉ែត្រ និងមានបង្គោលក្រាក់មួយនៅចំកណ្តាលរណ្តៅដង ។ រណ្តៅរបៀបនេះត្រូវបានជីកជាប់ផ្ទៃគ្នាយ៉ាងច្រើនតាមបណ្តោយមាត់ស្ទឹងត្រើយខាងលិច ។

កម្មាភិបាលដែលសួរចម្លើយអ្នកទោសបានពឹងផ្អែកលើឧបករណ៍ចាំបាច់មួយចំនួនដូចជា ម្ជុល ច្រវាក់ ញញួរ បន្ទាត់ និងដង្កាប់ ដែលដាក់គម្រៀបនៅលើតុជាស្រេច ។ អ្នកទោសដែលត្រូវយកមកធ្វើទារុណកម្ម មុនដំបូងត្រូវកងឈ្លបចងដៃទាំងពីរទៅក្រោយភ្ជាប់នឹងបង្គោលក្រាក់ ហើយទាញរ៉ឺតឡើងលើឲ្យជើងហើបផុតពីដី រួចទើបចាប់ផ្តើមធ្វើទារុណកម្ម ។ អ្នកទោសខ្លះទៀត ត្រូវវាយបញ្ចូលម្ជុលទៅក្នុងក្រចកដៃដោយបន្ទាត់ម្តងបន្តិចៗ ។ បន្ទាប់ពីអ្នកទោសផ្តល់ចម្លើយត្រឹមត្រូវហើយ ទើបម្ជុលត្រូវដកចេញមកវិញដោយដង្កាប់ ។ កម្មាភិបាលដែលមានភារកិច្ចសួរចម្លើយគឺ ឌុច, ចាន់, ដល, ប៉ុន និង មាស ។ កម្មាភិបាលទាំងអស់នេះ សុទ្ធតែមានកន្លែងសួរចម្លើយប្រចាំខ្លួនម្នាក់មួយទៀត គឺនៅនឹងមន្ទីរស្នាក់នៅរបស់ខ្លួនតែម្តង ។ ឌុច

ជាអ្នកសួរចម្លើយដោយផ្ទាល់ទៅលើប្រភេទអ្នកទោសដែលត្រូវចោទប្រកាន់ថា មានឋានៈខ្ពស់ជាងគេនៅក្នុងមន្ទីរសន្តិសុខម-១៣ ។ មន្ទីររបស់ ឌុច មានទីតាំងស្ថិតនៅចម្ងាយប្រហែល៥០ម៉ែត្រពីត្រពាំងប្រាប ។ ឧបករណ៍សម្រាប់ ឌុច សួរចម្លើយមានកាំបិត និង ចន្លុះ ។ អ៊ុន បានប្រាប់ថា ឌុច ជាមនុស្សកាចជាងគេក្នុងការសួរចម្លើយនិងធ្វើទារុណកម្មអ្នកទោស ។ ចំណែកចាន់ ក៏ដូច្នេះដែរ លើកលែងតែ ប៉ុន និង ផល ប៉ុណ្ណោះ ដែលពុំសូវមាត់កធំៗខ្លាំងៗ និងវាយដំអ្នកទោស ។ អ៊ុន បានប្រាប់ពីវិធីដែល ឌុច ធ្វើទារុណកម្មមកលើបងប្រុសរបស់គាត់ថា ឌុចបានចងដៃទាំងពីរព្យួរឡើងលើភ្ជាប់នឹងបង្គោលក្រោក រួចយកកាំបិតចាក់លើរាងកាយសព្វកន្លែងតាំងពីដើមដៃរហូតដល់ចុងជើង ។ នៅចុងបាតជើងដែលផុតពីដី ឌុច បានដាក់ចានដែកមួយទុកត្រងឈាមហូរចេញពីស្នាមកាំបិតដែលចាក់ ។ ទារុណកម្មមួយប្រភេទទៀតដែល ឌុច ប្រព្រឹត្តទៅលើអ្នកទោសដែលគាត់យល់ថាផ្តល់ចម្លើយមិនត្រឹមត្រូវគឺ យកញញួរឈើទៅវាយដើមទ្រូងនិងខ្នងរហូតទាល់តែអ្នកទោសសន្លប់បាត់ស្មារតី និងជួនកាលស្លាប់ទៀតក៏មាន ។ វិធីសំខាន់មួយទៀតគឺ ឌុច បញ្ច្រកទឹកសាប៊ូចូលក្នុងពោះអ្នកទោសដោយប្រើទុយយោសិកបញ្ចូលតាមបំពង់ក ។ វិធីទាំងប៉ុន្មាននេះ គឺជាវិធីដែលសាហាវបំផុតនិងជាបទពិសោធន៍ធ្ងន់ធ្ងរបំផុតមួយសម្រាប់ជីវិតរបស់ ឌុច ដែលធ្លាប់ឆ្លងកាត់និងជួបប្រទះកាលពីអំឡុងឆ្នាំ១៩៦៧ដល់ឆ្នាំ១៩៧០គឺក្នុងចន្លោះពេលដែល ឌុច ជាប់គុក ដោយសារតែមានជាប់ពាក់ពន្ធ័នឹងរឿងរ៉ាវបោះខិត្តប័ណ្ណឃោសនាបម្រើឲ្យចលនាខ្មែរក្រហម ។ បទពិសោធន៍ទាំងអម្បាលម៉ាននេះបានត្រូវ ឌុច យកមកប្រើធ្វើទារុណកម្មលើអ្នកទោសមន្ទីរម-១៣ ទាំងមូលវិញម្តង ។ នៅឆ្នាំ១៩៧២ មន្ទីរទាំងមូលស្ថិតក្នុងការគ្រប់គ្រងរបស់ឌុច នៅឡើយដែលត្រូវតែអនុវត្តតាមអ្វីដែល ឌុច ចង់បាន ។ រាល់ចម្លើយដែលត្រឹមត្រូវនិងដែលអង្គការចង់បានបំផុតនោះគឺត្រូវតែឆ្លើយថា “ធ្លាប់ធ្វើទាហានប៉ូលិសនិងមន្ត្រីថ្នាក់ធំៗនៅសម័យសាធារណរដ្ឋខ្មែរ” ។ តាមប្រសាសន៍របស់ អ៊ុន ថា ឌុចជាមនុស្សមានអត្តចរិតចម្លែកជាងមនុស្សផ្សេងទៀតបន្តិច ថ្វីដ្បិតតែ ឌុច ចូលចិត្តនិយាយលេងច្រើននិងសើចញុំៗជាមួយអ្នកទោសក៏ដោយ ប៉ុន្តែ ឌុច មិនដែលមានមេត្តាធម៌ជាមួយអ្នកទោសណាម្នាក់ឡើយ ។ អ៊ុន បាននិយាយថា “ជួនកាលពេលកំពុងតែជជែកលេងសប្បាយជាមួយអ្នកទោស ស្រាប់តែ ឌុច នឹកឃើញថាចង់សម្លាប់អ្នកទោសណាម្នាក់ គាត់ក៏បញ្ជាឲ្យកងការពារទៅដោះយកអ្នកទោសចេញពីខ្នោះ ហើយបណ្តើរយកទៅសម្លាប់ភ្លាម” ។ អ៊ុន ធ្លាប់បានឮការស្រែកបញ្ជានេះដោយផ្ទាល់ ។ ឌុចឧស្សាហ៍ហៅ អ៊ុន មកជជែកលេងជាមួយណាស់ពីរឿងរ៉ាវដែលគាត់ធ្លាប់ជាប់គុកកាលពីសម័យសង្គមរាស្ត្រនិយមនិងរឿងរ៉ាវជាច្រើនទៀត ហើយ អ៊ុន ក៏ធ្លាប់ត្រូវ ឌុច ស្តីបន្ទោសខ្លាំងណាស់ដែរ ។ អ៊ុន បាននិយាយដូច្នេះថា ថ្ងៃមួយគាត់បានដើរចូលទៅកាន់រោងបាយ ដោយមិនដឹងថាមានការប្រជុំនៅទីនោះទេស្រាប់តែឌុច ចេញមកស្រែកសម្លុតនិងចោទគាត់ថា មានបំណងចង់យកការណ៍ឲ្យខ្មាំង ។ ប៉ុន្តែ អ៊ុន បានប្រាប់ពីមូលហេតុនិងគោលបំណងនៃការមកកាន់រោងបាយនេះថា គាត់ចង់មកជួបប្រពន្ធ ចាន់ ជាប្រធានរោងបាយដើម្បីសួរពីរឿងរកម្ហូបអាហារ ។ ក្រោយពីបញ្ជាឲ្យកងការពាររបស់ខ្លួនសម្លាប់អ្នកទោស ឌុច ក៏ធ្វើដោយខ្លួនឯងដែរ ។ ដូចក្នុងករណីបាញ់សម្លាប់អ្នកទោសជាច្រើននាក់ដែលចាន់ ខន បាននិយាយឲ្យដឹងថា គាត់មិនចាំចំនួនជនរងគ្រោះដែលឌុច បានសម្លាប់ឡើយ ។ ចាន់ ខន និយាយទៀតថា ក្រុមកងការពាររបស់គាត់ធ្លាប់បានទទួលបញ្ជាពី ឌុច ឲ្យបាញ់ប្រហារអ្នកទោសនៅពេលដែលលួចរត់ចេញ ។ អ៊ុន ក៏បាននិយាយថា ក្រុមកងការពារក៏ទទួលបញ្ជាឲ្យធ្វើទារុណកម្មអ្នកទោសដែរ ។ តាមការនិយាយរបស់ អ៊ុន បានឲ្យដឹងថា ចាន់ ខន ដែលជាកងការពារអ្នកទោសនៅមន្ទីរម-១៣ ធ្លាប់បានធ្វើទារុណកម្មមកលើជីតារបស់ខ្លួនឈ្មោះ សុខ ដែលជាអ្នកទោសនៅមន្ទីរម-១៣ ។ អ៊ុននិយាយទៀតថា ជីតារបស់ ខន បានហៅ ខន ថា “បង” ចំណែកឯខន វិញ ក៏និយាយតបភ្លាមថា “អើ! គេក្មេងមែន តែគេបងខាងបដិវត្តន៍” ។ នៅឆ្នាំ១៩៧៩ ខន បានលើកដៃសំពះសុំទោសចំពោះអំពើដែលខ្លួនបានធ្វើកាលពីនៅក្នុងមន្ទីរម-១៣ នៅចំពោះមុខជីតារបស់គាត់ឈ្មោះ សុខ ដោយលើកហេតុផលថា “មកពីនៅក្មេងមិនដឹងអី” ។

## ការងាររបស់អ្នកទោស

អ្នកទោសដែលនៅសេសសល់ពីការសម្លាប់និងអ្នកទោសដែលចូលថ្មី ត្រូវធ្វើការងារជារៀងរាល់ថ្ងៃទាំងនៅជាប់ច្រវាក់និងចំណង ដោយមានកងការពារជាអ្នកមើលការខុសត្រូវ ។ ការឃ្លាំមើលរបស់កងការពារមានសភាពម៉ឺងម៉ាត់បំផុត ។ កងការពារអ្នកទោសមានសិទ្ធិបាញ់អ្នកទោសសម្លាប់ចោលនៅពេលណាដែលនរណាម្នាក់ព្យាយាមលួចរត់ចេញពីមន្ទីរសន្តិសុខក្នុងពេលបំពេញការងារ ។ អ្នកទោសមួយភាគបានស្លាប់ពេលបំពេញភារកិច្ចដោយសារការបាក់កម្លាំងនិងការគ្មានរបបអាហារគ្រប់គ្រាន់ ។ ការងាររបស់អ្នកទោស គឺលើកទំនប់ ដាំដំឡូងកាប់ឆ្ការព្រៃ និងរានដីធ្វើស្រែ ។ ផលដែលទទួលបានពីការខិតខំផលិតរបស់អ្នកទោសមិនត្រូវបានផ្តល់ដល់អ្នកទោសឡើយ ។ របបអាហារត្រូវពឹងផ្អែកទាំងស្រុងទៅលើការចាត់ចែងរបស់កម្មាភិបាលដែលជាអ្នកកាន់កាប់រោងបាយប្រចាំមន្ទីរ ។

## របបអាហារ

អ្នកទោសម្នាក់អាចទទួលបានរបបអាហារក្នុងមួយពេលតែបបរាវកក្កុកមួយបំពង់ឫស្សីតូចប៉ុណ្ណោះ ។ ចំណែករបបអាហារក្នុងមួយពេលរបស់កងការពារអ្នកទោសវិញ គឺបាយមួយចានលាយជាមួយដំឡូងមី និងពោតដែលផលិតដោយកម្លាំងរបស់អ្នកទោស ។ ប៉ុន្តែជួនកាលកងការពារក៏ទទួលរបបបបរមួយកូនចានដូចអ្នកទោសដែរ លើកលែងតែថ្នាក់កម្មាភិបាលប៉ុន្មាននាក់ប៉ុណ្ណោះដែលទទួលបានរបបបាយគ្រប់ពេលនិងម្ហូបគ្រាន់បើ ។ ប្រពន្ធរបស់ ចាន់ គឺជាប្រធានគ្រប់គ្រងរោងបាយមន្ទីរសន្តិសុខ ម-១៣ ។ អ៊ីន បានរៀបរាប់ពីការដាំបបរដែលជារបបរបស់អ្នកទោសថា ក្នុងបបរមួយខ្ទះគឺដាក់អង្ករតែពីរកំប៉ុងប៉ុណ្ណោះ លាយជាមួយពោតក្រហមខ្លះ ស្លឹកដំឡូងមីខ្លះនិងស្លឹកដំឡូងជ្វាខ្លះ ។

## សេដ្ឋកិច្ច

សេដ្ឋកិច្ចនៅមន្ទីរម-១៣ ត្រូវពឹងផ្អែកទាំងស្រុងលើការបង្កបង្កើនផល ការដាំបន្លែ ផ្លែឈើ និងការនេសាទត្រីរបស់អ្នកទោសប្រភេទស្រាល ។ អ៊ីន ជាអ្នកនេសាទត្រីនៅក្នុងស្ទឹងដែលហូរកាត់មន្ទីរ និងត្រពាំងប្រាបដែលស្ថិតនៅក្បែរភ្នា ។ ឌុច បានដោះលែង អ៊ីន ឲ្យធ្វើជាអ្នកនេសាទប្រចាំរោងបាយមន្ទីរម-១៣ ។ អ៊ីន ជាមនុស្សម្នាក់មានជំនាញច្បាស់លាស់ក្នុងការចាប់ត្រីនឹងដៃ ព្រោះកាលពីនៅក្មេងៗ គាត់ធ្លាប់បានទៅនេសាទត្រីជាមួយឪពុករបស់គាត់ ។

## ការប្រជុំនយោបាយ

ក្នុងមួយសប្តាហ៍ ឌុច បានកោះហៅសមាជិករបស់ខ្លួននៅតាមសាខាមួយចំនួនរបស់មន្ទីរសន្តិសុខមកចូលរួមប្រជុំនៅនឹងមន្ទីររបស់ ឌុច ផ្ទាល់តែម្តង ។ រៀងរាល់បីសប្តាហ៍ ឬមួយខែម្តង ឌុច តែងតែស្ពៀកពាក់ស្អាតបាតឡើងទៅប្រជុំនៅក្រោមន្ទីរម-១៣ ។ យានជំនិះរបស់ ឌុច គឺម៉ូតូប៉ូបឺខ្សែត ។ អ៊ីន និយាយថាគាត់មិនបានដឹងថា ឌុច ឡើងទៅប្រជុំនៅទីណាទេ ប៉ុន្តែរាល់ពេលដែលត្រឡប់មកពីប្រជុំវិញ ឌុច តែងតែបន្ថែមភារកិច្ចថ្មីៗទៀតដល់កងការពារកម្មាភិបាលថ្នាក់ក្រោមនិងអ្នកទោស ។ អ៊ីន និយាយទៀតថា នៅពេលដែល ឌុច មកដល់ភ្លាមគាត់បានដាក់បញ្ជាឲ្យកងការពារក្មេងៗយកអ្នកទោសមួយចំនួនទៅសម្លាប់ចោលភ្លាម ។

## គណៈគ្រប់គ្រងមន្ទីរ ម-១៣

១) ឌុច ជាប្រធានមន្ទីរ ម-១៣ មានភារកិច្ចមើលការខុសត្រូវក្នុងមន្ទីរ គ្រប់គ្រងកងការពារ និងកងសួរចម្លើយអ្នកទោសដែលមានឋានៈខ្ពស់ជាងគេ ។

២) ចាន់ ជាអនុប្រធានមន្ទីរ ម-១៣ មានភារកិច្ចមើលការខុសត្រូវក្នុងមន្ទីរនៅពេលដែល ឌុច អវត្តមាន និងសួរចម្លើយអ្នកទោសដែលមានឋានៈខ្ពស់បន្ទាប់ៗមក ។

៣) ប៉ុន ជាសមាជិកមន្ទីរ ម-១៣ មានភារកិច្ចសួរចម្លើយអ្នកទោស និងធ្វើទារុណកម្ម ។

៤) ផល ជាសមាជិកមន្ទីរ ម-១៣ មានភារកិច្ចសួរចម្លើយអ្នកទោស និងធ្វើទារុណកម្ម ។

៥) មាស ជាសមាជិកមន្ទីរ ម-១៣ មានភារកិច្ចសួរចម្លើយអ្នកទោស ធ្វើទារុណកម្ម និងសម្លាប់ ។ តាមសម្តីរបស់ ចាន់ ខន ជាកងការពារនៅមន្ទីរ១៣ ថា មាស ជាកម្មាភិបាលម្នាក់ដែលបានសម្លាប់អ្នកទោសអស់ច្រើនជាងគេ ដោយទទួលបញ្ជាពីឌុច ។ អ៊ីន បានប្រាប់ថាចំណែក ឌុច ក៏សម្លាប់អ្នកទោសអស់ច្រើនដែរ ព្រមទាំងធ្លាប់វាយដំធ្វើទារុណកម្មខ្លាំងៗទៅលើអ្នកទោស

ច្រើនសន្ទឹកសន្ធាប់ផង ។ ថ្វីដ្បិតតែការធ្វើទារុណកម្មរបស់ ឌុច មិនទាន់ធ្វើឲ្យអ្នកទោសស្លាប់ភ្លាមៗក៏ពិតមែន ប៉ុន្តែ អ៊ីន និយាយថារយៈពេលប៉ុន្មានថ្ងៃក្រោយមក អ្នកទោសទាំងនោះពិតជាត្រូវស្លាប់មិនខាន ។

កម្មាភិបាលទាំង៥នាក់ខាងលើនេះ គឺជា "ជនចម្រើន" របស់បដិវត្តន៍ ។ ចាន់ វឿន បាននិយាយថា ជនចម្រើនគឺអ្នកដែលបានធ្វើទារុណកម្មយ៉ាងខ្លាំងក្លាទៅលើអ្នកទោស និងជាអ្នកដែលអង្គការបក្សទុកចិត្តបំផុតមិនដូចកងការពារដែលរង់ចាំតែទទួលបញ្ជាពីថ្នាក់លើយកមកអនុវត្តជាមួយអ្នកទោសទេ ។

**កងការពារ**

កងការពារនៅមន្ទីរ ស-២១ ត្រូវខ្មែរក្រហមជ្រើសរើសយកតែក្មេងៗដែលមានអាយុក្រោម១៥ឆ្នាំ ។ កងការពារទាំងនេះគឺ ឌុច ជាអ្នកដែលជ្រើសរើសដោយផ្ទាល់ ។ អ៊ឹម វ៉ន ហៅ ឌិន ជាអតីតកងការពារមន្ទីរ ស-២១ ត្រូវបាន ឌុច ទៅយកពីឪពុកម្តាយនៅភូមិក្រាំង ឃុំប្រាំបីមុំ ស្រុកថ្ពងមក ។ ឌិន គឺជាឈ្មោះប្រើ ពេលមកធ្វើជាកងការពារមន្ទីរ ស-២១ ។ ចំណែក វ៉ន ជាឈ្មោះទើបនឹងដាក់នៅពេលក្រោយ ។ វ៉ន បានប្រាប់ថាឈ្មោះនេះគាត់ដាក់នៅពេលដែលគាត់ស្ម័គ្រចិត្តចូលបម្រើកងទ័ពរដ្ឋាភិបាលកម្ពុជាកាលពីអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ។ ឌុច បានទៅជ្រើសរើស ចាន់ វឿន និងមិត្តភក្តិម្នាក់ទៀតពីទីលានហ្វឹកហាត់មួយកន្លែងនៅក្នុងទឹកដីស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។ ចំណែក ចាន់ ខន ត្រូវ ឌុច ជ្រើសរើសយកមកតាមរយៈការសម្រាំងពីថ្នាក់ភូមិនិងឃុំ ។ ចំណែកកងការពារផ្សេងទៀតក៏ត្រូវ ឌុច ជ្រើសរើសដូច វ៉ន ខន និងវឿន ដែរ ។ តាមការសម្ភាសន៍ជាមួយនឹងអ៊ីពូដែលជាអ្នកស្រុកថ្ពងបានឲ្យដឹងថា ឈ្មោះ ខែល គុន (កូនអ៊ំស្រី ញ៉ាំង យី) បេ (កូនអ៊ំស្រី ហែម) គឹម អុន (កូនអ៊ំស្រី ដួង នួច) ប៉ៅ កាក់ (ក្មួយពូ សី ជា) ហែម បឿន (កូនយាយ ស៊ឹម) និងអឿន (កូនយាយ យក់) ត្រូវបានបំបែកចេញពីគ្រួសារហើយរហូតមកដល់នឹងពេលបច្ចុប្បន្ននេះនៅតែបាត់រហូតមិនឃើញត្រឡប់មកផ្ទះវិញឡើយ ។ កងកម្លាំងការពារទាំងប៉ុន្មានដែល ឌុច ជ្រើសរើសយកមកបម្រើការងារនៅក្នុងមន្ទីរ ស-២១ មានមួយចំនួនមិនបានហាត់រៀនក្បួនយុទ្ធសាស្ត្រអ្វីទាំងអស់និងមិនដែលស្គាល់ការងារយ៉ាងម៉េចឡើយពីមុនមក ។ អ៊ីន និយាយដូច្នេះថា "កងការពារសុទ្ធតែជាមនុស្សថ្មីនិងក្មេងៗបំផុត" ។ ការប្រមែប្រមូលកងការពារមានវ័យក្មេងៗនេះបានបញ្ចប់នៅដើមឆ្នាំ១៩៧៣ ។ ការរៀបចំក្រុមមួយបានបង្កើតឲ្យមានឡើងសម្រាប់ដាក់ឲ្យក្រុមកងការពារអនុវត្ត ។ កងការពារចំនួនជាង ១០នាក់ សុទ្ធតែជ្រើសរើសយកមកពីឃុំប្រាំបីមុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។ កងការពារទាំងនេះត្រូវបានបែងចែកជាពីរក្រុមធំៗ គឺ ១) ការពារអ្នកទោសនៅក្នុងមន្ទីរឃុំឃាំង និង២) ការពារអ្នកទោសពេលកំពុងបំពេញការងារ ។ ក្រៅពីភារកិច្ចការពារអ្នកទោសនៅមានការងារជាច្រើនទៀតដែលក្រុមកងការពារត្រូវតែអនុវត្តតាមបញ្ជាដែលបានដាក់ចុះ ។ អ៊ីន បាននិយាយថាចំពោះអ្នកទោសមួយចំនួនដែលចាប់មកពីទីកន្លែងផ្សេងៗគឺកងការពារមន្ទីរ ស-២១ ជាអ្នកទៅចាប់ដោយផ្ទាល់ដៃ ។ ការធ្វើទារុណកម្មទៅលើអ្នកទោសនិងការនាំអ្នកទោសយកទៅសម្លាប់ ក៏ជាតួនាទីមួយផ្នែករបស់កងការពារដែរ ។ ការបែងចែកពេលម៉ោងយាមអ្នកទោសត្រូវបានកំណត់យ៉ាងច្បាស់លាស់ដោយកងការពារចំនួនពីរនាក់ត្រូវយាមអ្នកទោសចំនួនពីរម៉ោង បន្ទាប់មកត្រូវផ្លាស់ប្តូរវេនបន្តបន្ទាប់ទៅទៀត ។ ក្នុងពេលយាមកាម កងការពារពុំមានសិទ្ធិសម្រាកឬអង្គុយមួយកន្លែងឡើយ ។ ក្នុងអំឡុងពេលនោះ ប្រសិនបើមានអ្នកទោសណាម្នាក់លួចរត់ចេញពីមន្ទីរចំវេនកងការពារមួយណា កងការពារនោះនឹងត្រូវទទួលទណ្ឌកម្មពី ឌុច ដោយផ្ទាល់ ។ វឿន ជាកងការពារតែម្នាក់គត់ដែលធ្វេសប្រហែសក្នុងពេលយាមអ្នកទោស ដោយបណ្តោយឲ្យអ្នកទោសបីនាក់រត់រួច ។ វឿន បានទទួលទណ្ឌកម្មពី ឌុច ដោយផ្ទាល់ជាមួយនឹងអ្នកទោសដទៃទៀត ។ ក្នុងចំណោមកងការពារអ្នកទោសទាំងអស់គឺពុំមាននរណាម្នាក់ត្រូវបានចាត់តាំងឲ្យធ្វើប្រធានឡើយ ។ ខន បាននិយាយថា ឌុច ជាអ្នកគ្រប់គ្រងដោយផ្ទាល់លើកងការពារទាំងជាង១០នាក់នោះ ។

រហូតមកដល់បច្ចុប្បន្ននេះ កងការពារមន្ទីរ ស-២១ ដែលនៅមានជីវិតគឺ ចាន់ វឿន រស់នៅភូមិកុមារមាស ឃុំអមលាំង ស្រុកថ្ពង ។ ជន (មិនស្គាល់ត្រកូល) រស់នៅថ្នល់បំបែកអមលាំង ឃុំអមលាំង ស្រុកថ្ពង ។ ណិន (មិនស្គាល់ត្រកូល) រស់នៅភូមិ

ទំនាប ឃុំអមលាំង ស្រុកថ្ពង ។ ចាន់ ខន រស់នៅភូមិទេពភិរម្យ ហៅភូមិក្បាលចិន ឃុំវាលពន់ ស្រុកឧត្តុង្គ ។ អ៊ឹម វន ហៅ ឌិន រស់នៅភូមិស្តុកស្អាត ឃុំមានជ័យ ស្រុកឧត្តុង្គ ។

## ការមិនទុកចិត្តគ្នា

បន្ទាប់ពីមានទឹកជំនន់ជន់លិចទីតាំងមន្ទីរសន្តិសុខទាំងមូល នៅក្នុងចុងឆ្នាំ១៩៧៣ និងបន្ទាប់ពីអ្នកទោសស្ទើរតែទាំងអស់ត្រូវស្លាប់ដោយសារទឹកជំនន់នេះ ហើយនៅពេលប្រជុំម្តងៗ ឌុច ពុំដែលរាយការណ៍ប្រាប់អង្គប្រជុំអំពីបញ្ហានេះ ទើប ឌុច ត្រូវស្ថិតនៅក្នុងការសង្ស័យរបស់បណ្តាកម្មាភិបាលផ្សេងទៀតដែលត្រូវបែងចែកឲ្យទៅនៅមន្ទីរសន្តិសុខនគរបាល ប្រសិទ្ធិត្រ័យត្រិង្គ និងមន្ទីរ-៩៩ ។ អ៊ីន បានរៀបរាប់ពីការសង្ស័យនេះថា កម្មាភិបាលធំៗមួយចំនួនបានជជីកសួរពីបញ្ហាអ្នកទោសស្លាប់នៅមន្ទីរ ម-១៣ នៅពេលមានទឹកជំនន់ និងត្រូវទទួលការស្តីបន្ទោសខ្លះៗដោយសារមិនព្រមរាយការណ៍ទៅថ្នាក់លើពីហេតុការណ៍ដែលបានកើតឡើងនេះ ។ អ៊ីន បាននិយាយថា ស៊ុម ដែលជាប្រធានសន្តិសុខនៅនគរបាល បានសុំឲ្យគាត់ជួយយកការណ៍ទៅប្រាប់ថ្នាក់លើពីករណីដែល ឌុច មិនរាយការណ៍ពីការស្លាប់មនុស្សអស់រាប់សិបនាក់នេះផង ។ នៅដើមឆ្នាំ១៩៧៥ ទំនាស់ផ្ទៃក្នុងរវាងកម្មាភិបាលធំៗនៅក្នុងមន្ទីរបានកើតមានឡើងជាសម្ងាត់ ។ ផល ដែលជាកម្មាភិបាលម្នាក់បន្ទាប់ពី ឌុច ប៉ុន និង ចាន់ ត្រូវកងការពារនាំយកទៅសម្លាប់ ។ រឿងហេតុនេះមានតែ អ៊ីន ម្នាក់គត់ដែលជាអ្នកដឹងច្បាស់ជាងគេ ព្រោះគាត់បានទៅពិនិត្យមើលដោយផ្ទាល់តាមបញ្ជារបស់ ឌុច បន្ទាប់ពីមានការភ្ញាល់គ្នាជាមួយពួកកងការពារ និងអ្នកទោសស្រាលមួយចំនួន ។ អ៊ីន បានរំឭករឿងនេះថា ឌុច បានប្រកាសថានឹងឲ្យកង់មួយដល់នរណាដែលទាយត្រូវពីអ្នកទោសដែលគាត់បានចាប់ចងនោះថាជានរណា ។ ប៉ុន្តែគ្មាននរណានឹកស្មានដល់ថា អ្នកដែលត្រូវចាប់មកនោះជា ផល ទេ ។ ផល ជាកម្មាភិបាលដែលត្រូវចាប់ខ្លួនដោយ ឌុច ។ តាមសម្តីរបស់ ចាន់ ខន អតីតកងការពារនៅមន្ទីរ ម-១៣ ថា ផល បានធ្វើខុសនឹងអង្គការវិន័យនៅក្នុងមន្ទីរពីបញ្ហាខូចសីលធម៌ និងអាងខ្លួនជាអ្នកធំនៅក្នុងមន្ទីរបន្ទាប់ពី ឌុច ។ ចំណែក ចាន់ វឿន ដែលជាអតីតកងការពារនៅមន្ទីរ ម-១៣ ដែរបាននិយាយថា ផល ជាមនុស្សស្លូតបូតជាងគេម្នាក់ក្នុងចំណោមកម្មាភិបាលនៅទីនោះទាំងអស់ ។

## ការសម្លាប់

វិធីសម្លាប់អ្នកទោសនៅមន្ទីរ ម-១៣ មានច្រើនប្រភេទណាស់ ។ អ្នកទោសខ្លះត្រូវសម្លាប់នៅពេលសួរចម្លើយ អ្នកទោសខ្លះត្រូវសម្លាប់ដោយបាញ់នឹងកាំភ្លើង អ្នកខ្លះត្រូវសម្លាប់ដោយកម្មាភិបាលដឹកនាំក្នុងមន្ទីរនៅពេលធ្វើទារុណកម្ម និងអ្នកខ្លះទៀតត្រូវនាំយកទៅសម្លាប់នៅនឹងទីតាំងពិឃាតតែម្តង ។ អ៊ីន បានរៀបរាប់ពីវិធីសម្លាប់មួយប្រភេទទៀតដែលបានប្រព្រឹត្តទៅលើអ្នកទោសរាប់រយនាក់ ដោយសម្លាប់ក្នុងពេលតែមួយ ។ អ៊ីន និយាយដូច្នេះថា «អាសម្លាប់ប្រភេទច្រើនរាប់រយហ្នឹង ជួនកាលពីពីររយឡើងទៅ គឺយកទៅ គេយកម្តងមួយៗទៅដាក់ជាប់នឹងរណ្តៅត្រង់ឈាម រួចយកក្រមារុំកពីរជុំអីចេះ ហើយម្នាក់ទាញចុងជាយម្ខាងៗ ទើបយកកាំបិតអ៊ែរកែងមុខពីរសំលៀងឲ្យស្ពើងដូចស្លាបមាន់ទៅចាក់បំពង់កខ្លះឲ្យបាញ់ឈាមចូលក្នុងរណ្តៅត្រង់ឈាម ។ បន្ទាប់ពីសម្លាប់រួច មានកងការពារពីរនាក់ផ្សេងទៀតជាអ្នកជញ្ជូនយកទៅតម្រៀបដាក់ក្នុងរណ្តៅកប់សាកសពរួមចំនួនបីរណ្តៅដែលមានសណ្ឋានជាមុំចត្រ្កោន» ។ អ៊ីន និយាយទៀតថា នៅត្រង់ណាក៏ឃើញតែក្បាលខ្មោចដែរ ។ ដោយសារតែមានខ្មោចងាប់ច្រើនបែបនេះហើយ ទើបធ្វើឲ្យគាត់លែងខ្លាចខ្មោចតាំងពីពេលនោះរហូតមក ។

តាំងពីថ្ងៃផ្តើមបង្កើតមន្ទីរសន្តិសុខនេះដំបូងរហូតមកទល់និងថ្ងៃត្រូវផ្លាស់ប្តូរទៅនៅទួលស្លែងវិញ អ៊ីន បានរាយការណ៍ពីចំនួនមនុស្សដែលត្រូវសម្លាប់ ស្លាប់ដោយសារជំងឺ និងស្លាប់ដោយសារទឹកជំនន់ជន់លិចកាលពីចុងឆ្នាំ១៩៧៣ នៅក្នុងមន្ទីរ ១៣ ថា មានចំនួនប្រហែលបីម៉ឺននាក់ ។ អ៊ីន បានប្រាប់ពីការយល់ឃើញរបស់គាត់ចំពោះអ្នកទោសដែលស្លាប់អស់ប្រហែលបីម៉ឺននាក់ នៅក្នុងមន្ទីរ ម-១៣ ថាគឺជាការទទួលខុសត្រូវរបស់ ឌុច តែម្នាក់គត់ ព្រោះបញ្ជាទាំងប៉ុន្មានរបស់ ឌុច ត្រូវបានអនុវត្តដោយមិនអាចល្មើសបាន ។ ចាន់ ខន ប្រាប់ថា «បើខ្ញុំមិនធ្វើតាមបញ្ជាទេ គឺត្រូវធ្លាក់មកលើខ្លួនឯងដែលជាអ្នកទទួលបញ្ជាហើយ ជួនកាលត្រូវ ឌុច សម្លាប់ដោយផ្ទាល់ដៃថែមទៀតផង» ។ អ៊ីន

បានឮផ្ទាល់នឹងត្រចៀកអំពីការដាក់បញ្ជារបស់ ឌុច ឲ្យកងការពារមន្ទីរសម្លាប់ខ្មាំងក្នុងមួយថ្ងៃពីរនាក់ជាកំហិត ។ អ៊ីន បាននិយាយពីការលើកឧទាហរណ៍របស់ ឌុច ប្រាប់ទៅក្មេងៗកងការពារថា "ក្នុងមួយថ្ងៃ គេដាំដំឡូងមីបាន១០០គុម្ព ឯងគ្រាន់តែសម្លាប់ខ្មាំងដែលចាប់បានចំនួនពីរនាក់ក៏ពិបាកដែរ" ។ ថ្វីដ្បិតតែនេះជាការព្រមាន ប៉ុន្តែការអនុវត្តផែនការនៅតែសម្រេចបានដដែល ។

នៅខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីថ្ងៃជ័យជម្នះទូទាំងប្រទេសរបស់ខ្មែរក្រហម មន្ទីរសន្តិសុខម-១៣ បានផ្លាស់ប្តូរទីតាំងមកនៅភ្នំពេញវិញ ។ តាមសម្តីរបស់កងការពារឈ្មោះ ចាន់ ខន ថា ទីកន្លែងដែលត្រូវប្តូរមកក្រុងភ្នំពេញនោះគឺទួលស្លែង (មន្ទីរស-២១) ។ ឌុច នៅតែមានតួនាទីជាប្រធានមន្ទីរសន្តិសុខដដែល ។ ឯ ចាន់ និង ប៉ុន ក៏ជាកម្មាភិបាលថ្នាក់លើរបស់មន្ទីរនេះដែរ ។

ការផ្លាស់ប្តូរទីតាំងនេះត្រូវបាន ឌុច ប្រកាសប្រាប់បណ្តាកម្មាភិបាល កងការពារ និងអ្នកទោសថា ត្រូវតែផ្លាស់ប្តូរកន្លែងធ្វើការ ។ ឌុច បាននិយាយទៀតថា គាត់នឹងប្រមូលបណ្តាកម្មាភិបាល និងកងការពារណាដែលមានប្រវត្តិរូបល្អ យកទៅធ្វើការជាមួយនៅភ្នំពេញ ។ ចំណែកអ្នកទោសដែលនៅសេសសល់ពីការសម្លាប់ ត្រូវបានដោះលែងទាំងអស់ ។ ការដោះលែងអ្នកទោសនៅមន្ទីរ ម-១៣ ត្រូវបាន ខន រាយការណ៍ប្រាប់ថា មានគោលការណ៍មួយដែល ឌុច កាន់ក្នុងដៃហើយយកមកប្រកាសជាទូទៅ ។ អ៊ីន ជាអ្នកនិយាយតាមការប្រាប់របស់ ឌុច ថា "ឥឡូវបក្សយើងទទួលបានជ័យជម្នះទាំងស្រុងហើយ ដូច្នេះយើងត្រូវតែទៅរស់នៅឯភ្នំពេញ ដោយផ្លាស់ប្តូរមន្ទីររបស់យើងទៅតាំងនៅភ្នំពេញវិញ" ។ ពាក្យសម្តីមួយឃ្លានេះបានធ្វើឲ្យកម្មាភិបាលទាំងអស់បូករួមទាំងកងការពារផងសប្បាយរីករាយ និងអបអរចំពោះមហាជ័យជម្នះនេះគ្រប់គ្នា ព្រោះ ឌុច បានសន្យាថានឹងប្រមូលកម្មាភិបាល និងកងការពារជំនិតមួយចំនួនឲ្យទៅធ្វើការនៅភ្នំពេញបន្តទៀត ។ ចាន់ ខន បាននិយាយពីការសប្បាយរីករាយ និងការខកចិត្តរបស់គាត់ចំពោះអន្តការថា គាត់សង្ឃឹមខ្លាំងណាស់ថា នឹងបានទៅធ្វើការនៅភ្នំពេញជាមួយ ឌុច ព្រោះគាត់ខិតខំធ្វើការគ្រប់បែបយ៉ាងតាមបញ្ជារបស់ ឌុច ។ ប៉ុន្តែគាត់ប្រែជាត្រូវបញ្ជូនឲ្យទៅនៅកងចល័តជាមួយប្រជាជនឯទៀតនៅក្នុងស្រុកភូមិរបស់គាត់ទៅវិញ បន្ទាប់ពី ឌុច ស៊ើបដឹងថា ខន មានគ្រួសារជាប់ពាក់ពន្ធ័នឹងមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ ។ ខន និយាយដូច្នេះថា "ខិតខំធ្វើការដើម្បីជ័យជម្នះនិងដើម្បីធ្វើការមានមុខមានមាត់ ។ លុះដល់ថ្ងៃជ័យជម្នះហើយ ស្រាប់តែបែជាអស់សង្ឃឹមទៅវិញ" ។ ខន សោកស្តាយនូវអំពើទាំងឡាយដែលខ្លួនបានធ្វើទៅលើអ្នកទោសទាំងឡាយតាមបញ្ជារបស់ ឌុច ដោយរាប់ទាំងការបាញ់សម្លាប់អ្នកទោសជាច្រើនលើកផង ។ ខន និយាយដោយផ្ទាល់មាត់ប្រាប់ថា គាត់ធ្លាប់បានបាញ់សម្លាប់អ្នកទោសតាមបញ្ជារបស់ ឌុច ផ្ទាល់ នៅពេលដែលអ្នកទោសលួចរត់ចេញពីមន្ទីរឃុំឃាំង ។

ចាន់ ប៉ុន និងកងការពារខ្លះទៀតដែលមានប្រវត្តិរូបល្អ ត្រូវបាន ឌុច បញ្ជូនឲ្យមកធ្វើការជាមួយខ្លួននៅឯទួលស្លែង ។ ចំណែកអ្នកទោសមួយចំនួនដែលនៅសេសសល់ពីការសម្លាប់ ត្រូវបានដោះលែងឲ្យវិលត្រឡប់ទៅតាមការដ្ឋាន និងផ្ទះសម្បែងរៀងៗខ្លួនវិញ ហើយមួយចំនួនទៀតត្រូវបញ្ជូនទៅមន្ទីរសន្តិសុខដែលជាសាខារបស់មន្ទីរម-១៣ ។ អ៊ីន និងបក្ខពួកគាត់បីនាក់ទៀត ត្រូវបានបញ្ជូនទៅកាន់មន្ទីរ៩៩ ហើយអ្នកខ្លះទៀតត្រូវបញ្ជូនទៅកាន់ខេត្តពោធិ៍សាត់ ។ ចំណែកមន្ទីរម-១៣ ត្រូវទុកចោលជាមួយនឹងភាពកណ្តោចកណ្តែង ស្ងាត់ជ្រងំ មានតែរណ្តៅធំៗនិងសាកសពមនុស្សរាប់ម៉ឺននាក់ ។

ការកាន់កាប់តំណែងជាប្រធានសន្តិសុខ ស-២១ របស់ ឌុច បានបញ្ចប់នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ កម្មាភិបាលថ្នាក់ដឹកនាំមន្ទីរមួយភាគត្រូវបានសម្លាប់ ហើយមួយភាគទៀតបានរត់ប្រាសអាយុទៅកាន់តំបន់ដាច់ស្រយាលដែលជាអតីតទីជម្រកដ៏សុខសាន្តរបស់ខ្លួន ។ ឌុច ប្រធានមន្ទីរស-២១ បានរត់ទៅកាន់ទឹកដីឃុំអមលាំង ស្រុកថ្ពងម្តងទៀត ដែលនៅទីនោះខ្មែរក្រហមបានប្រមែប្រមូលប្រជាជនចំនួនជាង៨៦០០នាក់យកទៅសម្លាប់ចោលនៅប៉ែកខាងជើងវត្តកន្សែងសម ដោយឆ្លងស្ទឹងក្រាំងពន្លៃ ដែលក្នុងចំណោមនោះមានរាប់បញ្ចូលទាំងយុទ្ធជនខ្មែរក្រហមដែលចាប់យកមកពីប៉ែកភូមិភាគបូព៌ាផង ។ តាមប្រសាសន៍របស់អធិការប៉ូលិសស្រុកថ្ពងបានឲ្យដឹងថា ការ

កៀរជនរងគ្រោះខាងលើមកសម្លាប់គឺ ឌុច ជាអ្នកអនុវត្តផែនការនេះដោយផ្ទាល់ បន្ទាប់ពីគាត់ត្រឡប់ពីភ្នំពេញទៅវិញ ។ នៅក្នុងឯកសារ "សំណុំរឿងរបស់តុលាការកាត់ទោសបនប្រល័យពូជសាសន៍ ប៉ុល ពត-អៀង សារី" ខែសីហា ឆ្នាំ១៩៧៩ បានរៀបរាប់ពីការដឹកជញ្ជូនមនុស្សចំនួន១២០០នាក់ផ្សេងទៀតយកទៅសម្លាប់ចោលនៅទីតាំងខាងជើងវត្តកន្សែងសមដែរគឺក្នុងអំឡុងខែកុម្ភៈ ឆ្នាំ១៩៧៩ ។

### ***ទីតាំងត្រពាំងប្រាបក្នុងចន្លោះឆ្នាំ១៩៧៩រហូតមកដល់បច្ចុប្បន្ន***

ចាប់តាំងពីឆ្នាំ១៩៧៥-១៩៧៩ អតីតមន្ទីរ ម-១៣ប្រត្រពាំងប្រាប គ្មានប្រជាជន ឬខ្មែរក្រហមណាម្នាក់ដើរឆ្លងកាត់ទីនោះឡើយ ព្រោះជាកន្លែងស្ងាត់ជ្រងំនិងសំបូរសត្វព្រៃ ។ ប៉ុន្តែបច្ចុប្បន្ននេះ ផ្នែកខ្លះនៃទីតាំងត្រពាំងប្រាបត្រូវបានប្រជាជនដែលរស់នៅក្នុងភូមិថ្នុកប ឃុំអមលាំង បានរានយកធ្វើជាដីស្រែរបស់ខ្លួន ។ ចំណែកមួយផ្នែកធំទៀតគឺទុកទំនេរចោល ។ ដើមឫស្សីជាច្រើនគុម្ពបានដុះប្រជ្រៀតគ្នានៅលើទីតាំងនៃអតីតមន្ទីរសន្តិសុខ ម-១៣នោះ ។ រណ្តៅជ្រៅៗពីមុន (សព្វថ្ងៃនេះប្រែជារាក់ៗអស់ជម្រៅនៅត្រឹមតែប្រហែលមួយម៉ែត្រឬមួយម៉ែត្រកន្លះប៉ុណ្ណោះ) ។ បន្គោលក្រាក់ដែលពីដើមមានកំពស់៥ទៅ៦ម៉ែត្រនោះ ឥឡូវនៅសល់តែប្រហែលមួយម៉ែត្រដែរ ។ ស្ទឹងដែលហូរកាត់ទីតាំងមន្ទីរសន្តិសុខ ម-១៣ នៅតែជាស្ទឹងទទួលទឹកពីជើងភ្នំឱរ៉ាល់រួចហូរកាត់មកតាមទីតាំងនេះដដែល ។ ត្រពាំងប្រាបដែលជាជម្រកត្រី និងជាកន្លែងដែលផ្តល់សេដ្ឋកិច្ចសំខាន់សម្រាប់មន្ទីរសន្តិសុខ ម-១៣ ក៏ស្ថិតនៅដូចមុនព្រមទាំងបម្រើដល់សេចក្តីត្រូវការរបស់ប្រជាជនក្នុងការធ្វើស្រែចម្ការនិងចិញ្ចឹមសត្វពាហនៈផង ។ មនុស្សច្រើននាក់ណាស់នៅក្នុងទឹកដីស្រុកថ្ពង ខេត្តកំពង់ស្ពឺ ដែលដឹងពីការសម្លាប់មនុស្សនៅក្នុងមន្ទីរសន្តិសុខ ម-១៣ ដែលមាន ឌុច ជាអ្នកគ្រប់គ្រង ។ រហូតមកដល់សព្វថ្ងៃនេះ ការចងចាំរឿងពីអតីតកាល និងភាពសាហាវឃោរឃៅដែលប្រព្រឹត្តដោយថ្នាក់ដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យនៅតែជាស្រមោលអន្ទោលតាមប្រាណមួយសម្រាប់អតីតជនរងគ្រោះទូទៅ ។ ស្រមោលនេះនឹងរលាយបាត់នៅពេលដែលតុលាការជំនុំជម្រះរឿងក្តីខ្មែរក្រហមមួយត្រូវបានបង្កើតឡើងនិងអនុវត្តការងាររបស់ខ្លួនរហូតដល់ចប់ចុងចប់ដើម ។ ហាម អ៊ីន, ចាន់ វឿន, អ៊ុម វន ហៅ ឱន និង ចាន់ ខន បានទាមទារឲ្យមានការកាត់ទោសមេដឹកនាំខ្មែរក្រហមទាំងឡាយដែលនៅរស់ហើយបានសង្កត់ធ្ងន់ទៅលើមេដឹកនាំជាន់ខ្ពស់ម្នាក់ដែលអ្នកស្រុកស្គាល់ច្បាស់ថាជាអ្នកសម្លាប់មនុស្សអស់ជាងបីម៉ឺននាក់នៅក្នុងមន្ទីរ ម-១៣ ក្នុងអំឡុងឆ្នាំ១៩៧២-១៩៧៥ផង ។

**ផេង ពង្សរ៉ាស៊ី**

## ពន្យល់ពាក្យខ្មែរក្រហម

◆ ***ពាក្យថ្នាក់លើរាយការណ៍ទៅថ្នាក់ក្រោមៈ*** គឺជាការរៀនសូត្រការផ្ញើទស្សនាវដ្តី ឯកសារសេចក្តីសម្រេចចាត់តាំងផ្សេងៗ ។

◆ ***អប់រំមនុស្សៈ*** គឺការអប់រំកសាងសង្គមនិយម ។

◆ ***បដិសង្គមនិយមៈ*** គឺវាយកម្មសិទ្ធិកសាងសង្គមនិយម សហករណ៍ គឺចិញ្ចឹមគោឲ្យធាត់ រកដី លើកភ្លឺប្រឡាយ ដោះស្រាយជីវភាពប្រជាជន ដោះស្រាយទឹក បំផុសពីដាំដុះ កសាងប្រជាជនពិបាកគឺប្រវត្តិរូប ។

◆ ***ភារកិច្ចធំៈ*** គឺប្រមូលកម្លាំងទាំងអស់យល់ដល់លើ ការពារបូរណភាព និងអធិបតេយ្យព្រមជាមួយនោះការពារលទ្ធផលនៃធនធានរបស់បដិវត្តន៍ ។

◆ ***ដាច់ខាតៈ*** គឺដាច់ខាតទាំងខាងគណៈនយោបាយ សតិអារម្មណ៍បដិវត្តន៍ ។

**(ដកស្រង់ពីសៀវភៅកំណត់ហេតុ២០៩)**

◆ ***ប្រតិកិរិយាៈ*** ការចម្រើនថយក្រោយហួសសម័យប្រាសជើង ។

◆ ***នាយទុនៈ*** អ្នកមានសម្បត្តិ ស៊ីចាយហួរហៀរមិនចេះខ្វះ ។

◆ ***មូលដ្ឋានៈ*** ជាគ្រឹះដ៏រឹងមាំ ឬជាទម្រដ៏រឹងមាំ ។

◆ ***សមូហភាពៈ*** ការប្រមូលផ្តុំសង្គមមនុស្ស ។

◆ ***សាមគ្គីៈ*** ការរួមកម្លាំងគ្នាពួតផ្តុំវេញត្របាញ់ចូលគ្នាជាធ្លុងមួយ ។

**(ដកស្រង់ពីសៀវភៅកំណត់ហេតុអ៊ីវ)**

(តមកពីទំព័រ១)

រួមជាមួយឯកសាររូបថតនិងឯកសារកិច្ចសម្ភាសន៍ជាមួយសាក្សី របាយការណ៍ដែនទីលើកឡើងនូវភ័ស្តុតាងសំខាន់ៗទាក់ទងនឹងឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយបក្សកុម្មុយនិស្តកម្ពុជា ។ សក្ខីកម្មតាមកោសល្យវិច័យតម្រូវឲ្យមាន ។ កោសល្យវិច័យនេះ បង្ហាញអំពីអាយុនិងរបៀបដែលជនរងគ្រោះត្រូវបានសម្លាប់ ។ តាមរយៈការវិភាគអំពីអាយុកាលឯកសារនិងសម្ភារផ្សេងៗ បន្សល់ទុកនៅតាមគុក រណ្តៅសាកសពរួម កន្លែងធ្វើទារុណកម្ម ជំនាញការកោសល្យវិច័យក៏អាចភ្ជាប់របស់ទាំងនេះទៅនឹងសម័យកម្ពុជាប្រជាធិបតេយ្យផងដែរ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាថ្មីៗនេះ កំពុងតែអនុវត្តគម្រោងកម្មវិធីកោសល្យវិច័យជាមួយអ្នកជំនាញការមួយក្រុម ហើយការងារនេះនឹងត្រូវបញ្ចប់នៅចុងឆ្នាំ២០០៣ ។

និយាយរួមប្រភេទឯកសារដែលរៀបរាប់ខាងដើម អាចដើរតួយ៉ាងសំខាន់ក្នុងការបង្ហាញជាសក្ខីកម្មអំពីឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា ។ នៅក្នុងចំណោមឯកសារខាងលើ ឯកសារដែល“មានតម្លៃភ័ស្តុតាងមិនអាចប្រកែកបាន” ពិតជាមានតិចតួចណាស់ ។ របបប៉ុល ពត ដែលមានលក្ខណៈបិទជិត ក៏ដូចជាភាពស្មុគស្មាញនៃការប្រព្រឹត្តិបទល្មើសតម្រូវឲ្យមានឯកសារលម្អិតយកមកផ្ទឹមគ្នាទើបអាចបង្ហាញភ័ស្តុតាងបានថាមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាពិតជាបានប្រព្រឹត្តបទល្មើសណាមួយជាក់លាក់ ។ តាមរយៈការបង្ហាញអំពីការកើតឡើងនូវអំពើព្រហ្មទណ្ឌ ការដឹងឮ ឬចេតនារបស់មេដឹកនាំណាខ្លះ និងទំនាក់ទំនងនៃការបញ្ជា ឯកសារភ័ស្តុតាងអាចដើរតួនាទីជាកងចង្វាក់តភ្ជាប់គ្នាម្តងមួយៗទើបអាចបង្កើតបានជាការទទួលខុសត្រូវតាមផ្លូវច្បាប់បាន ។

**ឆាំង យុ និង ចន ឆរឆីអារី**



នៅសហករណ៍ភូមិតាឡី ស្រុកដង្កោ ខេត្តកណ្តាល
“ពេលពួកបនសន្តិសុខបោកប្រាសខ្ញុំ (ប៊ូ ម៉េង) ថា ឲ្យទៅបង្រៀនគំនូរសិស្សនៅឯសាលារចនា”

# សកម្មភាពរបស់កងសន្តិសុខនៅមន្ទីរ ស-២១គូរដោយវិចិត្រករ ប៊ូ ម៉េង (អតីតអ្នកទោសនៅមន្ទីរ ស-២១)



*“ពួកវាបផមុខខ្ញុំ និងប្រពន្ធខ្ញុំ ហើយគោកក្បាលដល់ប្រពន្ធខ្ញុំទៀត គឺឈឺដល់ខ្ញុំ”*




*“ពួកវាឃាត់ខ្ញុំ នៅពេលវាបណ្តើរចូលមន្ទីរស-២១ ហៅ គុកទួលស្លែង”*

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ (គុកទួលស្លែង)

រៀបចំនិងចងក្រងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ៧៤០ | ទិត កាន | យុទ្ធជន | ស២១-យ | ២៥-៧-៧៦ | ២៥-៧-៧៦ |
| ៧៤១ | ទូច ទ្រី | យុទ្ធជន | ស២១-យ | ២៥-៧-៧៦ | ២៥-៧-៧៦ |
| ៧៤២ | ស កិ | យុទ្ធជន | ស២១-យ | ២៥-៧-៧៦ | ២៥-៧-៧៦ |
| ៧៤៣ | ឡុង លន | យុទ្ធជន | ស២១-យ | ២៥-៧-៧៦ | ២៥-៧-៧៦ |
| ៧៤៤ | ហ៊ុយ ឡាញ់ | កម្មករ | ស្រែអំបិល | ២២-៧-៧៦ | ២៨-៧-៧៦ |
| ៧៤៥ | ធី ធឿន | កងវរយ | កងពល១៧០ | ?? | ២៩-៧-៧៦ |
| ៧៤៦ | សុក សារិន | កងវរយ | កងពល១៧០ | ?? | ២៩-៧-៧៦ |
| ៧៤៧ | យឹម សម្បត្តិ | កងហ | កងពល១៧០ | ?? | ២៩-៧-៧៦ |
| ៧៤៨ | សោម ថន ហៅ ថាន់ | អនុកងហ | កងពល១៧០ | ?? | ២៩-៧-៧៦ |
| ៧៤៩ | ចក់ យន់ | វរសេនាតូច | កងពល១៧០ | ?? | ២៩-៧-៧៦ |
| ៧៥០ | គឹម ស៊ុត | នីរសា | កងពល១៧០ | ?? | ២៩-៧-៧៦ |
| ៧៥១ | ជាប នី | ប្រធានវរសេនាតូច | កងពល១៧០ | ?? | ២៩-៧-៧៦ |
| ៧៥២ | យី លុយ | ប្រធាននយោបាយ | កងពល១៧០ | ?? | ២៩-៧-៧៦ |
| ៧៥៣ | សូ សឿន | ស្នងការកងវរយ | កងពល១៧០ | ?? | ២៩-៧-៧៦ |
| ៧៥៤ | យ៉ា វណ្ណៈ | អនុក្រុម | កងពល១៧០ | ?? | ២៩-៧-៧៦ |
| ៧៥៥ | អ៊ុក យុននី | អនុក្រុម | កងពល១៧០ | ?? | ២៩-៧-៧៦ |
| ៧៥៦ | មួង សារឿន | យុទ្ធជន | កងពល៥០២ | ?? | ២៩-៧-៧៦ |
| ៧៥៧ | យឹម សារឿន | ប្រធានកងវរយ | ព្រៃវែង | ?? | ២៩-៧-៧៦ |
| ៧៥៨ | សៀង សាន | មេក្រុម | កងពល១៧០ | ?? | ២៩-៧-៧៦ |
| ៧៥៩ | ឯក អាំ | អនុក្រុម | កងពល១៧០ | ?? | ២៩-៧-៧៦ |
| ៧៦០ | ជា ស៊ីម ហៅ កុសល | អនុក្រុម | កងពល១៧០ | ?? | ២៩-៧-៧៦ |
| ៧៦១ | ចក់ អុន ហៅ អឿន | ពេទ្យ | កងពល១៧០ | ?? | ២៩-៧-៧៦ |
| ៧៦២ | គង់ វង់ | មេពួក | កងពល១៧០ | ?? | ២៩-៧-៧៦ |
| ៧៦៣ | ដៀម គាន ហៅ ធឿន | ពេទ្យ | កងពល១៧០ | ?? | ២៩-៧-៧៦ |
| ៧៦៤ | កាំង ណន | យុទ្ធជន | កងពល១៧០ | ?? | ២៩-៧-៧៦ |
| ៧៦៥ | យី សារុន | យុទ្ធជន | កងពល១៧០ | ?? | ២៩-៧-៧៦ |

(នៅមានត)

# អាហាពិពាហ៍នឹងគ្នានៅចុះ

យាយ ដួង គី និង តា គីម គូ រស់នៅភូមិឫស្សីជុំ ឃុំទ្រា ស្រុកសំរោង ខេត្តតាកែវ បានរួមចំណែកចែករំលែករឿងរ៉ាវរបស់គាត់ដែលរស់នៅឆ្លងកាត់ជាច្រើនរបបមកហើយដល់ក្មេងជំនាន់ក្រោយ ។

យាយគី និង តាគូ អាយុ៧២ឆ្នាំដូចគ្នា កើតនៅឆ្នាំវក (ឆ្នាំ១៩៣១) នៅភូមិឫស្សីជុំ ឃុំទ្រា ស្រុកសំរោង ខេត្តតាកែវ ។ យាយគី ជាកូនទោល ឪពុកឈ្មោះ ដួង និងម្តាយឈ្មោះ គីម ។ ពេលដែលយាយមានអាយុ៩ឆ្នាំ ឪពុករបស់យាយបានស្លាប់ដោយជំងឺអាសន្នរោគ ។ បីឆ្នាំក្រោយមកម្តាយរបស់យាយក៏ស្លាប់ដោយរោគម្រេញ ។ បន្ទាប់ពីឪពុកម្តាយស្លាប់ចោលអស់ទៅ យាយរស់នៅជាមួយបងជីដូនមួយប្រកបរបរធ្វើស្រែចម្ការជាប្រក្រតី ។

លោកតា គីម គូ ជាកូនទី៦ក្នុងចំណោមបងប្អូន៧នាក់ ។ ឪពុករបស់តាឈ្មោះ គីម ម្តាយឈ្មោះ សួត៍ ។ យាយគី និង តាគូ ជាបងប្អូនជីទួតមួយ ហើយបានរៀបការនឹងគ្នានៅឆ្នាំខាល (ឆ្នាំ ១៩៥០) តាមការរៀបចំទុកដាក់របស់ចាស់ទុំទាំងសងខាង ។ យាយនិងតាមានកូនទាំងអស់ ៩នាក់ ស្រី២នាក់ ប្រុស៧នាក់ ។ កូនស្រីច្បងស្លាប់នៅអាយុ៦ឆ្នាំ ដោយសារជំងឺគ្រុនស្រឹល ។ កាលពីមុនផ្ទះរបស់យាយតានិងប្រជាជននៅក្នុងភូមិឫស្សីជុំស្ថិតនៅឆ្ងាយពីផ្លូវថ្នល់ ។ នៅឆ្នាំរោង (ប្រហែលឆ្នាំ១៩៥២) រដ្ឋអំណាចបានបង្គាប់បញ្ជាឲ្យប្រជាជនលើកផ្ទះសម្បែងមករស់នៅតាមបណ្តោយផ្លូវថ្នល់ដើម្បីឲ្យមានភាពអ៊ូអរ ។

នៅខែមីនា ឆ្នាំ១៩៧០ ខ្មែរក្រហមបានគ្រប់គ្រងឃុំទ្រា ។ កូនទី៨ របស់យាយដែលមានអាយុ៦ឆ្នាំ បានស្លាប់ដោយជំងឺ



ប៉ែស្ត នៅឆ្នាំ១៩៧០ ។ ឆ្នាំ១៩៧១ កូនប្រុសទីមួយរបស់យាយគាបានចូលបម្រើក្នុងជួរកងទ័ពបដិវត្តន៍ ។ នៅឆ្នាំ១៩៧៣ កូនទី៣ ក៏ចូលក្នុងជួរបដិវត្តន៍ទៀត ។ យាយគាមិនចង់ឲ្យកូនទៅឆ្ងាយអំពីខ្លួនទេ ប៉ុន្តែនេះជាតម្រូវការរបស់បដិវត្តន៍ ។

ចាប់ពីឆ្នាំ១៩៧៣ ភូមិឫស្សីជុំបានទទួលរងការគំរាមកំហែង ដោយការទម្លាក់គ្រាប់បែកពីយន្តហោះរបស់ទាហានលន់ ណុល ។ ក្រុមគ្រួសាររបស់ យាយគី និង តាគូ ព្រមទាំងប្រជាជនក្នុងឃុំទាំងមូលត្រូវរត់ចោលផ្ទះសម្បែងជាញឹកញាប់ ជួនកាលត្រូវលាក់ខ្លួនក្នុងលេណដ្ឋានជាច្រើនថ្ងៃ ដាច់បាយក្រហាយទឹក ហើយពេលខ្លះទៀតត្រូវខ្មែរក្រហមកៀរឡើងទៅតំបន់ភ្នំមួយរយៈទើបចុះមកវិញ ។ ប្រជាជនជួបវិបត្តិអត់ឃ្លានដោយសារខកខានធ្វើស្រែចម្ការ ព្រោះរវល់តែរត់គេចខ្លួន ។ ពេលនោះយាយទើបនឹងប្រសូត្រកូនទី៩ ត្រូវធ្វើដំណើរភៀសខ្លួនទាំងសរសៃខ្ចី ពេលខ្លះត្រូវដេកក្នុងលេណដ្ឋានជាច្រើនថ្ងៃ បណ្តាលឲ្យស្ពឹកជើងមួយចំហៀងរហូតដល់បច្ចុប្បន្ន ។

បន្ទាប់ពីចូលបដិវត្តន៍បានបី-បួនខែ កូនទី៣បានមកលេងផ្ទះម្តង ហើយក៏បាត់ដំណឹងកូនទាំងពីររហូត ។

នៅក្នុងរបបខ្មែរក្រហម យាយត្រូវអង្គការចាត់តាំងឲ្យប្រូតស្រូវ បន្ទាប់មកក៏ត្រូវចាត់តាំងឲ្យធ្វើចុងភៅប្រចាំសហករណ៍ភូមិឫស្សីជុំ ។ ចំណែកតាត្រូវអង្គការចាត់តាំងឲ្យបររទេះដឹកស្រូវ ជួនកាលទៅឃ្វាលគោ ស្ទូងស្រូវ ប្រូតកាត់ វែកដី ដឹកប្រឡាយ លើកទំនប់ ឬធ្វើចុងភៅតាមតែកន្លែងនីមួយៗត្រូវការកម្លាំង ។ ចំណែកកូនៗទាំងអស់ត្រូវបំបែកទៅកងចល័តតាមភេទនិងអាយុ នៅសល់តែកូនពៅដែលទើបតែមានអាយុជាង២ឆ្នាំត្រូវទុកនៅមណ្ឌលកុមារ ។ យាយ ដួង គី បានឲ្យដឹងថា អង្គការគ្រប់គ្រងនៅក្នុងភូមិឫស្សីជុំមានសភាពតឹងតែងជាងភូមិដទៃទៀត ។ នៅភូមិជិតខាង ប្រជាជនមូលដ្ឋានអាចទៅសួរសុខទុក្ខឬទទួលរាក់ទាក់សាច់ញាតិដែលទើបជម្លៀសមកពីភ្នំពេញ ដោយឡែកប្រជាជននៅក្នុងភូមិឫស្សីជុំមិនបានទទួលការអនុញ្ញាតឲ្យធ្វើដូច្នេះឡើយ ។ យាយ ដួង គី និយាយថា "ភូមិគេផ្សេងគេធ្វើនំនែកទៅទទួលបងប្អូនគេបាន ចំណែកភូមិខ្ញុំនេះអត់ទេ អង្គការថាក្បាលអ្នកណាសក់អ្នកហ្នឹង មិនឲ្យទៅរវល់ជាមួយបងប្អូនមកពីភ្នំពេញទេ" ។

យាយ ដួង គី រៀបរាប់ទៀតថា អំឡុងពេលដែលគាត់ចាប់ផ្តើមធ្វើចុងភៅដំបូង ប្រជាជនបានទទួលរបបអាហារ៣ពេលក្នុងមួយថ្ងៃ ។ ដូច្នេះ ក្រុមចុងភៅដែលមានសមាជិក៧នាក់ ត្រូវធ្វើការយ៉ាងហត់នឿយក្នុងការចម្អិនបាយម្ហូបឲ្យប្រជាជនទូទាំងសហករណ៍ ។ នៅក្នុងសហករណ៍ ភូមិឫស្សីជុំមានរោងបាយពីរ រោងបាយមួយសម្រាប់បុរស រោងបាយមួយទៀតសម្រាប់ស្ត្រីនិងកុមារ ។ ប្រជាជន១៧មេសា និង ប្រជាជនមូលដ្ឋានរស់នៅជាមួយគ្នា និងបានទទួលរបបអាហារដូចៗគ្នា ។ ដើមឆ្នាំ១៩៧៥ របបអាហាររបស់ប្រជាជនគឺម្នាក់បានទទួលបាយមួយចានតូច និងសម្លមួយចានសម្រាប់មនុស្ស៤នាក់ ។ ចាប់ពីឆ្នាំ១៩៧៦ របបអាហាររបស់ប្រជាជនត្រូវបានកាត់បន្ថយពីបាយទៅបបរខាប់ ហើយនៅទីបំផុតគឺបបររាវ ។ តា គឹម គូ បានប្រាប់ថា រស់នៅជាង៣ឆ្នាំនៅក្នុងរបបខ្មែរក្រហម គាត់បានទទួលរបបអាហារពិសេសតែម្តងគត់ គឺមាន់ស្ងោរមួយសម្រាប់មនុស្ស៤នាក់ ។ ក្រៅពីនោះគឺបានទទួលតែបបររាវកក្លុក ពេលដែលសម្រិតទឹកចេញនៅសល់កាកបបរតែមួយវែកប៉ុណ្ណោះ ។ វែកដែល តាគូ ប្រើសម្រាប់វាល់បបរកាលពីពេលនោះ តារក្សាវាទុករហូតដល់សព្វថ្ងៃ គឺជាវែកដែលផលិតក្នុងស្រុក ។ យាយបន្ថែមថា ប្រជាជនដែលជម្លៀសមកពីភ្នំពេញហើយហូបមិនឆ្អែត បានរកចាប់កូនត្រី ក្តាម ខ្យង សត្វល្អិតគ្រប់ប្រភេទ បេះត្រកៀត ព្រលឹត ប្រាច់ ស្លឹកឈើព្រៃយកមកធ្វើជាអាហារ ។ អ្នកខ្លះស្គាល់ស្លឹកឈើមិនច្បាស់ បេះចំស្លឹកឈើដែលមានជាតិពុលយកមកបរិភោគ បណ្តាលឲ្យពុលស្លាប់ទាំងក្រុមគ្រួសារ ។

ធ្វើចុងភៅបានរយៈពេល១១ខែ យាយគី សុំផ្លាស់មកធ្វើការនៅក្នុងកងចិញ្ចឹមសត្វ ។ កងចិញ្ចឹមសត្វទទួលខុសត្រូវចិញ្ចឹមសត្វរាប់រយក្បាល មានមាន់ ទា ជ្រូក និងទន្សាយ ។ ជួនកាលយាយត្រូវដើរវែងកន្ទក់នៅតាមរោងម៉ាស៊ីនកិនស្រូវនៅស្រុកឆ្ងាយៗ ដូចជាអង្គរបុរី និង កោះញ៉ែ ដើម្បីបានកន្ទក់យកមកឲ្យជ្រូកស៊ី ។ ដោយសេចក្តីអត់ឃ្លានខ្លាំងពេក ក្រុមរបស់យាយបានលួចចំហុយកន្ទក់ហូប អ្នកខ្លះទៀតលួចហូបបាយជ្រូក ។ យាយគាប្រាប់ថា បើនរណាម្នាក់ត្រូវឈ្លបឃើញពេលកំពុងលួចហូបឬលួចបេះដំណាំសមូហភាព អ្នកនោះនឹងត្រូវចាប់ខ្លួនបញ្ជូនទៅ

ភូមិណាំកី ។ ភូមិណាំកីស្ថិតនៅក្នុងឃុំទ្រាដែរ គឺជាកន្លែងដាក់អ្នកទោសស្រាលៗ ដូចជាទោសលួចជាដើម ។ នៅទីនោះអ្នកទោសត្រូវធ្វើការធ្ងន់ធ្ងរជាងប្រជាជននៅក្នុងសហករណ៍ និងកាត់បន្ថយរបបអាហារពាក់កណ្តាល ។ អ្នកណាដែលជាប់នៅភូមិណាំកីរយៈពេលខ្លីអាចមានជីវិតរស់នៅ ផ្ទុយទៅវិញអ្នកណាជាប់នៅទីនោះរយៈពេលយូរគឺត្រូវស្លាប់ដោយអត់ឃ្លាននិងបាក់កម្លាំង ។ អ្នកទោសធ្ងន់ត្រូវបញ្ជូនទៅគុកស្រះក្រាំងបន្ទាយ នៅក្នុងឃុំបឹងត្រាញ់ ស្រុកសំរោង ។ អ្នកដែលត្រូវបញ្ជូនទៅគុកស្រះក្រាំងបន្ទាយគ្មានសង្ឃឹមថាមានសំណាងបានរស់រានមានជីវិតឡើយ ។

នៅក្នុងសហករណ៍ដែលយាយតារស់នៅ ប្រជាជនត្រូវបង្ខំឲ្យធ្វើការងារជាង១០ម៉ោងក្នុងមួយថ្ងៃ មិនថាថ្ងៃសៅរ៍ឬថ្ងៃអាទិត្យឡើយ ។ ក្នុងមួយខែមានថ្ងៃសម្រាកពីរថ្ងៃ គឺថ្ងៃទី១០ និងថ្ងៃទី២០ ប៉ុន្តែប្រជាជនមិនបានឈប់សម្រាកនៅផ្ទះទេគឺត្រូវទៅចូលរួមមិទ្ទីងស្តាប់អង្គការមានមតិណែនាំ ។ នៅក្នុងអង្គប្រជុំម្តងៗ គណៈឃុំ គណៈភូមិ គណៈសហករណ៍ ឡើងមានយោបល់បន្តគ្នាពីម្នាក់ទៅម្នាក់ ចំណែកប្រជាជនមិនត្រូវបានអនុញ្ញាតឲ្យបញ្ចេញយោបល់អ្វីទាំងអស់ គឺបានត្រឹមតែអង្គុយស្តាប់ដោយស្ងៀមស្ងាត់ និងទះដៃតែប៉ុណ្ណោះ ។

កូនៗរបស់យាយតាដែលទៅធ្វើការនៅតាមកងចល័តយូរៗឃើញមកលេងផ្ទះម្តង ។ មកម្តងៗនៅផ្ទះបានមួយឬពីរម៉ោង ជួនកាលនៅបានមួយយប់ ក៏ប្រញាប់ប្រញាល់ត្រឡប់ទៅវិញ ។ យាយនិងតានិយាយថា មើលទៅរូបរាងរបស់កូនៗគួរឲ្យសង្វេគណាស់ ម្នាក់ៗស្គមស្គាំងមានតែស្បែកដណ្តប់ឆ្អឹង ទឹកមុខស្លេកស្លាំងពោរពេញទៅដោយការហេវហត់ ។

យាយគី និយាយថានៅក្នុងរបបខ្មែរក្រហម អ្វីៗទាំងអស់សុទ្ធតែត្រូវសន្សំសំចៃ សូម្បីតែលាមកមនុស្សនិងសត្វក៏ត្រូវសន្សំដែរដើម្បីយកទៅធ្វើជី ។ ថ្ងៃមួយ យាយត្រូវប្រធានកងចិញ្ចឹមសត្វទិតៀនពីបទបន្ទោរបង់ក្រោបគ្គន់ ។ ប្រធានកងទិតៀនថាយាយមិនជួយសន្សំសំចៃជីឲ្យប្រទេសជាតិ ។

នៅដើមឆ្នាំ១៩៧៩ ពេលដែលកងទ័ពវៀតណាមចាប់ផ្តើមវាយលុកចូលប្រទេសកម្ពុជាខ្មែរក្រហមបានកៀរប្រជាជននៅក្នុងឃុំទ្រា ឡើងទៅតំបន់លើ ។ យាយនិងតាក៏ចេះតែទៅតាមគេ លុះដល់ទាហានខ្មែរក្រហមទៅអស់ក៏ត្រឡប់ក្រោយមករស់នៅក្នុងស្រុកកំណើតវិញ ។ បន្ទាប់ពីវិលត្រឡប់មករស់នៅស្រុកកំណើតបានមួយរយៈខ្លី ទើបឃើញកូនៗរបស់យាយតាវិលត្រឡប់មករកឪពុកម្តាយជាបន្តបន្ទាប់ បាត់តែកូនប្រុស២នាក់ដែលចូលបម្រើកងទ័ពខ្មែរក្រហមមិនឃើញវិលត្រឡប់មកវិញ ។ យាយនិងតាព្យាយាមស៊ើបសួររកដែរ ប៉ុន្តែបានទទួលដំណឹងត្រឹមថា កូនទីពពិការ ភ្នែកម្ខាងនិងរត់ឡើងលើភ្នំ ចំណែកកូនច្បងត្រូវអង្គការចាប់ខ្លួន ។

បច្ចុប្បន្ន យាយគី និង តាគូ នៅសល់កូន៥នាក់ និងបានរៀបចំទុកដាក់ឲ្យមានគូស្រករទាំងអស់ ។ យាយតានិងកូនៗនៅតែប្រកបរបរធ្វើស្រែចំការដូចពីមុន ប៉ុន្តែយាយប្រាប់ថា កូនៗរបស់យាយមានជីវភាពមិនសូវគ្រប់គ្រាន់ទេ ព្រោះដីស្រែតូចហើយកូនចៅកើតកាន់តែច្រើន ម៉្លោះហើយត្រូវដើរស៊ីឈ្នួលពលកម្មរកប្រាក់កម្រៃមកបង្គ្រប់ជីវភាពគ្រួសារ ។

អស់រយៈពេលជាងម្ភៃឆ្នាំហើយដែលយាយ ដួង គី និង តា គីម គូ ទន្ទឹងមើលផ្លូវកូនប្រុសទាំងពីររបស់គាត់ ។ ពេលនេះគាត់អស់សង្ឃឹមនឹងរង់ចាំទៀតហើយ ។ យាយតាគិតថាកូនរបស់គាត់ប្រហែលជាស្លាប់ហើយ បើនៅរស់ម៉្លេះពេលនេះវិលត្រឡប់មករកឪពុកម្តាយនៅភូមិកំណើតវិញ មិនមែនបាត់ដំណឹងសូន្យឈឹងបែបនេះទេ ។ យាយតាខ្វល់ខ្វាយនឹកកូន សោកស្តាយកូនខ្លាំងណាស់ ប៉ុន្តែមិនដឹងធ្វើយ៉ាងម៉េច បើទោះជាខឹងអ្នកដែលយកកូនរបស់គាត់ទៅធ្វើបដិវត្តន៍ ក៏អ្នកទាំងអស់នោះបានស្លាប់អស់ទៅហើយ ដូច្នេះមានតែអហោសិកម្មនឹងគ្នាទៅចុះ ។

**សាន់ កល្យាណ**

## ពាក្យស្លោកខ្មែរក្រហម

- **បើចង់ដើរឱ្យលឿនតាមផ្លូវកុំទៅជាមួយសត្វបង្គួយ។**
- **អង្កាមទុកជាពណ៌ស្រស់យ៉ាងណាក៏ដោយ គេមិនអាចយកទៅធ្វើជាម្សៅបានឡើយ។**

*(ដកស្រង់ពីសៀវភៅញុក)*

# សុខចិត្តធ្វើការលំបាកគ្រប់យ៉ាងជាជាងព្រាត់ប្រាសកូនចៅ

ក្រោយពីថ្ងៃរដ្ឋប្រហារទម្លាក់សម្តេច នរោត្តម សីហនុ នៅឆ្នាំ១៩៧០ ប្រជាជននៅស្រុកកោះធំ ចាប់ផ្តើមលេចឮពាក្យឃោសនាអប់រំបំពាក់បំប៉ នមនោគមវិជ្ជា បំផុសចលនាប្រជាជនឲ្យមានកំហឹងវណ្ណៈប្រឆាំងនិងរបប លន់ ណុល ដើម្បីរំដោះជាតិឡើងវិញភ្លាម ។ កាលនោះមានយុវជនយុវនារីមួយចំនួនតូចប៉ុណ្ណោះ បានស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍ដើម្បីរំដោះជាតិតាមការឃោសនារបស់ជនមួយចំនួននិងតាមរយៈមេភូមិ ។ ប៉ុន្តែនៅឆ្នាំ១៩៧៣រហូតដល់ឆ្នាំ១៩៧៥ ប្រជាជននៅស្រុកកោះធំស្ទើរតែទាំងអស់បាននិយាយថា យុវជន យុវនារី ដែលមានអាយុពី១៤ទៅ១៨ឆ្នាំត្រូវបានមេភូមិបង្ខំឲ្យចូលបម្រើបដិវត្តន៍ដោយគ្មាននរណាអាចគេចសម្ងំនៅផ្ទះបានទេ ។

ដូចជាករណីឈ្មោះ អ៊ុល ខេង ដែលត្រូវជាកូនរបស់លោកយាយ លាន ស្រិន ។ លោកយាយ ស្រិន មានអាយុ៨២ឆ្នាំ រស់នៅភូមិថ្មី ឃុំពោធិ៍បាន ស្រុកកោះធំ ខេត្តកណ្តាល ប្តីរបស់គាត់ឈ្មោះ កុង ប៉ែត មានអាយុ៩០ឆ្នាំ បច្ចុប្បន្នស្លាប់ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ភូមិនេះត្រូវបានដាក់ឈ្មោះមួយទៀតថា“ភូមិលេខ៤” ។ លោកយាយ ស្រិន បានរៀបរាប់ថា គាត់មានកូនទាំងអស់១១នាក់ ស្លាប់៣នាក់ បាត់ខ្លួនម្នាក់ឈ្មោះ ខេង ។ លោកយាយ ស្រិន បាននិយាយថា ខេង មានលក្ខណៈសម្បត្តិល្អណាស់ ចេះដឹងខុសត្រូវ ចេះគោរពឪពុកម្តាយ ពេលទៅចម្ការនិងត្រឡប់មកពីចម្ការម្តងៗ ប្រសិនបើមិនឃើញម្តាយនៅផ្ទះទេ ខេង ស្រែករកម្តាយផ្អើលគេផ្អើលឯងអស់ហើយ ។ លោកយាយ ស្រិន បន្តថា “កូនខ្ញុំ ខ្ញុំស្រឡាញ់ទាំងអស់ តែមួយហ្នឹងវាពិសេសជាងគេ ព្រោះមិនដែលធ្វើអ្វីឲ្យខ្ញុំខុសចិត្តឡើយ ។ ប៉ុន្តែជាវាសនាអាក្រក់សម្រាប់កូនខ្ញុំពេលធំពេញវ័យចំពេលស្រុកមានសង្គ្រាមបានធ្វើឲ្យខ្ញុំ និងកូនជាទីស្រឡាញ់បែកចេញពីក្រុមគ្រួសារទៅយ៉ាងនេះ” ។ ខេង បានចូលបដិវត្តន៍តាមការបង្ខិតបង្ខំពីសំណាក់មេភូមិ ។ លោកយាយ ស្រិន និយាយថា “ទោះបីខ្ញុំខំយកកូនទៅលាក់បំពួនយ៉ាងណាក៏ដោយ ក៏មេភូមិនៅតែរកឃើញ ហើយចាប់កូនខ្ញុំយកទៅ ។ ពេលនោះខ្ញុំស្រែកយំអង្វរយ៉ាងណា ក៏មេភូមិមិនស្តាប់ការអង្វររបស់ខ្ញុំដែរ ។ ខ្ញុំស្រណោះកូនណាស់ មុនចេញទៅវាមកថ្វាយបង្គំខ្ញុំបីដង ហើយស្រែកឲ្យម៉ែជួយកូនផង ។ តែម៉ែគ្មានអំណាចអ្វីនឹងជួយកូនបានទេ បានត្រឹមតែឈរយំតាមកូនប៉ុណ្ណោះ” ។



លោកយាយ លាន ស្រិន

ខេង ត្រូវពួកខ្មែរក្រហមបញ្ជូនឲ្យទៅនៅភូមិលេខ៣ កន្ទះខែ ទើបអង្គការបញ្ជូនឡើងមកព្រែកប៉ិ ស្នាក់នៅទីនោះជាបណ្តោះអាសន្ន ។ ដោយក្តីនឹករឭកឪពុកម្តាយខ្លាំងពេក ខេង បានហែលទឹកឆ្លងទន្លេបាសាក់មកលេងផ្ទះ គឺនៅពេលដែលអង្គការអនុញ្ញាតឲ្យងូតទឹក ។ ពេលបានជួបម្តាយ ខេង បាននិយាយថា “ម៉ែអើយកូនមិនចង់ទៅវិញទេ កូនចង់នៅជួបឪពុកម្តាយបងប្អូនណាមួយកូនខ្លាចគ្រាប់រំសេវផង” ។ ខេង សន្ទនាជាមួយម្តាយបានមួយភ្លែត ក៏ត្រឡប់ទៅអង្គភាពវិញទាំងក្តីអាល័យ ។ ក្រោយមក ខេង ត្រូវបានអង្គការខ្មែរក្រហមបញ្ជូនទៅវត្តកោះខែលនិងកោះឧញ្ញាប់ជន្លាដើម្បីហាត់ក្បួនយោធានៅទីនោះ ។ ខេង ក៏ធ្លាប់លួចរត់មកលេងផ្ទះបងនៅភូមិតាលន់ម្តងដែរ ។ លោកយាយនិយាយថា “កូនខ្ញុំនៅភូមិតាលន់ត្រូវជាបង

របស់ ខេង ដែលដឹងថាខេងនៅកោះខ្សាច់ជន្លា ក៏មកប្រាប់ខ្ញុំ ខ្ញុំក៏ប្រញាប់ប្រញាល់ជិះកង់ទៅរកជួបកូន ពេលដែលទៅដល់ខ្មែរ-ក្រហមមិនអនុញ្ញាតឲ្យចូលទេ ។ លុះដល់ខ្ញុំអង្វរខ្លាំងពេក ទើបអនុញ្ញាតឲ្យជួបមួយភ្លែតមិនបាននិយាយអ៊ីវែងឆ្ងាយទេ» ។ ចាប់តាំងពីពេលនោះមក ខេង បាត់ដំណឹងរហូតដល់សព្វថ្ងៃនេះ ។

រាល់ថ្ងៃនេះលោកយាយនៅតែរង់ចាំមើលផ្លូវកូនជានិច្ច ឲ្យតែឃើញមនុស្សដើរកាត់មុខផ្ទះគាត់ដែលមានវ័យជាង៤០ឆ្នាំ គាត់បេះតែមានអារម្មណ៍ថា កូនគាត់បើនៅរស់ប្រហែលស្រករហ្នឹងដែរ ។ លោកយាយមានការសោកស្តាយយ៉ាងខ្លាំង ព្រោះថាកូនដែលគាត់ខំបង្កើតខំចិញ្ចឹមបានធំធាត់បែរជាខ្មែរក្រហមយកទៅបាត់មិនដឹងជាស្លាប់ឬរស់ គ្មាននរណាយកចិត្តទុកដាក់បន្តិចសោះឡើយ ។

លោកយាយ ឆាំង យន មានអាយុ៧៨ឆ្នាំ និងលោកតា សឿង អ៊ុន(ស្លាប់) រស់នៅភូមិពោធិ៍រាមា ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល ។ លោកយាយប្រកបរបរដាំដំណាំនៅក្បែរផ្ទះបន្តិចបន្តួចដូចជាប៉េងប៉ោះ ដើម្បីប្តូរយកអង្ករនិងម្ហូបចិញ្ចឹមចៅៗ៤នាក់ដែលនៅក្នុងបន្ទុក (ម្តាយស្លាប់ដោយ-សាររន្ទះបាញ់) ។ លោកយាយមានកូនទាំងអស់៧នាក់ បច្ចុប្បន្ននៅរស់៤នាក់ ស្លាប់ម្នាក់ពីរនាក់បាត់ខ្លួន(ម្នាក់ឈ្មោះ សឿង យី) ។


លោកយាយ ឆាំង យន ជាមួយចៅ

សឿង យី បានចូលធ្វើជាយុទ្ធនារីបដិវត្តន៍នៅឆ្នាំ១៩៧៣ ក្រោមការបង្ខិតបង្ខំរបស់មេភូមិ ដែលកាលនោះ យី មានអាយុទើបតែ១៦ឆ្នាំ ។ តាមសម្តីរបស់លោកយាយបានឲ្យដឹងថា យី មិនចង់ចូលបម្រើបដិវត្តន៍ទេ ចង់នៅជួយធ្វើស្រែចម្ការឪពុកម្តាយ ប៉ុន្តែដោយសារស្រុកមានសង្គ្រាម មេភូមិបង្ខំមិនអាចសម្ងំនៅផ្ទះបាន ទើបចូលបដិវត្តន៍ទាំងបង្ខំចិត្ត ។ ចំណែកលោកយាយបានត្រឹមតែឈរសម្លឹងមើលកូនដែលមេភូមិចាប់ទៅប៉ុណ្ណោះ ។

ថ្ងៃមួយ យី បានលួចរត់មកផ្ទះ ហើយបានប្រាប់ម្តាយថានៅក្នុងកងនារីខ្លួនត្រូវបានអង្គការចាត់តាំងឲ្យវែកបាយស្លុកទៅសមរភូមិមុខ ។ ដោយក្តីស្រឡាញ់និងអាណិតកូនពេក លោកយាយបានប្រើមធ្យោបាយមួយដើម្បីកុំឲ្យប្រធានភូមិចាប់យកកូនគាត់វិញ លោកយាយបានឲ្យកូនគាត់ផឹកថ្នាំបញ្ចុះរហូតដល់ធ្លាក់ខ្លួនឈឺជាទម្ងន់ ។ យី ចាប់ផ្តើមស្គមនិងជ្រុះសក់ ។ ប៉ុន្តែមធ្យោបាយបែបនេះមិនទទួលបានលទ្ធផលទេ បានត្រឹមតែធ្វើឲ្យកូនឈឺឥតប្រយោជន៍ ព្រោះថាមួយរយៈក្រោយពី យី ធូរស្រាលឡើងវិញ ប្រធានកងនារីបានមកហៅឲ្យត្រឡប់ចូលអង្គភាពដដែល ។ ចាប់ពីនោះមក យី មិនដែលឃើញលួចរត់មកផ្ទះជាលើកទីពីរទៀតឡើយ ។ លោកយាយបេះទន្ទឹងរង់ចាំផ្លូវ យី ត្រឡប់មកផ្ទះវិញដូចកូនអ្នកភូមិផ្សេងទៀតដែរ ។ ប៉ុន្តែសេចក្តីសង្ឃឹមរបស់យាយស្ទើរតែរលាយអស់ពីខ្លួនទៅហើយ ។ លោកយាយមានប្រសាសន៍ថា «មានអារម្មណ៍នឹកកូន អាល័យកូន ជួនកាលយំទាំងយប់ទាំងថ្ងៃ ហាក់បីដូចជាមនុស្សវិកលចរិត ព្រោះឃើញកូនអ្នកស្រុកខ្លះបានមករកឪពុកម្តាយគេវិញ ។ ចំណែកកូនខ្ញុំមិនឃើញមិនដឹងស្លាប់ឬរស់? មិនដឹងថាស្លាប់របៀបណា? ក្នុងព្រៃក៏មិនដឹង អាណិតកូនត្រង់ហ្នឹង ។ ខ្ញុំសុខចិត្តធ្វើការលំបាកគ្រប់បែបយ៉ាង ជាជាងព្រាត់ប្រាសកូនចៅជាទីស្រឡាញ់របស់ខ្លួន សុខចិត្តស្លាប់រស់ជាមួយគ្នា» ។

លោកយាយគឺជាអ្នកកាន់ធម៌អាជ៌ម្នាក់ ក៏ប៉ុន្តែលោកយាយចង់ឃើញសង្គមមានភាពយុត្តិធម៌សម្រាប់ប្រជាជនរាប់លាននាក់ដែលស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរ ។ លោកយាយចង់ឲ្យតុលាការកាត់ទោសមេដឹកនាំធំៗក្នុងសម័យខ្មែរក្រហមទើបជាការត្រឹមត្រូវ ព្រោះអ្នកទាំងនោះជាអ្នកទទួលខុសត្រូវក្នុងរយៈពេលដែលខ្លួនកាន់អំណាច ។

**សុខ ខណ្ណៈ**



# ជម្លោះរវាងចិន និង កម្ពុជាក្នុងអំឡុង




**(តចប់)** កិច្ចសហប្រតិបត្តិការនេះនឹងឈានដល់កម្រិតកំពូលនៅអំឡុងពេលសង្គ្រាមចិន-វៀតណាម ឆ្នាំ១៩៧៩ នៅពេលដែលមន្ត្រីសហរដ្ឋអាមេរិកជួបជាមួយឯកអគ្គរដ្ឋទូតចិននៅទីក្រុងវ៉ាស៊ីនតោន ស្ទើរតែរៀងរាល់ថ្ងៃ ពេញអំឡុងពេលមានជម្លោះយោធា ដើម្បីបង្វែរពីការស៊ើបការណ៍របស់អាមេរិកទៅជាការវាយទ័ពរបស់សូវៀតវិញ ។

ទោះបីជាក្រុងប៉េកាំងនិងវ៉ាស៊ីនតោនមានគោលដៅរួមគ្នាក្នុងការមិនឲ្យសូវៀតពាក់ព័ន្ធនឹងបញ្ហាកម្ពុជាយ៉ាងណាក៏ដោយ ក៏ភាគីទាំងពីរមិនយល់ស្របលើការចាត់ចែងរៀបចំខាងនយោបាយនៅប្រទេសនោះដែរ ។ ក្រុងប៉េកាំងនិងវ៉ាស៊ីនតោនសម្លឹងមើលក្រុមកម្ពុជាផ្សេងៗគ្នា ដើម្បីជំរុញឲ្យមានផលប្រយោជន៍របស់ខ្លួននៅទីនោះ ។ ក្រុងប៉េកាំងមើលឃើញថា សម្តេច សីហនុ គឺជាអ្នកការពារឯករាជ្យភាពរបស់ប្រទេសបានយ៉ាងល្អ ចំណែកឯក្រុងវ៉ាស៊ីនតោនចាត់ទុកក្រុម លន់ ណុល ជាសម្ព័ន្ធមិត្តដ៏ប្រពៃសម្រាប់ការពារផលប្រយោជន៍របស់អាមេរិកាំង ។ ភាគីទាំងពីរសុទ្ធតែមិនអាចបញ្ចុះបញ្ចូលគ្នាឲ្យទទួលយកនូវជម្រើសរបស់ផងខ្លួននៅកម្ពុជា ។

ជូ អេន ឡាយ ពិតជាបានបញ្ចប់កិច្ចសន្ទនាដែលពោរពេញទៅដោយជំនឿចិត្តជាមួយ ឃីសស៊ីងជឺ ។ តាមរយៈ ឃីសស៊ីងជឺ, ជូ អេន ឡាយ ដឹងថា សហរដ្ឋអាមេរិកបានសម្រេចចិត្តទប់ទល់នឹងការពង្រីកឥទ្ធិពលរបស់សូវៀតនៅអាស៊ី-អាគ្នេយ៍ ហើយថា មន្ត្រីអាមេរិកាំងក៏មិនទុកចិត្ត លន់ ណុល ដែរ ។ ជូ អេន ឡាយ បានសម្តែងនូវការធូរស្បើយក្នុងចិត្តនៅពេលប្រជុំបក្សនាខែមីនា ឆ្នាំ១៩៧៣ ថា “ស្ថានការណ៍នៅកម្ពុជាមានលក្ខណៈល្អ...។ ឥឡូវនេះរបប លន់ ណុល គ្រប់គ្រងទឹកដីតែមួយភាគតូច ម្យ៉ាងវិញទៀត ហាក់ដូចជាថា ជនជាតិអាមេរិក មិនចង់គោរពប្រធានា-ធិបតីនេះណាស់ណាទេ ។ ថ្មីៗនេះ ឥរិយាបថរបស់

សម្តេច សីហនុ មានលក្ខណៈតឹងតែងនិងដាច់ខាត» ។

ដើម្បីធ្វើឲ្យរូបភាពរបស់សម្តេច សីហនុ កាន់តែប្រសើរឡើងដែលស្តែងចេញយ៉ាងប្រត្យក្សនៅលើខ្មែរក្រហម ចិន រួមជាមួយវៀតណាមខាងជើង បានរៀបចំដំណើរទស្សនកិច្ចរបស់ព្រះអង្គនៅក្នុងតំបន់កាន់កាប់ដោយពួកកុម្មុយនិស្តនៅក្នុងប្រទេសកម្ពុជានាខែកុម្ភៈ ឆ្នាំ១៩៧៣ ។ សម្តេច សីហនុ ទាមទារឲ្យមានដំណើរបែបនេះមួយរយៈមកហើយ ប៉ុន្តែថ្នាក់ដឹកនាំខ្មែរក្រហមតែងតែបដិសេធជានិច្ចដោយយកលេសថា គ្មានសន្តិសុខសម្រាប់ព្រះអង្គ ពីព្រោះអាមេរិកកំពុងតែទម្លាក់គ្រាប់បែកទៅលើផ្លូវលំហូជីមិញ ។ ក្រោយពីការចុះហត្ថលេខានៅទីក្រុងប៉ារីស សម្តេច សីហនុ បានលើកបញ្ហានេះជម្រាបជូន ខៀវ សំផន ឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដោយគំរាមថា ប្រសិនបើខ្មែរក្រហមបដិសេធសំណើរបស់ព្រះអង្គ ព្រះអង្គនឹងដកខ្លួនថយពីរណសិរ្សរួបរួមជាតិកម្ពុជាមិនខាន ។ នៅពេលនេះ ជូ អេន ឡាយ បានធ្វើអន្តរាគមន៍ជួសមុខឲ្យសម្តេច សីហនុ ។ ជូ អេន ឡាយ ពន្យល់ អៀង សារី អំពីផលប្រយោជន៍នយោបាយនៃការអនុញ្ញាតឲ្យសម្តេច សីហនុ ធ្វើដំណើរទស្សនកិច្ច ។ ក្រោមសម្ពាធរបស់ចិន ថ្នាក់ដឹកនាំខ្មែរក្រហមក៏ផ្តល់ឱកាសនេះដល់សម្តេច សីហនុ ។ នៅចុងខែកុម្ភៈ សម្តេច សីហនុ ដែលអមព្រះរាជដំណើរដោយអ្នកម្នាងមុនីនាថ សីហនុ និង អៀង សារី បានយាងដំណើរតាមរថយន្តហ្ស៊ីបរបស់សូវៀតតាមផ្លូវលំហូជីមិញមកកម្ពុជា ។ សម្តេចបានជួបជាមួយ ប៉ុល ពត និងថ្នាក់ដឹកនាំខ្មែរក្រហមមួយចំនួនទៀត បានយាងទតសិល្បៈ និងយាងទៅធ្វើព្រះរាជទស្សនកិច្ចនៅអង្គរវត្តនិងប្រាសាទផ្សេងៗទៀត ។ នៅថ្ងៃទី១២ ខែមេសា ជូ អេន ឡាយ បានរៀបចំពិធីលៀងសាយភោជន៍ស្វាគមន៍ដល់ សម្តេច សីហនុ ក្នុងដំណើរយាងត្រឡប់មកក្រុងប៉េកាំងវិញ ។ នៅឯពិធីលៀងសាយភោជន៍នោះ ជូ អេន ឡាយ បានបញ្ជាក់សាជាថ្មីនូវការគាំទ្ររបស់ចិនចំពោះសម្តេច សីហនុ ហើយបានថ្កោលទោសសហរដ្ឋអាមេរិកដែលកំពុងតែបន្តការគាំទ្ររបបលន់ណុល និងបន្តទម្លាក់គ្រាប់បែកមកលើទឹកដីកម្ពុជា ។

ប៉ុន្តែការប្រព្រឹត្តិរបស់ចិនចំពោះសម្តេច សីហនុ និងខ្មែរ-ក្រហម មានការប្រែប្រួលនៅចន្លោះឆ្នាំ១៩៧៣ ដល់ដើមឆ្នាំ១៩៧៤ ។ រហូតមកដល់ចុងឆ្នាំ១៩៧៣ ចិនបានពឹងផ្អែកជាបឋមមកលើកិច្ចសហប្រតិបត្តិការជាមួយសម្តេច សីហនុ ដើម្បីកម្រិតឥទ្ធិពលរបស់សូវៀតនិងវៀតណាមនៅកម្ពុជាហើយមានការប្រុងប្រយ័ត្នក្នុងការប្រព្រឹត្តិមកលើខ្មែរក្រហម ពីព្រោះខ្មែរក្រហមបាននិងកំពុងទទួលជំនួយពីក្រុងហាណូយនៅក្នុងការតស៊ូរបស់ខ្លួន ។ ប៉ុន្តែនៅឆ្នាំ១៩៧៤ ចិនកាន់តែរីករាយក្នុងការផ្តល់កិច្ចគាំទ្រចំពោះខ្មែរក្រហម ។ នៅខែមេសា ខៀវ សំផន បានទៅបំពេញទស្សនកិច្ចនៅក្រុងប៉េកាំង ហើយបានជួបជាមួយ ម៉ៅ សេទុង ។ ខៀវ សំផន ជាខ្មែរកុម្មុយនិស្តទីមួយ ដែលទទួលបាននូវកិត្តិយសបែបនេះ ។ នៅក្នុងការព្រមព្រៀងគ្នាជាមួយរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ចិនយល់ស្របក្នុងការផ្តល់បរិក្ខារសឹកនិងគ្រឿងផ្គត់ផ្គង់ ។ សេចក្តីសម្រេចចិត្តរបស់ក្រុងប៉េកាំងក្នុងការផ្តល់នូវជំនួយជាសម្ភារៈដល់ខ្មែរក្រហមអាចបណ្តាលមកពីការបង្ហាញឲ្យឃើញថា ក្រុងហាណូយកំពុងព្យាយាមពង្រឹងជំហររបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ទោះបីជា ប៉ុល ពត ខិតខំលុបបំបាត់សមាជិកដែលគាំទ្រវៀតណាមចេញពីបក្សរបស់ខ្លួនក៏ដោយ ។ ការទទួលដ៏កក់ក្តៅរបស់ក្រុងប៉េកាំង ចំពោះ ខៀវ សំផន គឺជាសញ្ញាបញ្ជាក់ប្រាប់អំពីការផ្លាស់ប្តូរគោលនយោបាយចេញពីការដោះស្រាយបែបនយោបាយ ពោលគឺការបង្កើតនូវរដ្ឋាភិបាលអព្យាក្រឹតដឹកនាំដោយសម្តេច សីហនុ ឆ្ពោះទៅរកដំណោះស្រាយតាមផ្លូវយោធាដើម្បីដោះស្រាយបញ្ហាកម្ពុជា ។

យោងតាមប្រភពឯកសារដែលទើបតែបញ្ចេញឲ្យដឹងថ្មីៗនេះតាមរយៈបណ្ណសារអាមេរិក បង្ហាញថា រដ្ឋការលោក ហ្វដ បានព្យាយាមបញ្ចុះបញ្ចូលឲ្យចិនជួយរក្សារបប លន់ ណុល ប្រឆាំងនឹងខ្មែរក្រហម ។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៤ រដ្ឋមន្ត្រីក្រសួងការបរទេស ឃីសស៊ីងជឺ បានបំពេញទស្សនកិច្ចនៅទីក្រុងប៉េកាំង ។ នៅក្នុងកិច្ចសន្ទនារបស់ខ្លួនជាមួយ តេង ស៊ាវភីង ដែលជំនួយការផ្ទាល់របស់ ជូ អេន ឡាយ, ឃីសស៊ីងជឺ បានស្នើឲ្យមានការលើកស្ទួយឲ្យសម្តេច សីហនុ បានឡើងកាន់អំណាចជាប្រមុខរដ្ឋាភិបាលចម្រុះដ៏ធំមួយនៅកម្ពុជា ដែលអាចរួមបញ្ចូលទាំងអ្នកគាំទ្ររបបលន់ណុលផង ។ ប៉ុន្តែ តេង ស៊ាវពីង បានបដិសេធសំណើរបស់ ឃីសស៊ីងជឺ ។ ក្រោយពីប្រកាសការគាំទ្រ

របស់ចិនចំពោះសម្តេច សីហនុ និងខ្មែរក្រហមរួចមក គេង ស៊ាវពីង បានប្រាប់ទៅ ឃីសស៊ីងជឺ ថា «យើងគិតថា ប្រសិនបើសហរដ្ឋអាមេរិកដាក់ក្តីសង្ឃឹមទៅលើលន់ណុល ឬកម្លាំងណាមួយដែលលោកគិតថាអាចជំនួស លន់ ណុល បាននោះគឺមិនគួរឲ្យជឿទេ» ។

ហេតុអ្វីបានជាក្រុងប៉េកាំងកាន់តែចង់គាំទ្រដល់ការតស៊ូអាវុធរបស់ខ្មែរក្រហមនៅឆ្នាំ១៩៧៤? ហេតុផលទីមួយគឺទាក់ទងនឹងការប្រែប្រួលនៅក្នុងផ្នត់គំនិតរបស់ថ្នាក់ដឹកនាំចិនទៅលើទំនាក់ទំនងរវាងខ្មែរក្រហមនិងវៀតណាមខាងជើងនៅអំឡុងពេលនោះ ។ នៅឆ្នាំ១៩៧៤ ប៉ុល ពត កាន់តែមានឯករាជ្យខ្លាំងឡើងៗពីក្រុងហាណូយ ហើយមានការប៉ះទង្គិចធំៗរវាងកងកម្លាំងរបស់ ប៉ុល ពត និងកងទ័ពវៀតណាមខាងជើង ។ ជាការច្បាស់ណាស់ថា អ្នកតាក់តែងគោលនយោបាយរបស់ចិនលែងយល់អំពីទស្សនវិស័យថាកម្ពុជាដែលកាន់កាប់ដោយខ្មែរក្រហមលែងមានសម្ព័ន្ធភាពជាមួយវៀតណាមទៀតហើយ ។ ដោយដឹងអំពីការតាំងចិត្តនិងកម្លាំងរបស់ខ្មែរក្រហម អ្នកទាំងនោះប្រកាន់យកជំហរច្បាស់ថា ប្រសិនបើគេចង់ទទួលបាននូវផលប្រយោជន៍លើវៀតណាមនិងរុស្ស៊ីនៅកម្ពុជា គេត្រូវតែគាំទ្រ ប៉ុល ពត ។

ចិនដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយដល់ខ្មែរក្រហមឲ្យសម្រេចជំហានចុងក្រោយដើម្បីគ្រប់គ្រងអំណាចនៅកម្ពុជា ។ ក្រុងប៉េកាំងបានជួយជ្រោមជ្រែងខ្មែរក្រហមក្នុងការវាយប្រហារមកលើក្រុងភ្នំពេញនៅដើមឆ្នាំ១៩៧៥ ដោយជួយដាក់មីននៅតាមបណ្តោយទន្លេមេគង្គដែលជាខ្សែក្រវាត់ការពារក្រុងដ៏សំខាន់ ។ នៅថ្ងៃទី១៧ ខែមេសា ខ្មែរក្រហមវាយយកបានទីក្រុងភ្នំពេញ ។

ក្រោយពីកាន់អំណាចបានបន្តិចមក ប៉ុល ពត បានធ្វើទស្សនកិច្ចទីក្រុងប៉េកាំងនៅខែមិថុនា ឆ្នាំ១៩៧៥ និងទទួលនូវការស្វាគមន៍ពីគ្រូមនោគមវិជ្ជា ម៉ៅ សេទុង ។ នៅក្នុងកិច្ចសន្ទនាអ្នកទាំងពីរបាននិយាយបំផ្លើសនិងបញ្ជោរគ្នាទៅវិញទៅមក ។ ម៉ៅ សេទុង ប្រាប់ ប៉ុល ពត ថា «សមមិត្តបានសម្រេចយ៉ាងងាយស្រួល នូវអ្វីដែលយើងមិនអាចសម្រេចបានទោះជាប្រើអស់កម្លាំងជាច្រើនក៏ដោយ» ។ ក្រោយពីលើកសរសើរមេដឹកនាំខ្មែរក្រហមថាបានអនុវត្តនយោបាយបានត្រឹមត្រូវរួចមក ម៉ៅ សេទុង និយាយថាបទពិសោធន៍បដិវត្តន៍កន្លងមករបស់បក្សកុម្មុយនិស្តកម្ពុជាល្អជាងបក្សកុម្មុយនិស្តចិនឆ្ងាយណាស់» ។ ម៉ៅ សេទុង ពិតជារំជួលចិត្តដោយឃើញខ្មែរក្រហមសម្រេចបានជោគជ័យបែបនេះ ។ ដូចជាអ្វីដែល ស្តាលីន មានអារម្មណ៍សប្បាយនិងមានកម្លាំងចិត្តដោយសារជោគជ័យរបស់ជនកុម្មុយនិស្តវ័យក្មេងរបស់ចិននៅឆ្នាំ១៩៤៩ដែរ ម៉ៅ សេទុង ដែលមានវ័យកាន់តែចាស់ទៅហើយនោះ ឥឡូវនេះបានឃើញជោគជ័យរបស់ ប៉ុល ពត គាត់គិតថា ខ្លួនបានប្រែក្លាយជាជនកុម្មុយនិស្តវ័យក្មេងម្តងទៀត ។ ម៉ៅ បានប្រាប់ ប៉ុល ពត ថា ទម្រាំតែយល់ដឹងអំពីលទ្ធិកុម្មុយនិស្ត គឺមានការលំបាកស្មុគស្មាញណាស់ ។ ម៉ៅ សេទុង បន្តទៀតថា ទោះបីជា គ្រូតឆេវ និង លីអូនីដ ប្រឹសណេវ ដើរខុសពីលទ្ធិម៉ាក្ស-ឡេនីនក៏ដោយ ក៏នៅទីបញ្ចប់ សហភាពសូវៀតគង់តែនឹងវិលត្រឡប់មករកគោលការណ៍របស់ឡេនីនដដែល ។ ចិនក៏ដូចគ្នាដែរ គឺអាចត្រឡប់រកលទ្ធិសេរីនិយមនៅថ្ងៃអនាគត ប៉ុន្តែចុងក្រោយចិនអាចវិលត្រឡប់ទៅរកមាគ៌ាម៉ាក្ស-ឡេនីនវិញ ។

ឆ្លើយតបនឹងពាក្យសរសើរនេះ ប៉ុល ពត និយាយថា ខ្លួនបានចាប់ផ្តើមអានសំណេររបស់ ម៉ៅ សេទុង ជាពិសេសស្តីអំពីសង្គ្រាមប្រជាជននៅពេលដែលខ្លួននៅជាយុវជន ខ្លួនបានប្រើគំនិតរបស់ ម៉ៅ ដើម្បីដឹកនាំបក្ស ។ ប៉ុល ពត បានប្រាប់ ម៉ៅ សេទុង ថាខ្លួននឹងបន្តសិក្សាទាញយកបទពិសោធន៍របស់ចិន ដោយយកចិត្តទុកដាក់ទៅលើការតស៊ូវណ្ណៈ ។ ម៉ៅ សេទុង បានបញ្ចប់កិច្ចសន្ទនាដោយសូមកុំឲ្យ ប៉ុល ពត យកគំរូតាមចិនសុទ្ធសាធពេក ហើយបានផ្តល់ជាអំណោយសៀវភៅ៣០ក្បាល ដែលនិពន្ធដោយ ម៉ាក្ស អង់ហ្គែល ឡេនីន និងស្តាលីន ។ ដោយមានបំណងចង់ជំរុញឲ្យ ប៉ុល ពត ប្រកាន់នយោបាយឯករាជ្យពីវៀតណាម ម៉ៅ សេទុង បានចាត់ទុកកម្ពុជាជាតុល្យភាពសម្រាប់ទប់ទល់ជាមួយមហិច្ឆតារបស់វៀតណាមនៅក្នុងជ្រោយឥណ្ឌូចិន ។ នៅក្នុងអំឡុងពេលទស្សនកិច្ចរបស់ ប៉ុល ពត ចិនបានសន្យាផ្តល់ឲ្យកម្ពុជានូវជំនួយសេដ្ឋកិច្ចនិងយោធាគិតជាទឹកប្រាក់ជាងមួយ

កោះដិដុល្ហារ ។

មេដឹកនាំខ្មែរក្រហមជាសត្រូវរបស់សម្តេច សីហនុ ហើយមេដឹកនាំខ្មែរក្រហមមិនចង់ឃើញសម្តេច សីហនុ នៅលើទឹកដីកម្ពុជាទៀតឡើយ ។ សម្តេច សីហនុ បានបង្ហាញការមិនសប្បាយព្រះទ័យដោយបដិសេធមិនព្រមចូលរួមអគ្គមិទ្ទីងមហាជនអបអរដល់ការរំដោះក្រុងភ្នំពេញ ដែលរៀបចំឡើងដោយរដ្ឋាភិបាលចិននៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៥ ។ សម្តេចបានត្រឹមតែឲ្យសម្តេច ប៉ែន នុត នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាថ្លែងសុន្ទរកថាជួសមុខឲ្យព្រះអង្គនៅឯពិធីនោះប៉ុណ្ណោះ ។ ម្យ៉ាងវិញទៀត សម្តេច សីហនុ បានចាកចេញពទីក្រុងប៉េកាំង នៅខែឧសភា ទៅគង់ប្រថាប់នៅទីក្រុងព្យុងយ៉ាងវិញ ។

ថ្នាក់ដឹកនាំចិនមិនយល់ស្របចំពោះទង្វើរបស់ ប៉ុល ពត មកលើសម្តេច សីហនុ ឡើយ ។ ថ្នាក់ដឹកនាំចិនជឿថា ការបន្តដំណើរការរណសិរ្សរួបរួមជាតិជាមួយសម្តេច សីហនុ អាចជួយឲ្យខ្មែរក្រហមកាន់តែរឹងមាំនៅក្នុងស្រុក ។ នៅអំឡុងពេលសន្ទនាគ្នាជាមួយ ប៉ុល ពត នៅទីក្រុងប៉េកាំងនៅខែមិថុនា ឆ្នាំ១៩៧៥ តេង ស៊ាវ ភីង បានជំរុញឲ្យខ្មែរក្រហមបន្តនយោបាយរួបរួមរបស់ខ្លួនជាមួយសម្តេច សីហនុ ដើម្បីធ្វើឲ្យមានស្ថិរភាពនយោបាយនៅកម្ពុជា ។ តេង ស៊ាវ ភីង បានសុំឲ្យ ប៉ុល ពត អនុញ្ញាតឲ្យសម្តេច សីហនុ វិលត្រឡប់មកទីក្រុងភ្នំពេញវិញ ។ ជូ អេន ឡាយ ដែលជាអ្នកឧបត្ថម្ភដ៏យូរយារមកហើយរបស់សម្តេច សីហនុ ក៏បានដាក់សម្ពាធទៅលើខ្មែរក្រហមឲ្យប្រព្រឹត្តមកលើព្រះអង្គឲ្យបានសមរម្យ ហើយអនុញ្ញាតឲ្យព្រះអង្គវិលត្រឡប់មកកម្ពុជាវិញ ។ នៅថ្ងៃទី១៦ ខែសីហា ជូ អេន ឡាយ បានជួបជាមួយ ខៀវ សំផន និង អៀង សារី នៅមន្ទីរពេទ្យក្រុងប៉េកាំងដែលនៅទីនោះ ជូ អេន ឡាយ កំពុងតែព្យាបាលជំងឺ គឺជួបដើម្បីពិភាក្សាអំពីបញ្ហាសម្តេច សីហនុ ។

ក្រោមសម្ពាធរបស់ចិន នៅទីបំផុតខ្មែរក្រហមក៏បន្ទន់តវិយាបថ ។ ប៉ុល ពត បានបញ្ជូន ខៀវ សំផន ទៅកូរ៉េខាងជើង ដើម្បីយាងសម្តេច សីហនុ ឲ្យវិលត្រឡប់មកកម្ពុជាវិញ ។ សម្តេច សីហនុ បានធ្វើដំណើរទៅក្រុងប៉េកាំងនៅខែសីហា ។ មុនពេលយាងចេញដំណើរមកកាន់កម្ពុជា សម្តេច សីហនុ និង សម្តេច ប៉ែន នុត បានជួបជាមួយ ជូ អេន ឡាយ នៅក្នុងមន្ទីរពេទ្យនៅថ្ងៃទី២៦ ខែសីហា ។ នាយករដ្ឋមន្ត្រីចិនអបអរ-សាទរចំពោះជ័យជម្នះរបស់ប្រជាជនកម្ពុជាលើពួកអាមេរិក ដោយប្រកាសថា ជ័យជម្នះរបស់ប្រជាជនកម្ពុជាពិតជាត្រឹមត្រូវតាមទ្រឹស្តីរបស់ ម៉ៅ សេទុង ពិតមែន ដែលថា "ប្រទេសតូចអាចវាយប្រទេសធំ ហើយរដ្ឋខ្សោយអាចយកឈ្នះរដ្ឋខ្លាំង" ។ ជូ អេន ឡាយ បានសុំឲ្យអ្នកស្តាប់កម្ពុជាពង្រឹងជ័យជម្នះរបស់ខ្លួន និងកសាងប្រទេសដោយឯករាជ្យ ។ អមព្រះរាជដំណើរដោយ ខៀវ សំផន សម្តេច សីហនុ ក៏បានជម្រាបលា ម៉ៅ សេទុង នៅថ្ងៃទី២៧ ខែសីហា ។ ដោយសម្តែងនូវការពេញចិត្តចំពោះការរំដោះនៅកម្ពុជា ម៉ៅ សេទុង និយាយថា គាត់មិនដែលសង្ឃឹមថាជ័យជម្នះទទួលបានយ៉ាងឆាប់រហ័សបែបនេះទេ ។ ងាកមករក ខៀវ សំផន វិញ ម៉ៅ សេទុង បានបង្គំឲ្យខ្មែរក្រហមស្រុះស្រួលគ្នាកុំប្រទាំងប្រទើសនឹងគ្នាក្នុងការប្រព្រឹត្តិមកលើសម្តេចសីហនុ ។ ម៉ៅ សេទុង បញ្ចប់សេចក្តីដោយនិយាយសើចលេងជាមួយសម្តេច សីហនុ ថា ប្រសិនបើខ្មែរក្រហមធ្វើមិនល្អចំពោះព្រះអង្គទៀត សម្តេចនឹងបានទទួល "ការស្វាគមន៍ដ៏កក់ក្តៅម្តងទៀត" នៅប្រទេសចិន ។ សម្តេច សីហនុ នៅតែជាប្រធានរដ្ឋមានតែឈ្មោះដដែលរហូតដល់ខែមេសា ឆ្នាំ១៩៧៦ គឺជាពេលដែលសម្តេចបានលាលែងពីតំណែង ។ សម្តេច សីហនុ បានចំណាយពេល២៣ខែ ជាប់ឃុំនៅក្នុងព្រះបរមរាជវាំងនៅក្រុងភ្នំពេញ ។ មរណភាព របស់ ជូ អេន ឡាយ នៅខែមករា ឆ្នាំ១៩៧៦ ពិតជាបានដកចេញនូវឧបសគ្គដ៏ធំមួយរបស់ខ្មែរក្រហមប្រឆាំងនឹងសម្តេច សីហនុ ។

## សេចក្តីសន្និដ្ឋាន

ដំណោះស្រាយរបស់ចិនចំពោះជម្លោះនៅកម្ពុជារវាងឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ គឺធ្វើឡើងដោយមានលក្ខខណ្ឌចម្បងនៃការប្រកួតប្រជែងជាមួយសហភាពសូវៀតនិងវៀតណាមខាងជើងទៅលើជ្រោយឥណ្ឌូចិន ។ ចាប់តាំងពីការចូលលុកលុយរបស់សហភាពសូវៀតទៅលើប្រទេសឆេកូស្លូវ៉ាគីនៅឆ្នាំ១៩៦៨ និងការប៉ះទង្គិចនៅតាមព្រំដែនសូវៀត-ចិននៅឆ្នាំ១៩៦៩មក

ថ្នាក់ដឹកនាំចិនបានចាប់ផ្តើមចាត់ទុកសហភាពសូវៀតថាជាការគំរាមកំហែងប្រកបដោយគ្រោះថ្នាក់ដល់ចិន ។ កិច្ចសហប្រតិបត្តិការចេះតែកើនឡើងរបស់ក្រុងហាណូយជាមួយក្រុងម៉ូស្គូនៅក្នុងសង្គ្រាមរបស់ខ្លួនប្រឆាំងនឹងសហរដ្ឋអាមេរិក មានលក្ខណៈកាន់តែធ្វើឲ្យខ្លួនមានការព្រួយបារម្ភខ្លាំងទៅៗអំពីការឡោមព័ទ្ធរបស់សូវៀតទៅលើចិន ។ នៅឆ្នាំ១៩៧០ ថ្នាក់ដឹកនាំចិនបានផ្តល់ជម្រកនិងជំនួយឧបត្ថម្ភដល់សម្តេច សីហនុ ដើម្បីរក្សានូវឥទ្ធិពលរបស់ខ្លួននៅកម្ពុជា ។ ថ្នាក់ដឹកនាំចិនគឺជាឧបករណ៍សំខាន់សម្រាប់បង្កើតរណសិរ្សរួបរួមមួយរវាងសម្តេច សីហនុ និងខ្មែរក្រហម ។ ក៏ប៉ុន្តែដោយមិនប្រាកដក្នុងចិត្តអំពីទំនាក់ទំនងរវាងខ្មែរក្រហមនិងវៀតណាមខាងជើង ថ្នាក់ដឹកនាំចិនផ្តោតជាសំខាន់ទៅលើសម្តេច សីហនុ ។ នៅពេលដែលការកាត់ផ្តាច់ទំនាក់ទំនងរបស់ប៉ុល ពត ជាមួយក្រុងហាណូយកាន់តែលេចរូបរាងច្បាស់នៅដើមឆ្នាំ១៩៧៤ ថ្នាក់ដឹកនាំចិនចាប់ផ្តើមសម្តែងនូវភាពសាទរក្នុងការគាំទ្រចលនារបស់ ប៉ុល ពតវិញ ។

ចិននិងសហរដ្ឋអាមេរិកមានផលប្រយោជន៍ជាយុទ្ធសាស្ត្រដូចគ្នាក្នុងការកម្រិតឥទ្ធិពលរបស់សូវៀតនៅលើជ្រោយឥណ្ឌូចិន ។ នៅដើមឆ្នាំ១៩៧៣ ជូ អេន ឡាយ និង ឃីសស៊ីងជឺ បានឈានដល់កិច្ចព្រមព្រៀងគ្នាមួយស្តីអំពីការចែករំលែកទៅវិញទៅមកអំពីព័ត៌មានសម្ងាត់ ពោលគឺប្រទេសទាំងពីរនឹងផ្តល់ព័ត៌មានឲ្យគ្នាទៅវិញទៅមកអំពីសកម្មភាពរបស់សូវៀតនៅកម្ពុជា ។ ដោយយល់ស្របគ្នាទៅលើគោលដៅទូទៅក្នុងការកម្រិតឥទ្ធិពលរបស់សូវៀតនៅកម្ពុជាឲ្យតិចបំផុតនោះ ចិននិងអាមេរិកក៏មានគំនិតខ្វែងគ្នាទៅលើបញ្ហាថាតើត្រូវគាំទ្រក្រុមកម្ពុជាណាមួយដើម្បីធ្វើឲ្យគោលដៅនេះបានសម្រេច ។ ចិនពឹងផ្អែកជាដំបូងទៅលើសម្តេច សីហនុ ហើយក្រោយមកពឹងផ្អែកលើខ្មែរក្រហម ។ ចំណែកឯអាមេរិកាំងមុនដំបូងគាំទ្រ លន់ ណុល ហើយបដិសេធសម្តេច សីហនុ និងខ្មែរក្រហម ។ ប៉ុន្តែក្រោយមកក៏ផ្លាស់ប្តូរជំហររបស់ខ្លួនដោយយល់ស្របថានឹងធ្វើឲ្យសម្តេច សីហនុ មានតំណែងដូចដើមវិញនៅក្នុងរដ្ឋាភិបាលចម្រុះដ៏ធំដែលក៏នឹងត្រូវសហការជាមួយអ្នកគាំទ្រខាង លន់ ណុលដែរ ។

នៅដើមឆ្នាំ១៩៧៣ និងនៅក្នុងអំឡុងរដូវក្តៅឆ្នាំ១៩៧៥ ចិនបានដាក់សម្ពាធមកលើខ្មែរក្រហមជាលើកទីពីរ ដើម្បីឲ្យខ្មែរក្រហមប្រព្រឹត្តមកលើសម្តេច សីហនុ ឲ្យបានសមគួរ ។ ឧទាហរណ៍ក្រុងប៉េកាំងទទូចថា ខ្មែរក្រហមត្រូវនាំសម្តេច សីហនុ យាងទតនៅតំបន់រំដោះនានានៅក្នុងទឹកដីកម្ពុជា ។ ថ្នាក់ដឹកនាំចិនចង់លើកកម្ពស់ឋានៈរបស់សម្តេច សីហនុ ពីព្រោះគេមើលឃើញថាសម្តេច សីហនុ គឺជាឧបករណ៍ដ៏សំខាន់សម្រាប់រក្សាឥទ្ធិពលរបស់ចិននៅកម្ពុជានៅពេលនោះ ។ ឧទាហរណ៍មួយទៀត មន្ត្រីក្រុងប៉េកាំងជំរុញឲ្យរដ្ឋាភិបាលខ្មែរក្រហមអនុញ្ញាតឲ្យសម្តេច សីហនុ យាងត្រឡប់មកកម្ពុជាដោយហេតុផលថា សម្តេច អាចបម្រើឲ្យគោលបំណងរណសិរ្សរួបរួមប្រកបដោយគុណប្រយោជន៍ ។ ភាពចាំបាច់របស់ខ្មែរក្រហមចង់ឲ្យចិនគាំទ្រខាងនយោបាយនិងសម្ភារដែលមុនដំបូងប្រឆាំងនឹងអាមេរិកាំង និង លន់ ណុល ក្រោយមកប្រឆាំងនឹងវៀតណាមនោះបានពន្យល់អំពីឆន្ទៈរបស់ខ្លួនចង់ទទួលសំណើរបស់ចិន ។ ជំនួយរបស់ក្រុងប៉េកាំងបានជួយឲ្យខ្មែរក្រហមកាន់កាប់អំណាចនៅកម្ពុជាក្នុងឆ្នាំ១៩៧៥ ហើយទប់ទល់នឹងសម្ពាធរបស់វៀតណាមរហូតដល់ឆ្នាំ១៩៧៨ ។

**ឈាំង ថៃ**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: dccam@online.com.kh*

*Home page: www.dccam.org*

# ពិចារណាឡើងវិញនូវអនុសញ្ញាទីក្រុងហ្សឺណែវ

អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងពិធីសារបន្ថែមចំនួនពីរទៀតធ្វើឡើងនៅឆ្នាំ១៩៧៧ គឺជាប្រភពច្បាប់មនុស្សធម៌អន្តរជាតិជាលាយលក្ខណ៍អក្សរដ៏ច្បាស់លាស់ ។ ច្បាប់និងពិធីសារទាំងនេះរៀបចំប្រមូលជាបទដ្ឋាននានាដែលប្រទេសទាំងឡាយបានគាត់តែងសម្រាប់ឲ្យមានឥរិយាបថប្រកបដោយមេត្តាភាពនៅក្នុងពេលមានសង្គ្រាម ហើយបានបង្ហាញឲ្យឃើញថាទោះបីជាស្ថិតនៅក្នុងពេលមានកលយុគក៏ឥរិយាមារយាទដែលអាចទទួលយកបាននៅមានកម្រិតនៅឡើយ ។ អនុសញ្ញាទាំងនេះគឺជាកម្លាំងជំរុញឲ្យមានការស្អប់ខ្ពើមអំពើឃោរឃៅដ៏អាក្រក់បំផុតនៅក្នុងសតវត្សរ៍ទី២០នេះ ប៉ុន្តែអនុសញ្ញានេះក៏បង្ហាញថាខ្លួនមានភាពចំណាស់នៅក្នុងក្រសែភ្នែកបុគ្គលមួយចំនួន ។

ក៏ដូចជាអនុសញ្ញាអន្តរជាតិដែរ អនុសញ្ញាទីក្រុងហ្សឺណែវនិងពិធីសារបន្ថែមគឺមានវ័យចំណាស់បន្តិចហើយ ។ ច្បាប់ទាំងនេះឆ្លុះបញ្ចាំងអំពីការយល់ឃើញកាលពីសម័យធ្វើច្បាប់ទៅលើសារជាតិនៃសង្គ្រាមនិងការព្រួយបារម្ភ ព្រមទាំងការសំដៅទៅលើនយោបាយអន្តរជាតិសម័យបច្ចុប្បន្ន ។ ដោយសារច្បាប់សង្គ្រាមត្រូវបានធ្វើឲ្យទាន់សម័យចុងក្រោយបង្អស់នៅឆ្នាំ១៩៧៧ម្ល៉េះហើយបានជាមានការផ្លាស់ប្តូរសំខាន់ៗជាច្រើនទាក់ទងនឹងសារជាតិនៃជម្លោះប្រដាប់អាវុធ ។ ថ្មីៗនេះមានយុទ្ធនាការរបស់សហរដ្ឋអាមេរិកប្រឆាំងនឹងភេរវកម្មពិភពលោកដែលធ្វើឲ្យក្រឡាប់ចាក់ដល់ការសន្និដ្ឋាននានាដែលច្បាប់មនុស្សធម៌អន្តរជាតិត្រូវបានគេពឹងផ្អែកជាប្រពៃណី ។

រដ្ឋាភិបាលប្រទេសស៊ុយស៊ីសឥឡូវនេះបានផ្តើមគំនិតចង់សើរើរបៀបរបបអនុវត្តទៅលើជម្លោះប្រដាប់អាវុធនៅក្នុងបច្ចុប្បន្នកាលនៃពិភពលោកយើងនេះ ។ នៅចន្លោះថ្ងៃទី២៧ និង ២៨ ខែមករា ឆ្នាំ២០០៣ មានការប្រជុំមិនផ្លូវការមួយរវាងអ្នកជំនាញការនានាមកពីរដ្ឋាភិបាលនៃប្រទេសជាច្រើនមកពីគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ និងអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ជាច្រើននាក់ទៀតរៀបចំធ្វើឡើងនៅសាកលវិទ្យាល័យហាវើដក្នុងគោលបំណងរៀបចំជារបៀបវារៈសម្រាប់ការពិភាក្សា និងការស្រាវជ្រាវបន្ថែមទៀត ។ នៅពេលកំពុងដំណើរការកិច្ចប្រជុំនេះ កម្មវិធីទូរទស្សន៍សង្គ្រាមបានសាកសួរទៅអ្នកជំនាញការពីររូបស្តីអំពីច្បាប់សង្គ្រាមដើម្បីឲ្យអស់លោកពិភាក្សាដេញដោលទៅមើលថាអនុសញ្ញាទីក្រុងហ្សឺណែវចាំបាច់ត្រូវតែធ្វើឲ្យទាន់សម័យកាលបច្ចុប្បន្នដែរឬទេ ។

ក្រោយពីសង្គ្រាមលោកលើកទីពីរនីតិនិពន្ធដែលជាអ្នកធ្វើសេចក្តីព្រាងអនុសញ្ញាទីក្រុងហ្សឺណែវទាំងបួននៅឆ្នាំ១៩៤៩មានការបារម្ភយ៉ាងខ្លាំងចំពោះសង្គ្រាមរវាងរដ្ឋនិងរដ្ឋ(ទោះបីជានៅក្នុងមាត្រា៣ អនុសញ្ញានេះបានចែងអំពីបទដ្ឋានអប្បបរមាសម្រាប់ជម្លោះប្រដាប់អាវុធហើយក្តី) ។ អនុសញ្ញានេះភាគច្រើនទាក់ទងទៅនឹងប្រព្រឹត្តិកម្មមកលើកម្លាំងខ្មាំងដែលរងរបួស ឬចាប់ជាឈ្លើយសឹកនិងជនស៊ីវិលដែលធ្លាក់នៅក្នុងកណ្តាប់ដៃខ្មាំង ឬកំពុងរស់នៅក្នុងទឹកដីកាន់កាប់ ។

នៅពេលដែលប្រតិភូរដ្ឋាភិបាលចាប់ផ្តើមដំណើរការចរចាស៊ីជម្រៅដែលនាំដល់វិធីសារបន្ថែមនៅទសវត្សរ៍ឆ្នាំ១៩៧០ ប្រតិភូមានបំណងបំពេញចន្លោះដែលបន្សល់ទុកដោយអនុសញ្ញា ព្រមទាំងឆ្លុះបញ្ចាំងអំពីការចាប់អារម្មណ៍កាន់តែខ្លាំងឡើងៗទៅលើសង្គ្រាមស៊ីវិលនិងសង្គ្រាមរំដោះជាតិ ។ ពិធីសារបន្ថែមទីមួយរួមមានវិធានការមួយចំនួនក្នុងការកម្រិតនូវផលប៉ះពាល់ចំពោះជនស៊ីវិលនៅក្នុងអំឡុងពេលមានការប្រយុទ្ធគ្នារវាងរដ្ឋនិងរដ្ឋៈ ដូចជាពិធីសារនេះខិតខំកម្រិតការវាយប្រហារឲ្យចូលនៅក្នុងគោលដៅយោធាដែលអាចកំណត់ជានិយមន័យបាន និងនិយាយថា ការខូចខាតដោយចៃដន្យដែលកើតឡើងចំពោះជនស៊ីវិលមិនត្រូវធ្វើឲ្យលើសពីផលប្រយោជន៍យោធា ដែលត្រូវបានរំពឹងទុកនោះទេ ។ ពិធីសារទីពីរគឺសំដៅទៅលើជម្លោះប្រដាប់អាវុធដែលកើតឡើងនៅក្នុងទឹកដីរបស់រដ្ឋជាសមាជិកមួយ ។

ពិធីសារនេះសំដៅពង្រីកបន្ថែមនូវគោលការណ៍ជាច្រើនទៀតដែលមានរួចហើយសម្រាប់សង្គ្រាមអន្តរ-រដ្ឋៈ ប្រឆាំងនឹងការវាយប្រហារលើជនស៊ីវិល ការប៉ុនប៉ងធ្វើឲ្យជនស៊ីវិលភ័យខ្លាំងការដាក់ទណ្ឌកម្មរួម ឬការវាយប្រហារទៅលើបុគ្គលិកពេទ្យ និងគាំទ្រដល់ប្រព្រឹត្តិកម្មដោយក្តីមេត្តាមកលើឈ្លើយសឹក ។

យោងតាមប្រសាសន៍របស់លោកសាស្ត្រាចារ្យ ម៉ៃឃើល ស្មីត នៃមជ្ឈមណ្ឌល ចច ម៉ាហ្សាល នៅប្រទេសអាល្លឺម៉ង់ បានឲ្យដឹងថា ឥឡូវនេះដល់ពេលត្រូវសើរើការងារដាក់ស្តែងនៃច្បាប់មនុស្សធម៌អន្តរជាតិម្តងទៀតហើយ ។ លោកមានប្រសាសន៍ថា“អនុសញ្ញានិងពិធីសារ ផ្ទុកទៅដោយកំហុសធំៗ”ដែលកម្រិតដល់ប្រសិទ្ធភាពក្នុងការទប់មិនឲ្យមានការលើសលស់នៅក្នុងការធ្វើសង្គ្រាមនាពេលបច្ចុប្បន្ន ។ ចំណុចសំខាន់នៃការរិះគន់របស់ស្មីត គឺការទាញហេតុផលថា សារជាតិអាចបត់បែនបាននៃជម្លោះប្រដាប់អាវុធមានន័យថាអនុសញ្ញាទីក្រុងហ្សឺណែវមិនអាចចាត់ការបានជាមួយនឹងអំពើឃោរឃៅភាគច្រើនដែលកើតឡើងនៅក្នុងពិភពលោកនាពេលបច្ចុប្បន្ន ហើយថានៅពេលដែលគេដោះស្រាយមានកើតចេញនូវចំណុចខ្សោយមកជាប់ជាមួយដែរ ។

សហរដ្ឋអាមេរិកអាចនិយាយអំពី“សង្គ្រាមប្រឆាំងនឹងភេរវកម្ម” ប៉ុន្តែលោក ស្មីត មានទឡ្ហីករណ៍ថាយុទ្ធនាការរបស់សហរដ្ឋអាមេរិកប្រឆាំងនឹងអង្គការអាល់កេដាមិនស៊ីគ្នាទៅនឹងក្របខ័ណ្ឌនៃអនុសញ្ញាទីក្រុងហ្សឺណែវទេ ។ លោកមានជំនឿថាសហរដ្ឋអាមេរិកមានហេតុផលប្រើកម្លាំងទ័ពប្រឆាំងនឹងការគំរាមកំហែងភេរវកម្ម ប៉ុន្តែបើតាមផ្លូវច្បាប់គ្មានលក្ខណៈវិនិច្ឆ័យច្បាស់លាស់ក្នុងការកំណត់ថាតើកម្លាំងនោះប្រើបានត្រឹមណា ឬភេរវករដែលស្ថិតក្នុងការសង្ស័យត្រូវឃុំខ្លួនរយៈពេលយូរប៉ុនណានៅពេលមានប្រតិបត្តិការកើតឡើងឡើយ ។ នៅក្នុងជម្លោះបែបនេះ ស្មីត សន្និដ្ឋានថា “របៀបបែងចែករវាងជម្លោះប្រដាប់អាវុធអន្តរជាតិ ជម្លោះប្រដាប់អាវុធផ្ទៃក្នុងភេរវកម្ម និងភាពមានពិរុទ្ធខាងព្រហ្មទណ្ឌកំពុងតែឡូកឡំគ្នាគ្មានអ្វីច្បាស់លាស់ឡើយ” ។

ស្មីត ក៏អះអាងដែរថា គោលការណ៍“សមាមាត្រ”ដ៏សំខាន់ត្រូវការចាំបាច់នូវការឲ្យនិយមន័យឲ្យបានកាន់តែច្បាស់ ។ នេះគឺជាគំនិតដំបូងដែលមានសារសំខាន់ចំពោះពិធីសារបន្ថែមទីមួយដែលតម្រូវឲ្យអ្នកវាយប្រហារបង្កើតតុល្យភាពរវាងផលប្រយោជន៍ខាងយោធាជាក់ស្តែង និងដោយផ្ទាល់ជាមួយនឹងការប្រថុយគ្រោះថ្នាក់ធ្វើឲ្យប៉ះពាល់ដល់ជនស៊ីវិលៈ ការវិនិច្ឆ័យជាពិសេសគឺនៅពេលដែលខ្សែខណ្ឌចែករវាងកម្លាំងប្រដាប់អាវុធ និងក្រុមជនស៊ីវិលកាន់តែមានលក្ខណៈឡូកឡំមិនច្បាស់លាស់ហើយនោះ ។

ស្មីត សារភាពថា សញ្ញាណនៃគោលដៅយោធាចាំបាច់ត្រូវតែធ្វើឲ្យបានកាន់តែច្បាស់លាស់ ។ ការសម្រេចអំពីអ្វីដែលបង្កើតបានជាគោលបំណងយោធាស្របច្បាប់នោះគឺពិតជាការងារដ៏លំបាកនៅក្នុងជម្លោះប្រដាប់អាវុធនាពេលបច្ចុប្បន្ននេះ ហើយគោលបំណងនេះមិនមែនជាការចុះចុះចាញ់រដ្ឋដែលជាសត្រូវតាមផ្លូវយោធាទាំងស្រុង ប៉ុន្តែជាការប៉ុនប៉ងបង្ខំឲ្យរបបណាមួយអនុលោមតាមតម្រូវការតាមការកំណត់ជាក់ស្តែង ។ ស្មីត និយាយយោងដល់ការទម្លាក់គ្រាប់បែករបស់ណាតូមកលើប្រទេសស៊ែប៊ីនាឆ្នាំ១៩៩៩ ។ នៅក្នុងយុទ្ធនាការទម្លាក់គ្រាប់បែកនេះ មានភាពចម្រូងចម្រាសទៅលើការវាយប្រហាររបស់អង្គការណាតូទៅលើស្ទូឌីយោវិទ្យុ-ទូរទស្សន៍របស់ស៊ែប៊ី ។ តើនេះគួរតែត្រូវបានចាត់ទុកថាជាគោលដៅយោធាដែរឬទេ?

លោកសាស្ត្រាចារ្យ ស៊ីវ រ៉ាត់ន័រ នៃសាកលវិទ្យាល័យតិចសាសអាចយល់ស្របចំពោះការអង្កេតមួយចំនួន ប៉ុន្តែបាននិយាយថា វិធីដោះស្រាយបញ្ហាទាំងនេះគឺមិនមែនជាការដោះស្រាយដោយការបង្កើតឯកសារ ឬអនុសញ្ញាថ្មីនោះទេ ។ ទាក់ទងនឹងសង្គ្រាមប្រឆាំងនឹងភេរវកម្ម លោក រ៉ាត់ន័រ មានប្រសាសន៍ថា អនុសញ្ញាទីក្រុងហ្សឺណែវមិនអាចអនុវត្តបានក៏ពិតមែន ប៉ុន្តែសង្គ្រាមត្រូវស្ថិតនៅក្រោមច្បាប់ទម្លាប់អន្តរជាតិដែលគោលការណ៍ច្បាប់នេះ“បានមកពីទម្លាប់គោលការណ៍មនុស្សជាតិ និងមកពីតម្រូវការមនសិការសាធារណៈ”ដូចដែលមានចែងនៅក្នុងពិធីសារទីមួយ ។ និយាយម្យ៉ាងវិញទៀត សហរដ្ឋអាមេរិក មានកាតព្វកិច្ចប្រតិបត្តិតាមគោលការណ៍ជាមូលដ្ឋានមួយចំនួនដូចជាមិនដៅលើជនស៊ីវិលមិនធ្វើឲ្យគ្រោះថ្នាក់ដល់យុទ្ធជនរបស់ខ្មាំងដែលស្ថិតនៅក្រៅសមរភូមិនិងមិនប្រើអាវុធដែលបណ្តាលឲ្យមានការឈឺចាប់ដែលមិនចាំបាច់ ។

លោកសាស្ត្រាចារ្យ រ៉ាត់ន័រ ទទួលស្គាល់ថា តាមពិតមាន

បញ្ហាមួយចំនួនដែលលើកឡើងនៅក្នុងយុទ្ធនាការប្រឆាំងនឹងអង្គការអាល់កេដា ដែលច្បាប់ទម្លាប់មិនអាចដោះស្រាយបាន ប៉ុន្តែលោកមិនជឿសោះថាភាពមានន័យមិនប្រាកដទាំងនេះអាចដោះស្រាយបានដោយការបង្កើតអនុសញ្ញាថ្មី ឬពិធីសារថ្មីឡើយ ។ លោកប្រាប់ឲ្យដឹងមុនថា ការនាំយកក្រុមអាល់កេដាចូលទៅក្នុងក្រុមដែលត្រូវបានការពារដោយច្បាប់មនុស្សធម៌អន្តរជាតិ នោះនឹងធ្វើឲ្យបុព្វហេតុប្រយុទ្ធរបស់អង្គការនេះក្លាយទៅជាស្របច្បាប់មិនខាន ។ ភេរវករមិនគួរទទួលបានអ្វីឲ្យលើសពីការការពារ «គោលការណ៍មនុស្សជាតិចម្បងឡើយ» ។ លោកទាញហេតុផលថា «ដើម្បីពង្រីកច្បាប់សង្គ្រាមឲ្យអនុវត្តចំពោះគ្រប់ស្ថានភាពដែលធ្វើឲ្យអង្គការមួយ...បង្កើតកម្លាំងដើម្បីធ្វើឲ្យមានការស្រពិចស្រពិលមិនដឹងជានៅក្នុងស្ថានភាពណាដែលច្បាប់អនុញ្ញាតឲ្យបុគ្គលសម្លាប់គ្នាទៅវិញទៅមកបាន និងស្ថានភាពបែបណាដែលច្បាប់ហាមប្រាមមិនឲ្យធ្វើដូច្នេះ» ។

វ៉ាត់ន័រ ទទួលស្គាល់ថា ការលំបាកនានាបង្កឡើងដោយជម្លោះមួយដែលក្នុងជម្លោះនោះសហរដ្ឋអាមេរិកធ្វើប្រតិបត្តិការតាមច្បាប់យោធាពោលគឺការបាញ់សម្លាប់ខ្មាំងនៅកន្លែងណាក៏បាននៅក្នុងពិភពលោក ឬក៏ឃុំឃាំងខ្មាំងរហូតដល់«អរិភាព» ឈានដល់ទីបញ្ចប់ ខណៈដែលបដិសេធនូវសិទ្ធិរបស់យុទ្ធជនចំពោះខ្មាំង ។ លោកទាញហេតុផលថា ដំណោះស្រាយគឺមិនមែនបង្កើតពិធីសារថ្មីមួយទេ ប៉ុន្តែគឺការបង្កើតឲ្យមានបទដ្ឋានអន្តរជាតិមួយច្បាស់លាស់ដែលកំណត់ថា អ្វីដែលគេចាត់ចូលជាសមរភូមិ និងអ្វីជាជម្លោះប្រដាប់អាវុធ ។

គ្មានអ្នកណារំពឹងថាដំណើរការដែលចាប់ផ្តើមនៅឯកិច្ចប្រជុំនៅសាកលវិទ្យាល័យហាវើដនឹងនាំដល់ការសម្រេចចិត្តយ៉ាងឆាប់រហ័សយ៉ាងដូច្នេះឡើយ ។ បញ្ហាដែលកើតឡើងដោយការអនុវត្តច្បាប់សង្គ្រាមចំពោះជម្លោះបែបទំនើបគឺមានលក្ខណៈស្មុគស្មាញណាស់ ។ រាល់ការពិភាក្សាទៅលើប្រធានបទនេះតែងតែមានតុល្យភាពរវាងគំនិតនិយម ជាមួយនឹងការអនុវត្តជាក់ស្តែង និងរវាងការសម្រេចចិត្តទុកជាមុន ជាមួយនឹងភាពងាយបត់បែនតាមកាលៈទេសៈជាក់ស្តែង ។ អ្វីដែលទំនងជាកើតមានឡើងគឺថានឹងត្រូវចំណាយពេលវេលាដ៏យូរសម្រាប់ការពិភាក្សានិងការទាញរកហេតុផលអំពី ថាតើត្រូវជ្រើសរើសយកវិធីណាមួយដើម្បីធ្វើឲ្យតម្លៃច្បាប់មនុស្សធម៌អន្តរជាតិនៅក្នុងពិភពលោកបច្ចុប្បន្ននេះមានភាពនិរន្តរ៍ ។

**អាជូនី ទឹកឃីន**

***(សេចក្តីដកស្រង់ពីកម្មវិធីខក្រិដ្ឋសង្គ្រាម***
***ថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៣)***



# ខ្ញុំសូមសន្យានៅចំពោះមុខព្រលឹងរបស់អ្នកដែលបានបាត់បង់ជីវិត

## ចំណាប់អារម្មណ៍របស់ឯកឧត្តម សុខ អាន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារសម្រាប់សហប្រតិបត្តិការជាមួយអ្នកជំនាញច្បាប់បរទេស និងរៀបចំដំណើរការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម

## នៅក្នុងឱកាសពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិទាក់ទងទៅនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរយៈពេលកម្ពុជាប្រជាធិបតេយ្យ

### សាលចតុមុខ
### ភ្នំពេញថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣


ឯកឧត្តម សុខ អាន

ថ្ងៃនេះជាថ្ងៃប្រវត្តិសាស្ត្រសម្រាប់កម្ពុជានិងមនុស្សជាតិទាំងមូល ។ ខ្ញុំឈរយ៉ាងសុភាពរាបសារ នៅទីនេះដោយសារភារកិច្ចរបស់យើងនៅពេលខាងមុខ ពីព្រោះយើងត្រូវធ្វើដំណើរក្នុងភាពជាដៃគូជាមួយអង្គការសហប្រជាជាតិដើម្បីធ្វើការជំនុំជម្រះក្តីអ្នកប្រព្រឹត្តឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មដែលធំជាងគេនៅក្នុងសតវត្សរ៍ទី២០ ដែលនៅក្នុងរយៈពេលនោះជាងមួយភាគបីនៃប្រជាជនកម្ពុជាបានបាត់បង់ជីវិត ។

ខ្ញុំនឹកឃើញយ៉ាងច្បាស់នូវបរិយាកាសដ៏ស្ងៀមស្ងាត់នៅក្នុងខែសីហា ១៩៧៩ នៅពេលដែលសាក្សីម្នាក់ហើយម្នាក់ទៀតបានឡើងមកឆ្លើយបំភ្លឺនិងផ្តល់ភ័ស្តុតាងគួរឲ្យរំជួលចិត្ត ដោយបានលើកឡើងអំពីបទពិសោធន៍ផ្ទាល់ខ្លួន និងធ្វើរបាយការណ៍អំពីការស្រាវជ្រាវដល់ទីកន្លែងរណ្តៅសាកសពរួមនៅទូទាំងប្រទេស និងអំពីបញ្ហាសង្គមដែលប្រជាជនបានរួចរស់ជីវិតគ្រប់ប្រភេទទាំងអស់កំពុងប្រឈមមុខ ។

គឺនៅក្នុងសាលនេះហើយដែលយើងបានធ្វើការជំនុំជម្រះក្តីលើអំពើប្រល័យពូជសាសន៍ជាលើកដំបូងនៅក្នុងពិភពលោក ។ នៅក្នុងឱកាសនោះ លោកប្រធាន ហេង សំរិន បានសម្តែងជំនឿជឿជាក់ថា “តុលាការនៃប្រវត្តិសាស្ត្រ តុលាការនៃសម្បជញ្ញៈមនុស្សជាតិ និងចូលរួមជាមួយប្រជាជនកម្ពុជាដើម្បីកាត់ទោសអំពើប្រល័យពូជសាសន៍នេះ ។”

យើងបានរង់ចាំអស់ពេលជាយូរដើម្បីឲ្យការគ្រោងទុកនេះបានក្លាយជាការពិត ។ ជិតមួយភាគបួននៃសតវត្សរ៍ ឬមួយជំនាន់បានកន្លងផុតទៅនៅក្នុងរយៈកាលនេះភាពស្មុគស្មាញខាងភូមិសាស្ត្រ

នយោបាយ បានរាំងផ្លូវមិនឲ្យមានការទទួលស្គាល់ជាអន្តរជាតិ និងសមស្របចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ។ នៅទីបញ្ចប់ ឥឡូវនេះយើងបានចេញផុតពីរយៈកាលនោះហើយ ។

ប្រាំមួយឆ្នាំមុន នៅក្នុងខែនេះ ប្រទេសកម្ពុជាបានស្នើសុំជំនួយពីលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ខ្ញុំមានកិត្តិយសដោយត្រូវបានសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីតែងតាំងនៅក្នុងខែសីហា ឆ្នាំ១៩៩៩ ឲ្យធ្វើជាប្រធានក្រុមការងារកម្ពុជា និងដឹកនាំគណៈប្រតិភូកម្ពុជានៅក្នុងការចរចាចំនួនប្រាំលើក ។ នៅក្នុងភាគច្រើននៃការចរចាទាំងនោះ ឯកឧត្តម ហេន កូរែល ដែលជាអ្នកចូលរួមចុះហត្ថលេខាជាមួយខ្ញុំនៅក្នុងថ្ងៃនេះ គឺជាអ្នកដឹកនាំក្រុមរបស់អគ្គលេខាធិការដ្ឋានអង្គការសហប្រជា-ជាតិ ។

ខ្ញុំសូមឆ្លៀតឱកាសថ្ងៃនេះ ដើម្បីធ្វើការកោតសរសើរចំពោះការងាររបស់ឯកឧត្តម និងក្រុមរបស់ឯកឧត្តមនៅក្នុងការិយាល័យកិច្ចការច្បាប់ និងនាយកដ្ឋានកិច្ចការនយោបាយ ក៏ដូចជាតំណាងរបស់អង្គការសហប្រជាជាតិប្រចាំនៅទីក្រុងភ្នំពេញនេះ ដែលបានជួយសម្រួលរាល់ដំណើរទស្សនកិច្ចទាំងនេះ ។

ខ្ញុំសូមសម្តែងនូវអំណរគុណអស់ពីដួងចិត្ត ចំពោះបណ្តាប្រទេសសមាជិកអង្គការសហប្រជាជាតិដែលបានរក្សានូវជំនឿជឿជាក់ និងការប្តេជ្ញាចិត្តចំពោះដំណើរការនេះ ហើយប្រសិនបើពុំមានការជឿជាក់និងការប្តេជ្ញាចិត្តនេះ យើងពុំអាចមានពិធីចុះហត្ថលេខាថ្ងៃនេះទេ ។ ក្នុងរយៈកាលបួនឆ្នាំកន្លងមក យើងសូមវាយតម្លៃខ្ពស់ចំពោះការជួយឧបត្ថម្ភនិងគំនិតយោបល់ដែលបានផ្តល់ដល់យើង ជាពិសេសពីសំណាក់ប្រទេសបារាំង ជប៉ុន អូស្ត្រាលី សហព័ន្ធរុស្ស៊ី ឥណ្ឌា ស៊ុយអែដ ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក និងប្រទេសជាសមាជិកអាស៊ានទាំងអស់ ។ នៅក្នុងឆ្នាំ២០០២ ប្រទេសចំនួន២៧បានរួមគ្នាបង្កើតជាក្រុមប្រទេសដែលមានការចាប់អារម្មណ៍ដើម្បីផ្តល់ជូននូវអាណត្តិដែលលោកអគ្គលេខាធិការបានសំណូមពរ ។ ប្រទេសចំនួន៣០ បានគាំទ្រដោយជោគជ័យនូវសេចក្តីសម្រេចចិត្តសម្រាប់ដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិ ។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណចំពោះសមាជិកគណៈប្រតិភូកម្ពុជា ក្រុមការងាររបស់រាជរដ្ឋាភិបាលនិងលេខា-ធិការដ្ឋាន ដែលបានធ្វើការដោយមិនគិតនឿយហត់និងក្រោមកាលៈទេសៈដ៏លំបាកនៅក្នុងរយៈពេលនេះ ។

នៅក្នុងពេលបួនឆ្នាំកន្លងទៅនេះ យើងបានឆ្លងកាត់ការចរចាដ៏លំបាកស្មុគស្មាញ ដោយសារយើងត្រូវធ្វើដំណើរនៅលើផ្លូវដែលពុំទាន់មានផែនទី ។ ទោះបីជាតាមជាក់ស្តែងយើងមានសិទ្ធិគ្រប់គ្រាន់ដើម្បីកាត់សេចក្តីមេដឹកនាំខ្មែរក្រហមនៅក្នុងតុលាការជាតិ ស្របតាមកាតព្វកិច្ចនៅក្រោមអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ក៏ដោយ ក៏យើងស្វែងរកការចូលរួមពីអន្តរជាតិនៅក្នុងដំណើរការជាពិសេសតាមរយៈអង្គការសហប្រជាជាតិ ។ ម្យ៉ាងដោយយើងបានដឹងច្បាស់អំពីភាពទន់ខ្សោយនៅក្នុងប្រព័ន្ធតុលាការរបស់យើង ហើយយើងមានបំណងធ្វើយ៉ាងណាឲ្យការជំនុំជម្រះក្តីនេះបានប្រកបដោយបទដ្ឋានអន្តរជាតិ ។ ម្យ៉ាងទៀត យើងក៏យល់ឃើញដែរថា ដើម្បីឲ្យសមស្របត្រូវតែមានការចូលរួមពីអន្តរជាតិក្នុងការកាត់សេចក្តីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងមូលនេះ ។

ខ្ញុំជឿជាក់ថា ផ្លូវនៅខាងមុខពុំមែនជាការងាយស្រួលទេ ដោយយើងត្រូវឆ្លងពីដំណាក់កាលចរចាទៅដំណាក់កាលអនុវត្ត ។ ពេលនេះកិច្ចព្រមព្រៀងត្រូវបានចុះហត្ថលេខាហើយ យើងនឹងបញ្ជូនកិច្ចព្រមព្រៀងនេះទៅអង្គការនីតិបញ្ញត្តិ ដើម្បីសុំសច្ចាប័នសមស្របតាមច្បាប់ និងនីតិវិធីផ្ទៃក្នុងរបស់យើង ។ យើងរំពឹងថា នៅចុងឆ្នាំនេះ យើងនឹងអាចបង្កើតអង្គជំនុំជម្រះវិសាមញ្ញដែលនឹងមានការទទួលខុសត្រូវយ៉ាងធំធេង ក្នុងការជំនុំជម្រះក្តីឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុតប្រឆាំងនឹងច្បាប់មនុស្សធម៌អន្តរជាតិនិងច្បាប់ក្នុងស្រុករបស់កម្ពុជា ។

យើងសូមអំពាវនាវដល់បណ្តាប្រទេសទាំងអស់ដែលបានជួយផ្តល់ការលើកទឹកចិត្តដល់យើងតាំងពីដើមទីរហូតមកដល់ពេលនេះ សូមឲ្យប្រែក្លាយមនោសញ្ចេតនានេះទៅជាការគាំទ្រផ្នែកសម្ភារ រួមទាំងផ្តល់វិភាគទានដល់មូលនិធិស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិ តែងតាំងចៅក្រម និងបុគ្គលិកកម្រិតខ្ពស់ ព្រមទាំងផ្តល់នូវវិភាគទានផ្សេងៗទៀត ។ យើងត្រូវធ្វើយ៉ាងណាដើម្បីអាចបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានឆាប់បំផុត ហើយ

សមស្របទៅតាមបទដ្ឋានអន្តរជាតិ ។

សាលសន្និសីទចតុមុខ ដែលជាមោទកភាពនៃស្ថាបត្យកម្មរបស់យើង និងជាមុខមាត់របស់វប្បធម៌កម្ពុជា ទំនងជានឹងមានតួនាទីជាសាក្សីដ៏ស្ងៀមស្ងាត់ចំពោះការឈឺចាប់របស់ប្រជាជនយើង ដោយសារក្តីនៃអង្គជំនុំជម្រះវិសាមញ្ញអាចនឹងប្រព្រឹត្តទៅនៅទីនេះ ។ ហើយនៅពេលនោះ យើងសង្ឃឹមយ៉ាងមុតមាំថា លទ្ធផលនឹងត្រូវបានទទួលស្គាល់និងគោរពនៅទូទាំងពិភពលោក ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមសន្យានៅចំពោះមុខព្រលឹងរបស់អ្នកដែលបានបាត់បង់ជីវិតទៅចំពោះមុខបងប្អូនសាច់ញាតិ និងមិត្តភក្តិរបស់អ្នកទាំងនោះ និងចំពោះមុខប្រជាជនទាំងអស់ដែលបានទទួលរងទុក្ខវេទនានៅក្នុងរយៈពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃ ថានឹងបន្តការខិតខំប្រឹងប្រែងរបស់យើងរហូតសម្រេចបានការកាត់ទោសតាមផ្លូវច្បាប់ និងមានលក្ខណៈប្រវត្តិសាស្ត្រគួរជាទីពេញចិត្តនូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ។

**សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់**

# តើយើងបានធ្វើអ្វីខ្លះហើយដើម្បីបញ្ឈប់អំពើយង់ឃ្នង

## សេចក្តីថ្លែងការណ៍របស់លោក ហាន គូរ៉េល អគ្គលេខាធិការរងអង្គការសហប្រជាជាតិ

## ផ្នែកកិច្ចការច្បាប់ ទីប្រឹក្សាច្បាប់នៃអង្គការសហប្រជាជាតិ

***ក្នុងឱកាសចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាស្តីពីការកាត់សេចក្តីតាមច្បាប់កម្ពុជាចំពោះបទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ***

***ទេសរដ្ឋមន្ត្រី សុខ អាន***

***ឯកឧត្តម្ក លោកជំទាវ លោកនិងលោកស្រី***

ខ្ញុំមានកិត្តិយសដ៏ឧត្តុង្គឧត្តម តាងនាមឲ្យតំណាងអង្គការសហប្រជាជាតិក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការកាត់សេចក្តីតាមច្បាប់កម្ពុជាចំពោះបទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ។

កិច្ចការនេះជាបំណងរបស់ប្រជាជនកម្ពុជា ដើម្បីឈានទៅសម្រេចបានការស្វែងរកយុត្តិធម៌ ការផ្សះផ្សាជាតិ ស្ថិរភាព សន្តិភាព និងសន្តិសុខ ។ ក៏ប៉ុន្តែ ប្រសិនបើការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ជាការបញ្ចប់នូវដំណាក់កាលមួយក្នុងការខិតខំប្រឹងប្រែងនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោសដើម្បីរកយុត្តិធម៌មែននោះ វាក៏ជាការចាប់ផ្តើមនូវជំហានថ្មីមួយទៀត ។ ពីព្រោះយើងនៅមានកិច្ចការជាច្រើនទៀតដែលត្រូវធ្វើមុន អាចបង្កើតឡើងនូវអង្គជំនុំជម្រះវិសាមញ្ញនិងស្ថាប័នពាក់ព័ន្ធរបស់ខ្លួនហើយនិងអាចចាប់ផ្តើមធ្វើការស៊ើបអង្កេត ការចោទប្រកាន់និងជំនុំជម្រះ ។ ប៉ុន្តែប្រសិនបើមានឆន្ទៈនយោបាយហើយនោះ យើងនឹងអាចសម្រេចកិច្ចការទាំងនោះបានយ៉ាងឆាប់រហ័ស ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី សុខ អាន គឺជាសមភាគីរបស់យើងខ្ញុំក្នុងការចរចានេះ ។ ខ្ញុំសូមថ្លែងអំណរគុណដល់ឯកឧត្តម និងក្រុមការងាររបស់ឯកឧត្តមចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អនេះ ។ ថ្វីបើការចរចាមានលក្ខណៈមិនងាយស្រួលក្តី ក៏គណៈប្រតិភូទាំងពីរបានធ្វើការជាមួយគ្នាយ៉ាងល្អ ព្រមទាំងគោរពគ្នាទៅវិញទៅមក ។ ខ្ញុំសង្ឃឹមថា កិច្ចសហប្រតិបត្តិការក្នុងកិច្ចការនេះនឹងនៅតែបន្តក្នុងជំហានថ្មីតទៅទៀត ។

ឯកឧត្តម សុខ អាន បានលើកឡើងរួចមកហើយនូវកិច្ចការដែលរាជរដ្ឋាភិបាលកម្ពុជាត្រូវអនុវត្ត ។

អង្គការសហប្រជាជាតិក៏មានភារកិច្ចត្រូវធ្វើច្រើនដែរ ។ ជាបឋម លោកអគ្គលេខាធិការ ត្រូវធានាឲ្យមាននូវវិភាគទានស្ម័គ្រចិត្តពីប្រទេសនានាសម្រាប់ចំណាយលើជំនួយការដែលអង្គការសហប្រជាជាតិត្រូវផ្តល់ជូនតាមកិច្ចព្រមព្រៀង ។ ដើម្បីសម្រេចកិច្ចការនេះបាន លោកអគ្គលេខាធិការនឹងអំពាវនាវទៅដល់ប្រទេសនានាសុំឲ្យប្រទេសទាំងនោះឆ្លើយតបមកលោកវិញ

ប្រសិនបើពួកគេស្ម័គ្រចិត្តចូលរួមផ្តល់វិភាគទានជាថវិកា បុគ្គលិក និងសេវាកម្ម ដើម្បីគាំទ្រដល់អង្គជំនុំជម្រះវិសាមញ្ញ និងស្ថាប័នពាក់ព័ន្ធរបស់ខ្លួន ។ លោកក៏នឹងសូមឲ្យប្រទេសទាំងនោះបញ្ជាក់ផងដែរពីទំហំនិងវិសាលភាពនៃវិភាគទានដែលគេនឹងផ្តល់ ។

ឆ្លៀតឱកាសនៅទីនេះ ពេលនេះ ខ្ញុំសូមជំរុញឲ្យសហគមន៍អន្តរជាតិមេត្តាឆ្លើយតបយ៉ាងរហ័សនិងជាវិជ្ជមានចំពោះការអំពាវនាវនេះ ។

ទោះបីជាមានការងារជាច្រើនដែលអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាត្រូវធ្វើរៀងៗខ្លួន មុនពេលមានកិច្ចព្រមព្រៀងជាធរមានក៏ដោយ ក៏មានកិច្ចការជាច្រើនទៀតដែលពួកគេត្រូវធ្វើការរួមគ្នា ។

ជាពិសេសកិច្ចព្រមព្រៀងដែលឯកឧត្តមទេសរដ្ឋមន្ត្រី សុខ អាន និងរូបខ្ញុំផ្ទាល់ ទើបនឹងចុះហត្ថលេខា ចែងពីការអនុម័តលើកិច្ចព្រមព្រៀងបន្ថែមរវាងអង្គការសហប្រជាជាតិ និងរាជ-រដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំឲ្យមានសុវត្ថិភាពនិងសន្តិសុខជាដើម និងស្តីពីសម្ភារប្រើប្រាស់ អគារ និងសេវាចាំបាច់មួយចំនួនសម្រាប់ដំណើរការអង្គជំនុំជម្រះវិសាមញ្ញនិងស្ថាប័នពាក់ព័ន្ធរបស់ខ្លួន ។ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាត្រូវការចរចានិងបញ្ចប់ឲ្យបាននូវកិច្ចព្រមព្រៀងទាំងនេះ មុនពេលអាចចាប់ផ្តើមដំណើរការអង្គជំនុំជម្រះវិសាមញ្ញនិងស្ថាប័នពាក់ព័ន្ធរបស់ខ្លួន ។ អង្គការសហប្រជាជាតិក៏នឹងត្រូវពិភាក្សាជាមួយរាជរដ្ឋាភិបាលកម្ពុជាអំពីតម្រូវការបុគ្គលិកសម្រាប់អង្គជំនុំជម្រះ



ហេន កូរ៉េល

វិសាមញ្ញ និងស្ថាប័នពាក់ព័ន្ធរបស់ខ្លួន ព្រមទាំងតម្រូវការមួយចំនួនដូចជា សម្ភារ គ្រឿងសង្ហារិម គ្រឿងបរិក្ខារ សម្ភារផ្គត់ផ្គង់ និងតម្រូវការផ្សេងៗទៀតសម្រាប់ដំណើរការការងារ ។

លោកអគ្គលេខាធិការនឹងចាប់បញ្ជូនក្រុមបេសកកម្មផែនការ មករាជធានីភ្នំពេញនាពេលឆាប់ៗនេះដើម្បីសម្រេចកិច្ចការនេះ ។ លទ្ធផលនៃបេសកកម្មនេះនឹងប្រើប្រាស់ជាមូលដ្ឋានសម្រាប់អំពាវនាវសុំវិភាគទានស្ម័គ្រចិត្តដែលលោកអគ្គលេខាធិការនឹងផ្ញើសេចក្តីអំពាវនាវនោះទៅដល់ប្រទេសនានា ។

ក្នុងកិច្ចការនេះក៏ដូចជាក្នុងកិច្ចការដទៃទៀត លោកអគ្គលេខាធិការបានយល់ដឹងយ៉ាងច្បាស់នូវតម្រូវការដើម្បីដំណើរការឲ្យបានឆាប់រហ័ស ។ បើមិនដូច្នេះទេដូចដែលមហាសន្និបាតអគ្គការសហប្រជាជាតិបានគូសបញ្ជាក់រួចហើយថា ប្រហែលនឹងអាចបាត់បង់ឱកាសកាត់ទោសជនដែលទទួលខុសត្រូវចំពោះអំពើរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជានិងអន្តរជាតិក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។



ឯកឧត្តម សុខ អាន

អាស្រ័យហេតុនេះ អគ្គលេខាធិការបានប្តេជ្ញាអនុវត្តអស់លទ្ធភាពដើម្បីឲ្យកិច្ចព្រមព្រៀងចូលជាធរមានក្នុងពេលឆាប់ៗនេះ ។ ខ្ញុំយល់ថា សំខាន់គឺត្រូវពន្យល់លម្អិតពីវិធានការទាំងឡាយដែលត្រូវចាត់នៅក្នុងដំណាក់កាលថ្មី ដើម្បីឲ្យបានទាំងអស់គ្នា ។

ទោះបីយ៉ាងណាក៏ដោយ ការផ្តោតយកចិត្តទុកដាក់នាពេលនេះ មិនគួរតែលើបញ្ហាទាំងនេះទេ ទោះបីជាសំខាន់យ៉ាងណាក៏ដោយ តែក៏ជាពេលដែលត្រូវគិតផងដែរថា តើត្រូវធ្វើដូចម្តេច ។ ពិធីនេះមានការចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ អស់លោកនិងលោកស្រីជាច្រើន ។ ក្រៅពីអស់លោកដែលបានចូលរួមជាកិត្តិយសនិងមានវត្តមាននៅទីនេះ ក៏មានមនុស្សជាច្រើនទៀតទាំងក្នុងនិងក្រៅប្រទេសកម្ពុជា កំពុងតាមដានព្រឹត្តិការណ៍នេះតាមរយៈប្រព័ន្ធផ្សព្វផ្សាយពត៌មានផងដែរ ។ ក្នុងខណៈនេះដែរមានប្រជាពលរដ្ឋខ្លះប្រហែលជាកំពុងនឹកឃើញឡើងវិញនូវអតីតកាលដ៏ឈឺចាប់ដែលបានបន្សល់ទុកនូវភាពសោកសៅ ហើយខ្លះទៀតអាចចោទឡើងជាសំណួរថា «តើយើងមិនបានដឹងទេឬ? តើពេលនោះយើងមិនអាចរាំងស្កាត់កុំឲ្យបញ្ហាទាំងនេះកើតឡើងបានទេឬ?» «តើយើងបានធ្វើអ្វីខ្លះហើយដើម្បីបញ្ឈប់អំពើយង់ឃ្នងទាំងនេះ?

ទោះជាយ៉ាងណាក៏ដោយ ពេលនេះជាពេលសម្រាប់យើងទាំងអស់គ្នាចងចាំនូវភារកិច្ចដែលត្រូវអនុវត្តនិងដោះស្រាយឲ្យអស់ពីលទ្ធភាពចំពោះនិរទណ្ឌភាពដែលបានបន្តឡើង និងនៅតែបន្តធ្វើឲ្យមនុស្សជាតិរងនូវការឈឺចាប់យ៉ាងខ្លាំង ។

ប្រជាជនកម្ពុជាបានរង់ចាំជាយូរមកហើយ ចង់ឃើញការកាត់ទោសដល់មេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យនិងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឃោរឃៅក្នុងអំឡុងពេលនោះក្នុងប្រវត្តិសាស្ត្រជាតិរបស់ខ្លួន ។ ការរង់ចាំរបស់ពួកគេមិនទាន់ដល់ទីបញ្ចប់នៅឡើយទេ ប៉ុន្តែសង្ឃឹមថា វាក៏នឹងជិតដល់ទីបញ្ចប់ផងដែរ ។

# ផលប្រយោជន៍ត្រីភាគណៈ

## តុលាការអន្តរជាតិ តុលាការព្រហ្មទណ្ឌអន្តរជាតិ និង "តុលាការខ្មែរក្រហម"

តុលាការអន្តរជាតិ តុលាការព្រហ្មទណ្ឌអន្តរជាតិ និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាអង្គតុលាការបី មានលក្ខណៈខុសគ្នាទាំងយុត្តិការលើរូបរឿងក្តី អាយុកាល ឬរយៈពេលនៃការបង្កើត សមាសភាព ការគ្រប់គ្រង និងគោលបំណងនៃការបង្កើត ។

អត្ថបទនេះគឺចង់បង្ហាញអំពីភាពខុសគ្នារវាងស្ថាប័នយុត្តិធម៌ទាំងបីដែលមានលក្ខណៈអន្តរជាតិសុទ្ធសាធ និងជាលក្ខណៈចម្រុះ និងបង្ហាញថាតើតុលាការនេះមានសារសំខាន់យ៉ាងដូចម្តេចខ្លះចំពោះប្រទេសកម្ពុជានាពេលអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល ។

តុលាការអន្តរជាតិ ដែលហៅម្យ៉ាងទៀតថា "តុលាការពិភពលោក" គឺជាអង្គតុលាការចំណុះឲ្យអង្គការសហប្រជាជាតិ ។ តុលាការនេះបង្កើតឡើងនៅឆ្នាំ១៩៤៥ តាមធម្មនុញ្ញអង្គការសហប្រជាជាតិ បន្ទាប់ពីតុលាការអចិន្ត្រៃយ៍អន្តរជាតិចំណុះឲ្យសម្ព័ន្ធប្រជាជាតិ ។ តុលាការអន្តរជាតិប្រព្រឹត្តទៅតាមលក្ខន្តិកៈរបស់ខ្លួនផ្ទាល់ ដែលជាផ្នែកដ៏សំខាន់មួយរបស់ធម្មនុញ្ញអង្គការសហប្រជាជាតិ ។ ការងារចម្បងរបស់តុលាការនេះគឺត្រូវសម្រេចទៅលើរឿងក្តីនានារវាងរដ្ឋនិងរដ្ឋ ។ បុគ្គលឯកជនមិនអាចប្តឹងទៅតុលាការនេះបានទេ ។ គ្រប់សមាជិករបស់អង្គការសហប្រជាជាតិសុទ្ធតែជាភាគីនៃលក្ខន្តិកៈច្បាប់តុលាការពិភពលោក រួមទាំងរដ្ឋមិនមែនជាសមាជិកពីរទៀត គឺប្រទេសស្វីស និងប្រទេសណូរូ ។ ប្រទេសដែលមិនមែនជាភាគីនៃលក្ខន្តិកៈនេះអាចប្រើតុលាការនេះ ប្រសិនបើប្រទេសនោះទទួលយកនូវកាតព្វកិច្ចរបស់សមាជិកណាមួយនៃអង្គការសហប្រជាជាតិ ទោះជាក្នុងករណីទូទៅ ឬករណីដោយឡែកណាមួយក៏ដោយ ។

តាមមាត្រា៩៤ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ វិវាទនានាត្រូវយកមកប្តឹងចំពោះតុលាការនេះតាមវិធីពីរយ៉ាង ។ វិធីទីមួយគឺដោយកិច្ចព្រមព្រៀងពិសេស ដែលក្រោមកិច្ចព្រមព្រៀងនេះភាគីទាំងអស់យល់ស្របគ្នាក្នុងការដាក់ជូនសំណុំរឿងនេះទៅតុលាការ ។ វិធីទីពីរ គឺតាមរយៈការអនុវត្តជាឯកតោភាគីរបស់ភាគីម្ខាងដែលមានវិវាទ ។ ឧទាហរណ៍ថា ប្រទេសមួយអាចអះអាងថាបច្ចាមិត្តរបស់ខ្លួនមានកាតព្វកិច្ចតាមរយៈបទបញ្ញត្តិចែងនៅក្នុងសន្ធិសញ្ញាណាមួយឲ្យទទួលយកនូវអំណាចរបស់តុលាការក្នុងករណីមានវិវាទកើតឡើង ។ បទបញ្ញត្តិមួយនៅក្នុងលក្ខន្តិកៈតុលាការនេះ ក៏អនុញ្ញាតផងដែរ (ប៉ុន្តែមិនតម្រូវ) ឲ្យប្រទេសដែលជាភាគីលក្ខន្តិកៈនេះប្រកាសជាមុនអំពីការទទួលយករបស់ខ្លួននូវយុត្តាធិការដោយបង្ខំរបស់តុលាការនៅក្នុងប្រភេទនានានៃរឿងចម្រូងចម្រាស់ជាលក្ខណៈអន្តរជាតិ ។ ប្រសិនបើភាគីទាំងពីរដែលមានវិវាទធ្វើការប្រកាសបែបនេះ ហើយប្រសិនបើជម្លោះរវាងប្រទេសទាំងពីរស្ថិតនៅក្នុងអ្វីដែលបានចែងនៅក្នុងសេចក្តីប្រកាសទាំងនោះ ពេលនោះភាគីណាមួយក៏អាចដាក់បណ្តឹងមកតុលាការអន្តរជាតិបានដែរ ។ នៅខែតុលា ឆ្នាំ១៩៨៥ លោកប្រធានាធិបតី រ៉ូណាល់ រីហ្គែន បានបញ្ឈប់សហរដ្ឋអាមេរិកមិនឲ្យអនុវត្តសាលក្រមរបស់តុលាការពិភពលោកដែលជានយោបាយមានលក្ខណៈស្វ័យប្រវត្តិមានពីយូរយារណាស់មកហើយ ។ ទង្វើនេះធ្វើឲ្យមានតែប្រទេស៤៣តែប៉ុណ្ណោះ ដែលទទួលយកយុត្តាធិការដោយបង្ខំរបស់តុលាការ ។ ចំណាត់ការរបស់សហរដ្ឋអាមេរិកបានធ្វើឲ្យតុលាការកាន់តែចុះខ្សោយឡើង ទន្ទឹមពេលដែលតុលាការនេះមានលក្ខណៈខ្សោយរួចស្រេចទៅហើយដោយសារប្រទេសមហាអំណាចមួយចំនួនបដិសេធមិនព្រមទទួលយកអំណាចរបស់តុលាការនេះ មានដូចជា សហភាពសូវៀត ចិន បារាំង អាល្លឺម៉ង់ខាងលិច (ឥឡូវជាសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់) និងប្រទេសអ៊ីតាលី ។

តុលាការចេញសាលក្រមយោងតាមគោលការណ៍ទូទៅនៃច្បាប់អន្តរជាតិទទួលស្គាល់ដោយអារ្យប្រទេសនានា ក៏ដូចជាទំនៀមទម្លាប់អន្តរជាតិ វិធាននៃសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ

ដែលទទួលស្គាល់ដោយភាគីដែលជាប់វិវាទ ។ តុលាការនេះក៏យោងទៅតាមសេចក្តីសម្រេចរបស់តុលាការ និងសំណេររបស់អ្នកជំនាញការច្បាប់អន្តរជាតិផងដែរ ។ សាលក្រមរបស់តុលាការដែលត្រូវតែមានហេតុផលនោះ មានតម្លៃគតិយុត្តិបិទផ្លូវតវ៉ា ពេលគ្មានការប្តឹងឧទ្ធរណ៍ឡើយ ។ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិមានអំណាចចាត់វិធានការឲ្យអនុវត្តសាលក្រមចេញដោយតុលាការនេះ ប្រសិនបើភាគីជាប់វិវាទខកខានមិនអនុវត្តដោយខ្លួនឯងទេនោះ ។ ប៉ុន្តែតាមការជាក់ស្តែងតុលាការពិភពលោកមានអំណាចតិចតួចណាស់ក្នុងការចាប់បង្ខំឲ្យអនុវត្តសាលក្រមដែលខ្លួនសម្រេច ។ ឧទាហរណ៍នៅឆ្នាំ១៩៨០ នៅពេលតុលាការបង្គាប់ឲ្យប្រទេសអ៊ីរ៉ង់ដោះលែងចំណាប់ខ្មាំងជនជាតិអាមេរិកចំនួន៥៣នាក់ អ៊ីរ៉ង់មិនបានអនុវត្តនូវសាលក្រមតុលាការឡើយ ។

ប៉ុន្តែក្នុងរឿងវិវាទរវាងប្រទេសកម្ពុជា និងប្រទេសថៃទៅលើសិទ្ធិ កម្មសិទ្ធិលើប្រាសាទព្រះវិហារអំណាចសាលក្រមរបស់តុលាការអន្តរជាតិពិតជាមានប្រសិទ្ធភាព ។ ដំណើរការប្តឹងផ្តល់ទាក់ទងនឹងករណីប្រាសាទព្រះវិហាររវាងកម្ពុជានិងប្រទេសថៃចាប់ផ្តើមនៅថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៥៩ តាមរយៈសំណុំរឿងដែលរដ្ឋាភិបាលកម្ពុជាដាក់ជូនតុលាការអន្តរជាតិ ។ រដ្ឋាភិបាលថៃបានប្តឹងជំទាស់ ប៉ុន្តែតុលាការអន្តរជាតិដោយយោងតាមសាលក្រមចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៦១ បញ្ជាក់ថាតុលាការនេះមានយុត្តាធិការលើរឿងវិវាទនេះ ។ តាមស្មារតីនៃសាលក្រមរបស់តុលាការ ពោលគឺសំឡេងឆ្នោត៩ទល់នឹង៣ បានកំណត់ថាប្រាសាទព្រះវិហារស្ថិតនៅក្នុងទឹកដីដែលជាអធិបតេយ្យភាពរបស់កម្ពុជា ដូចនេះថៃត្រូវមានកាតព្វកិច្ចដកកងទ័ពនិងនគរបាល ឬឆ្មាំសន្តិសុខផ្សេងៗទៀតដែលឈរជើងនៅប្រាសាទព្រះវិហារ ឬដែលឈរជើងនៅម្តុំប្រាសាទដែលស្ថិតក្នុងទឹកដីកម្ពុជា ។ តាមរយៈសំឡេងឆ្នោត៧សំឡេងទល់នឹង៥សំឡេង តុលាការកំណត់ថា ប្រទេសថៃមានកាតព្វកិច្ចជួសជុលឲ្យដូចដើមឡើងវិញនូវចម្លាក់ គោលថ្មចារិក បំណែកប្រាសាទ របនាបទថ្មខ្សាច់ (ភក់) និងកុម្ភកាភ័ណ្ឌ ដែលអាចនឹងយកចេញពីប្រាសាទ ឬទីជុំវិញប្រាសាទដោយអាជ្ញាធរថៃ ចាប់តាំងពីខ្លួនចូលមកកាន់កាប់ប្រាសាទនេះនៅឆ្នាំ១៩៥៤ ។

ក្រៅពីការកាត់សេចក្តីរឿងវិវាទរវាងរដ្ឋនិងរដ្ឋ តុលាការអន្តរជាតិផ្តល់នូវប្រឹក្សាពាក់ព័ន្ធផ្លូវច្បាប់ជូនចំពោះមហាសន្និបាតអង្គការសហប្រជាជាតិ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងភ្នាក់ងារជំនាញៗផ្សេងៗទៀតដែលទទួលសិទ្ធិប្រទានពីមហាសន្និបាតអង្គការសហប្រជាជាតិក្នុងការសុំមតិយោបល់បែបនេះ ។ ឧទាហរណ៍ដូចជាសាលក្រមរបស់តុលាការនេះនៅឆ្នាំ១៩៦២ ដែលបង្គាប់ថា ចំណាយលើការថែរក្សាសន្តិភាពនៅក្នុងសាធារណរដ្ឋកុងហ្គោ (សព្វថ្ងៃហៅថា សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ) និងនៅមជ្ឈិមបូព៌ាគឺជា "ចំណាយរបស់អង្គការនេះ" ដែលបង់វិភាគទានដោយរដ្ឋជាសមាជិកតាមការបែងចែករបស់មហាសន្និបាតអង្គការសហប្រជាជាតិ ។

តុលាការអន្តរជាតិមានចៅក្រម១៥រូប ។ ចៅក្រមមួយរូបៗត្រូវជ្រើសតាំងដោយមតិភាគច្រើន ដាច់ខាតចេញពីក្រុមប្រឹក្សាសន្តិសុខនិងមហាសន្និបាតអង្គការសហប្រជាជាតិដែលបោះឆ្នោតដោយឯករាជ្យឲ្យគ្នាទៅវិញទៅមក ។ ចៅក្រមទទួលអាណត្តិ៩ឆ្នាំ ហើយអាចឈរឈ្មោះឲ្យគេជ្រើសរើសសាជាថ្មី ។ ចៅក្រមពីររូបមិនអាចមកពីប្រទេសតែមួយបានទេ ។ ចៅក្រមអាចដកចេញពីតំណែងបានតែក្នុងករណីមានសំឡេងឆ្នោតគាំទ្រជាឯកច្ឆន្ទពីចៅក្រមផ្សេងៗទៀតប៉ុណ្ណោះ ។ ចៅក្រមទាំងនោះមិនត្រូវបានជ្រើសតាំងឲ្យមកតំណាងប្រទេសរបស់គេនោះទេ ប៉ុន្តែជ្រើសរើសឡើងដោយយកចំណេះដឹងខាងច្បាប់អន្តរជាតិជាមូលដ្ឋាន ។ កូរ៉ុមរបស់តុលាការគឺវត្តមាននៃចៅក្រមចំនួន៩រូប ។ បញ្ហានានា នឹងត្រូវសម្រេចដោយមតិភាគច្រើននៃចៅក្រមដែលមានវត្តមាន ។ តុលាការជ្រើសតាំងមន្ត្រីរបស់ខ្លួននិងតែងតាំងក្រឡាបញ្ជី ព្រមទាំងមន្ត្រីផ្សេងៗទៀត ។ ការិយាល័យធំរបស់តុលាការនេះមានមូលដ្ឋាននៅទីក្រុងឡាអេ ប្រទេសហូល្លង់ ។

៥៧ឆ្នាំក្រោយពីការបង្កើតតុលាការអន្តរជាតិ ក៏មានការបង្កើតឡើងនូវតុលាការអន្តរជាតិអចិន្ត្រៃយ៍មួយមានឈ្មោះថាតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ លក្ខន្តិកៈច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិចូលជាធរមាននាថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០២ ។ ការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ គឺដោយហេតុ

ថាសតវត្សរ៍កន្លងទៅមានកើតឡើងនូវអំពើឃោរឃៅបំផុតនៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ។ នៅក្នុងករណីច្រើនពេកហើយដែលបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តឡើងដោយគ្មានការផ្តន្ទាទោស ដែលប្រការនេះបានជំរុញឲ្យអ្នកដទៃទៀតរំលោភមកលើច្បាប់មនុស្សធម៌ ។ កម្ពុជាជាភាគីហត្ថលេខីមួយក្នុងចំណោមភាគីហត្ថលេខី ៦០ ប្រទេសដែលធ្វើឲ្យលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិមានអានុភាពគតិយុត្តិ ។

ប្រទេសកម្ពុជានិងប្រទេសហត្ថលេខីផ្សេងៗទៀត ត្រូវការជាចាំបាច់តុលាការព្រហ្មទណ្ឌអន្តរជាតិដើម្បីជួយបញ្ចប់និទណ្ឌភាពនិងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិដែលកើតឡើងនៅក្នុងសតវត្សរ៍កន្លងមក ។

កិច្ចខិតខំប្រឹងប្រែងបង្កើតនូវតុលាការព្រហ្មទណ្ឌអន្តរជាតិមានសន្ទុះកាន់តែខ្លាំងឡើងនៅពេលអនុម័តនូវច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម នៅឆ្នាំ១៩៩៨ ។

តុលាការព្រហ្មទណ្ឌអន្តរជាតិមានមូលដ្ឋាននៅទីក្រុងឡាអេ ប្រទេសហុល្លង់ ។ ប្រទេសដែលផ្តល់សច្ចាប័នជាអ្នកមានសិទ្ធិជ្រើសរើសបុគ្គលិកតុលាការ ដែលមានចៅក្រម១៨រូបនិងព្រះរាជអាជ្ញាមួយរូប ។ តុលាការនេះមានដែនសមត្ថកិច្ចកាត់សេចក្តីបុគ្គលទាំងឡាយ ដែលបានប្រព្រឹត្តបទឧក្រិដ្ឋកម្មគួរឲ្យរន្ធត់ដែលមានដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ។

យុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិជួយបំពេញគ្នាទៅវិញទៅមកជាមួយនឹងតុលាការជាតិ មានន័យថាតុលាការព្រហ្មទណ្ឌអន្តរជាតិនឹងចូលមកអនុវត្តដែនសមត្ថកិច្ចរបស់ខ្លួននៅពេលដែលប្រទេសនានាគ្មានលទ្ធភាព ឬគ្មានឆន្ទៈចង់បើកការស៊ើបអង្កេត ឬកាត់សេចក្តីលើឧក្រិដ្ឋកម្មទាំងនោះ ។ តុលាការនេះធានាការពារមិនឲ្យមានការរំលោភនិងមានបំណងលើកកម្ពស់សិទ្ធិជនរងគ្រោះនិងយុត្តិធម៌សមភេទក្រោមច្បាប់អន្តរជាតិ ។

ប្រទេសនានាមានអារម្មណ៍ថាជាការសំខាន់គឺត្រូវបញ្ចូលឧក្រិដ្ឋកម្មនៃការឈ្លានពាននៅក្នុងលក្ខន្តិកៈច្បាប់ទីក្រុងរ៉ូម ប៉ុន្តែមិនអាចយល់ស្របគ្នាទៅលើបញ្ហានៃការកំណត់និយមន័យ ។

និយមន័យនៃពាក្យ «ឧក្រិដ្ឋកម្មនៃការឈ្លានពាន» គេនៅតែបន្តចរចានៅគណៈកម្មាធិការរៀបចំរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ការចរចាជួបការលំបាក ប៉ុន្តែមានការរីកចម្រើនមួយចំនួនហើយ ។ ដោយសន្មតថា នៅពេលកិច្ចព្រមព្រៀងនេះត្រូវបានសម្រេចនិយមន័យនេះនឹងត្រូវបញ្ចូលទៅក្នុងលក្ខន្តិកៈច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ នៅពេលដែលលក្ខន្តិកៈច្បាប់នេះត្រូវបានលើកមកពិនិត្យសាឡើងវិញក្នុងរយៈពេល៧ឆ្នាំម្តង ។

ប្រសិនបើរឿងក្តីមួយកំពុងតែត្រូវបានយកមកគិតពិចារណាដោយប្រទេសណាមួយដែលមានយុត្តាធិការទៅលើរឿងក្តីនោះ ពេលនោះតុលាការព្រហ្មទណ្ឌអន្តរជាតិមិនអាចអនុវត្តយុត្តាធិការរបស់ខ្លួនឡើយ លើកលែងតែប្រទេសនោះគ្មានឆន្ទៈឬគ្មានលទ្ធភាពធ្វើការស៊ើបអង្កេត ឬចោទប្រកាន់ពិតប្រាកដ ។

គេអាចកំណត់ថាប្រទេសមួយថា «គ្មានឆន្ទៈ» បាននៅពេលណាប្រទេសនេះការពារបុគ្គលណាម្នាក់មិនឲ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលបុគ្គលនោះបានប្រព្រឹត្តស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ប្រទេសមួយ «គ្មានលទ្ធភាព» នៅពេលដែលប្រព័ន្ធច្បាប់របស់ប្រទេសនេះខ្សោយមិនអាចប្រតិបត្តិដោយត្រឹមត្រូវ ។

ដំណើរការជំនុំជម្រះក្តីចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិអាចផ្តួចផ្តើមឡើងដោយភាគីរដ្ឋ ព្រះរាជអាជ្ញា ឬក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ។

លក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិចែងអំពីលក្ខខណ្ឌដាក់កំហិតមួយចំនួនសម្រាប់ពេលដែលយុត្តាធិការត្រូវគេយកមកអនុវត្ត ដូចជាការបំពេញគ្នាទៅវិញទៅមក និងតម្រូវការចងភ្ជាប់ដោយលក្ខណៈដែនដី ឬ សញ្ជាតិ ។

យុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិផ្អែកលើ «ភាពបំពេញគ្នាទៅវិញទៅមក» ដែលផ្តល់ឱកាសដំបូងដល់តុលាការជាតិក្នុងការស៊ើបអង្កេតនិងចោទប្រកាន់ ។

តុលាការព្រហ្មទណ្ឌអន្តរជាតិកើតចេញពីសន្ធិសញ្ញាពហុភាគី ចំណែកឯតុលាការនៅរ៉្វាន់ដា និងយូហ្គោស្លាវីបង្កើតឡើងដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ។ តុលាការទាំងពីរនេះបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងសភាពការណ៍ជាក់ស្តែង ហើយមានអាយុកាលខ្លី ។ ចំណែកឯតុលាការព្រហ្មទណ្ឌ

អន្តរជាតិគឺជាតុលាការអន្តរជាតិដែលមានលក្ខណៈអចិន្ត្រៃយ៍ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិមានលក្ខណៈឯករាជ្យមិនស្ថិតនៅក្រោមចំណុះអង្គការសហប្រជាជាតិឡើយ ។

តុលាការអន្តរជាតិគ្មានយុត្តាធិការលើករណីព្រហ្មទណ្ឌក្នុងការកាត់សេចក្តីបុគ្គលទេ ។ តុលាការនេះជាតុលាការរដ្ឋប្បវេណីដែលដោះស្រាយវិវាទរវាងរដ្ឋនិងរដ្ឋ ។

ដោយសារតុលាការព្រហ្មទណ្ឌអន្តរជាតិពុំមានយុត្តាធិការប្រតិសកម្ម ដូចនេះតុលាការនេះមិនអាចអនុវត្តយុត្តាធិការរបស់ខ្លួនទៅលើបទឧក្រិដ្ឋទាំងឡាយណាដែលប្រព្រឹត្តឡើងនៅមុនថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០២នោះឡើយ ។ យ៉ាងណាមិញ វាក៏មិនអាចអនុវត្តទៅលើករណីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយមេដឹកនាំកម្ពុជាប្រជាធិបតេយ្យនៅចន្លោះឆ្នាំ១៩៧៥ - ១៩៧៩ នោះដែរ ។

ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិអាចបញ្ជូនករណីបទល្មើសទៅកាន់តុលាការព្រហ្មទណ្ឌអន្តរជាតិ ទោះជាប្រទេសនោះជាភាគីហត្ថលេខីនៃលក្ខន្តិកៈច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ឬមិនមែនជាភាគីហត្ថលេខីក៏ដោយ ។

តុលាការព្រហ្មទណ្ឌអន្តរជាតិមានយុត្តាធិការលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ។ តុលាការព្រហ្មទណ្ឌអន្តរជាតិអាចកាត់សេចក្តីទៅលើអំពើភេរវកម្មនៅពេលដែលអំពើទាំងនេះមានទម្ងន់ស្មើនឹងបទឧក្រិដ្ឋទាំងបីនេះ ។ គ្រប់ប្រទេសទាំងអស់មានភារកិច្ចចាត់វិធានការចាំបាច់នានាក្នុងការទប់ស្កាត់មិនឲ្យប្រព្រឹត្តអំពើភេរវកម្មព្រមទាំងមានភារកិច្ចនាំយកភេរវជនមកកាត់ទោសទៀតផង ។

លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិចូលជាធរមាននៅថ្ងៃទី១ ខែកក្កដា ហើយចាប់ពីពេលចូលជាធរមានរួចមក បទបញ្ញត្តិរបស់តុលាការនេះក្លាយជាកាតព្វកិច្ចចាប់បង្ខំនៅក្នុងច្បាប់អន្តរជាតិ ។ កិច្ចប្រជុំចុងក្រោយរបស់គណៈកម្មការរៀបចំតុលាការព្រហ្មទណ្ឌអន្តរជាតិធ្វើឡើងពីថ្ងៃទី១ ដល់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០២ នៅទីក្រុងញូវយ៉ក ដែលនៅទីនោះមានកិច្ចការជាច្រើនដែលតម្រូវឲ្យធ្វើដើម្បីធ្វើឲ្យតុលាការនោះមានលក្ខណៈពេញលេញ ។

កិច្ចប្រជុំលើកទីមួយនៃរដ្ឋជាភាគីហត្ថលេខីរៀបចំធ្វើឡើងក្នុងអំឡុងថ្ងៃទី៣ ដល់ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០២ នៅទីក្រុងញូវយ៉ក ។ នៅក្នុងកិច្ចប្រជុំនេះ ឯកសារទាំងអស់ដែលស្នើឡើងដោយគណៈកម្មការរៀបចំត្រូវបានយកមកពិនិត្យពិចារណា ហើយនីតិវិធីសម្រាប់ការតែងតាំងចៅក្រម និងព្រះរាជអាជ្ញារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានអនុម័ត ។ រដ្ឋនានាបានគិតគូរ និងតែងតាំងបេក្ខជន តាមរយៈការបោះឆ្នោតនៅខែកុម្ភៈ ឆ្នាំ២០០៣កន្លងមកនេះ ។ រាជរដ្ឋាភិបាលកម្ពុជាក៏បានបញ្ជូនបេក្ខជនមួយរូបគឺលោក ហេង វង្សប៊ុនឆាត សម្រាប់ចូលរួមក្នុងដំណើរការជ្រើសរើសចៅក្រមនេះ ។ ប៉ុន្តែគួរឲ្យសោកស្តាយលោកមិនទទួលបានសំឡេងគាំទ្រគ្រប់គ្រាន់សម្រាប់តំណែងចៅក្រមតុលាការព្រហ្មទណ្ឌអន្តរជាតិទេ ។

ដោយសារកិច្ចការនេះមានលក្ខណៈចាំបាច់ ហើយតម្រូវឲ្យមានកិច្ចខិតខំប្រឹងប្រែងខ្លាំងដើម្បីប្រែក្លាយតុលាការព្រហ្មទណ្ឌពីគំនិតនៅលើក្រដាសឲ្យចេញជារូបរាងពិតប្រាកដនោះ ពេលវេលាកំណត់ដាក់ដោយគណៈកម្មការរៀបចំគឺពិតជាអាចសម្រេចបាន និងប្រកបដោយការទទួលខុសត្រូវ ។

ការដាក់ឲ្យតុលាការព្រហ្មទណ្ឌប្រតិបត្តិពេញលេញពិតជាត្រូវការពេលវេលា ។ នេះមិនត្រឹមតែជាការរំពឹងទុកនោះទេ ប៉ុន្តែវាជាការចាំបាច់ប្រសិនបើយើងរៀបចំធ្វើឲ្យតុលាការនេះមានមូលដ្ឋានរឹងមាំនៅពេលប្រតិបត្តិការនាឆ្នាំដំបូង ។

ប្រការនេះមិនខុសទៅនឹងការបង្កើតតុលាការចម្រុះសម្រាប់វិនិច្ឆ័យទោសមេដឹកនាំខ្មែរក្រហមនោះទេ ដែលត្រូវការមូលដ្ឋានច្បាប់និងនីតិវិធីដែលអាចទទួលយកបានជាអន្តរជាតិ ។ អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាគឺរៀបចំឡើង "ដើម្បីវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនិងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលប្រព្រឹត្តឡើងក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩" ដោយមានការចូលរួមពីអង្គការសហប្រជាជាតិ ។ អាជ្ញាយុកាលនៃបណ្តឹងអាជ្ញានៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលទាក់ទងដល់បទល្មើសខាងលើត្រូវ

បានពន្យារពេលបន្ថែម២០ឆ្នាំទៀតទៅលើអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាសម្រាប់ឧក្រិដ្ឋកម្មទាំងឡាយខាងក្រោមដែលស្ថិតក្នុងសមត្ថកិច្ចនៃអង្គជំនុំជម្រះវិសាមញ្ញ ។ ច្បាប់នេះគ្របនូវបទល្មើសដូចជាមនុស្សឃាត (ច្បាប់ឆ្នាំ១៩៥៦ៈ មាត្រា៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧និង៥០៨) ទារុណកម្ម (ច្បាប់ឆ្នាំ១៩៥៦ មាត្រា៥០០) ការធ្វើទុក្ខបុកម្នេញលើសាសនា (ច្បាប់ឆ្នាំ១៩៥៦ មាត្រា២០៩ និង២១០) ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិវប្បធម៌, អំពើប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងបុគ្គលដែលត្រូវបានការពារដោយច្បាប់អន្តរជាតិ ។

សមាសភាពនៃអង្គជំនុំជម្រះ គឺក្នុងអង្គជំនុំជម្រះសាលាដំបូងមានចៅក្រមខ្មែរបីរូបនិងចៅក្រមអន្តរជាតិពីររូប ។ អង្គជំនុំជម្រះតុលាការកំពូលដែលជាកន្លែងបណ្តឹងឧទ្ធរណ៍ផង និងជាកន្លែងចេញសេចក្តីសម្រេចបិទផ្លូវតវ៉ាផងនោះមានចៅក្រមខ្មែរបួនរូបនិងចៅក្រមអន្តរជាតិបីរូប ។

លោកអគ្គលេខាធិការអង្គការសហប្រជាជាតិនឹងបញ្ជូនបញ្ជីឈ្មោះបេក្ខជនសម្រាប់តំណែងជាចៅក្រមអន្តរជាតិយ៉ាងតិចប្រាំពីររូប ហើយពីក្នុងបញ្ជីនេះឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងតែងតាំងចំនួនប្រាំរូបដើម្បីបម្រើការងារជាចៅក្រមនៅអង្គជំនុំជម្រះទាំងពីរថ្នាក់ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតែងតាំងចៅក្រមអន្តរជាតិដោយយកពីក្នុងបញ្ជីឈ្មោះដែលអគ្គលេខាធិការអង្គការសហប្រជាជាតិបានប្រគល់ជូនតែប៉ុណ្ណោះ ។ អង្គជំនុំជម្រះវិសាមញ្ញត្រូវរលាយខ្លួនជាស្វ័យប្រវត្តិ ក្រោយពេលដែលការវិនិច្ឆ័យទោសក្នុងរឿងក្តីនេះបានចប់ជាស្ថាពរ ។

អង្គតុលាការទាំងបីពិតជាផ្តល់ផលប្រយោជន៍យ៉ាងសំខាន់ដល់ប្រទេសកម្ពុជាទាំងខាងផ្លូវច្បាប់ សីលធម៌ មនុស្សធម៌និងការការពារអធិបតេយ្យភាពជាតិ ។ ជាក់ស្តែងកម្ពុជាទទួលបាននូវប្រាសាទព្រះវិហារមកវិញពីប្រទេសថៃដែលចូលមកកាន់កាប់តាំងពីឆ្នាំ១៩៥៤ តាមអំណាចសាលក្រមរបស់តុលាការអន្តរជាតិ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២ ។ ករណីយុត្តិសាស្ត្រលើវិវាទទាក់ទងនឹងប្រាសាទព្រះវិហារនេះអាចប្រើប្រាស់ជាគំរូសម្រាប់ដោះស្រាយវិវាទនាពេលបច្ចុប្បន្នផងដែរ ជាពិសេសបញ្ហាព្រំកិលព្រំដែន បញ្ហាដែនសមុទ្រត្រួតស៊ីគ្នា និងបញ្ហាផ្សេងទៀតដែលរដ្ឋាភិបាលកម្ពុជាមិនទាន់ដោះស្រាយតាមផ្លូវច្បាប់ជាមួយប្រទេសជិតខាងប្រកបដោយជោគជ័យ ។

យ៉ាងណាមិញ តុលាការព្រហ្មទណ្ឌអន្តរជាតិក្រោយពីចូលជាធរមាននិងដំណើរការពេញលេញហើយនោះ អាចឲ្យប្រជាជាតិទាំងអស់រួមទាំងកម្ពុជាបង្ការបាននូវអំពើឃោរឃៅទាំងឡាយប្រកបដោយប្រសិទ្ធភាពដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុតដែលភាគច្រើននៅក្នុងអតីតកាលតែងតែរួចខ្លួន និងរំលោភយ៉ាងធ្ងន់ធ្ងរទៅលើសីលធម៌សង្គមនិងច្បាប់មនុស្សធម៌អន្តរជាតិ ។ មិនតែប៉ុណ្ណោះការទទួលយកនូវកាតព្វកិច្ចដោយស្ម័គ្រចិត្តរបស់រដ្ឋជាសមាជិកក្នុងការរួមសហការជាមួយតុលាការនឹងដើរតួនាទីបង្ការទប់ស្កាត់យ៉ាងសំខាន់ ។

ចំណែកឯអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដែលមានការចូលរួមពីអង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិនឹងឈានទៅបញ្ចប់បរិយាកាសនិទណ្ឌភាព និងការពង្រឹងភាពជឿជាក់លើប្រព័ន្ធតុលាការនៅក្នុងប្រទេសនិងជាការលាតត្រដាងនូវអតីតកាលប្រកបដោយមន្ទិលសង្ស័យដល់យុវវ័យជំនាន់ក្រោយ នៅពេលដែលសាលក្រមរបស់តុលាការនេះត្រូវបានគោរពនិងទទួលយកជាអន្តរជាតិ ។ ប៉ុន្តែអង្គជំនុំជម្រះក៏គ្មានន័យអ្វីដែរប្រសិនបើមានតែអង្គជំនុំជម្រះ ហើយចារីប្រព្រឹត្តបទឧក្រិដ្ឋស្លាប់ដោយភាពចាស់ជរា ឬដោយជំងឺដោយសារភាពយឺតយ៉ាវ និងកង្វះឆន្ទៈនៃរដ្ឋាភិបាលកម្ពុជា ព្រមទាំងដោយសារការមិនចូលរួមដោយស្ម័គ្រចិត្តនិងពេញលេញប្រកបដោយន័យស្ថាបនារបស់សហគមន៍អន្តរជាតិ សង្គមស៊ីវិល ជាពិសេសរដ្ឋដែលមានចំណាប់អារម្មណ៍លើតុលាការនេះ ។ លើសពីនេះទៀតប្រសិនបើតុលាការចម្រុះនេះចេញជារូបរាងពិតប្រាកដ វាអាចជួយពង្រឹងការអនុវត្តច្បាប់នៅកម្ពុជា ពិសេសពង្រឹងប្រព័ន្ធតុលាការកម្ពុជាទៀតផង ។

ដូចនេះតុលាការទាំងបីគឺជាមុំចង្ក្រានបីយ៉ាងរឹងមាំក្នុងការធានាដល់បូរណភាពទឹកដី ធម្មាធិបតេយ្យ និងភាពថ្លៃថ្នូររបស់ពលរដ្ឋខ្មែរ ។

**សួ ប៊ុនស៊ូ**

## *ការពិតដែលនិយាយមិនចេញៈ*

# បញ្ហាលំបាកដែលគណៈកម្មការស្វែងរកការពិតប្រឈមមុខ

*រីឆាត ហ្គោលស្តូន បានលើកឡើងនៅក្នុង* American Prospect *សរសេរនៅលើទំព័រមុខនៃសៀវភៅនេះ ដែលមានចំណងជើងថាៈ «ការពិតដែលនិយាយមិនចេញៈបញ្ហាលំបាកដែលគណៈកម្មការស្វែងរកការពិតប្រឈមមុខ»ថាវា«ផ្តល់នូវការស៊ីជម្រៅទៅលើរបៀបដែលគណៈកម្មការស្វែងរកការពិតអាចបម្រើឲ្យបុព្វហេតុសិទ្ធិមនុស្ស និងយុត្តិធម៌យ៉ាងដូចម្តេចខ្លះ?» ។*

*នៅក្នុងសៀវភៅដែលមានចំណងជើងថា«ការពិតដែលនិយាយមិនចេញ» អ្នកនិពន្ធ ព្រីស ស៊ីឡា ហេន័រ នាយកកម្មវិធីនៅមជ្ឈមណ្ឌលអន្តរជាតិដើម្បីយុត្តិធម៌ប្រចាំនៅទីក្រុងញូវយ៉កឈ្មោះជាភាសាបារាំងសរសេរថា«*Spectateur engagé*»ដែលល្បីថា ជាសិស្សពូកែម្នាក់ក្នុងចំណោមសិស្សពូកែខ្លាតពិភពលោកជំនាញខាងគណៈកម្មការស្វែងរកការពិតនោះ បានបញ្ចេញនូវការសិក្សាស្រាវជ្រាវដ៏ច្បាស់លាស់អំពីគណៈកម្មការស្វែងរកការពិតនៅក្នុងពិភពលោក កំហឹងឈឺចាប់ ភាពអយុត្តិធម៌ និងកេរដំណែលនៃសេចក្តីស្អប់ដែលគណៈកម្មការទាំងនោះចង់ដោះស្រាយ ។ អ្នកស្រីពិនិត្យទៅលើគណៈកម្មការសំខាន់ៗចំនួន២១ដែលបង្កើតឡើងជុំវិញពិភពលោក ដោយផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើប្រទេសអាហ្វ្រិកខាងត្បូង អែលសាវ៉ាឌ័រ អាហ្សង់ទីន ឈីលី និងហ្គេតាម៉ាឡា ។*

*ទាក់ទងនឹងគណៈកម្មការស្វែងរកការពិតមានក្មេងស្រីជនជាតិភូមាម្នាក់អង្គុយជួរមុខនៅនិទាឃរដូវឆ្នាំ២០០០ នៅទីស្នាក់ការសម្ព័ន្ធជាតិប្រជាធិបតេយ្យរបស់អ្នកស្រី អ៊ុងសាន ស៊ូជី ដែលហ៊ុមជុំជិតដោយភ្នាក់ងារស៊ើបការណ៍យោធាបានសួរដោយត្រង់ថា «តើគេបង្កើតគណៈកម្មការស្វែងរកការពិតយ៉ាងដូចម្តេច» ។ ទាន់ទិននឹងបញ្ហានេះ ធីម៉ូធី ហ្គាតុន អាហ្ស និយាយនៅក្នុងកថាមុខនៃសៀវភៅនេះថា «...ចម្លើយនេះមិនត្រឹមតែទាក់ទងទៅនឹងប្រទេសភូមានោះទេ ប៉ុន្តែទាក់ទងប្រទេសជាច្រើនទៀតដែលបម្រុង ឬដែលកំពុងតែជួបការលំបាកនៅក្នុងដំណាក់កាលឆ្លងកាត់ពីរបបផ្តាច់ការ ។ មនុស្សគ្រាន់តែទទួលស្គាល់ថាប្រទេសទាំងនេះអាចនិងគួរតែរៀនសូត្រពីប្រទេសផ្សេងៗទៀត មិនត្រឹមតែបញ្ហាកសាងសេដ្ឋកិច្ចទីផ្សារ សរសេររដ្ឋធម្មនុញ្ញ ឬស្តារឡើងវិញនូវធម្មាធិបតេយ្យនោះទេ ប៉ុន្តែត្រូវផ្តោតទៅលើវិធីធ្វើយ៉ាងដូចម្តេចដើម្បីដោះស្រាយអតីតកាលដែលមានការលំបាក ។ មានពាក្យ ឬពាក្យបន្ថែមផ្សេងៗគ្នាចំពោះបញ្ហាប្រយុទ្ធជាមួយនឹងអតីតកាលដែលបញ្ហានីមួយៗមានអាទិភាពផ្សេងៗគ្នា ។ ប៉ុន្តែទាំងអស់គ្នាទទួលស្គាល់អំពីបញ្ហាថា «ត្រូវធ្វើយ៉ាងណាចំពោះអតីតកាល» គឺជាបញ្ហាសំខាន់និងជាផ្នែកមួយនៃដំណើរការឆ្លងកាត់នេះ ។ មិនតែប៉ុណ្ណោះវាអាចធ្វើឲ្យមានភាពផ្សេងគ្នារវាងជោគជ័យនិងបរាជ័យថែមទៀត» ។*

*ដោយដកស្រង់សម្តីរបស់អ្នកផ្តល់សម្ភាសន៍រាប់រយនាក់នៅក្នុងប្រទេសរាប់សិប សៀវភៅនេះផ្តោតយ៉ាងសំខាន់ទៅលើគណៈកម្មការស្វែងរកការពិតនៅក្នុងពិភពលោក ។ អ្នកស្រី ហេន័រ រកឃើញថា ជនរងគ្រោះត្រូវញាំញីដោយភាពចាំបាច់ពីរយ៉ាង ទីមួយត្រូវចងចាំនិងទីពីរត្រូវបំភ្លេចចោល ។*

*ឆ្លើយតបទៅនឹងសំណួររបស់អ្នកនិពន្ធ «តើលោកចង់ចងចាំ ឬក៏បំភ្លេចចោល?» ដែលលើកឡើងនៅចុងឆ្នាំ១៩៩៥ ពោលគឺមួយឆ្នាំគត់ក្រោយពីអំពើប្រល័យពូជសាសន៍កើតឡើងនៅក្នុងប្រទេសនេះដែលបណ្តាលឲ្យមនុស្សស្លាប់ជាង៥សែននាក់ មន្ត្រីរដ្ឋាភិបាលរ៉ាន់ដា ដែលបាត់បង់សមាជិកគ្រួសារផ្ទាល់ចំនួន១៧នាក់ក្នុងអំឡុងពេលបីឆ្នាំនិងកន្លះខែនៃការកាប់សម្លាប់នេះ បានឆ្លើយតបទាំងស្ទាក់ស្ទើរនិងយឺតៗថា «យើងត្រូវតែចងចាំទុកនូវអ្វីដែលបានកើតឡើងដើម្បីកុំឲ្យអំពើនេះកើតឡើងជាថ្មីម្តងទៀត» ។ «ប៉ុន្តែយើងត្រូវឈប់គិតក្នុងអារម្មណ៍ក្នុងមនោសញ្ចេតនា មានតែបំភ្លេចចោលទេទើបយើងអាចធ្វើដំណើរទៅមុខបាន» ។*

*ក្រោយពីការអង្កេតនិងយល់អំពីសេចក្តីវន្ទត់ដែលគាត់ (ជនរងគ្រោះខាងលើ) បានឆ្លងកាត់ អ្នកស្រី ហេន័រ ដឹងថា«គ្មានចម្លើយណាផ្សេងពីនេះទៀតទេ» ។ មនុស្សម្នាក់ត្រូវតែចងចាំ ប៉ុន្តែគាត់ជួនកាលក៏ត្រូវតែបំភ្លេចដែរ» ។ ឧទាហរណ៍ នៅពេលនិយាយជាមួយអ្នកចម្ការម្នាក់ ជនជាតិ អែលសាវ៉ាឌ័រ រស់នៅដាច់ស្រយាល ជាកន្លែងដែលត្រូវបានស្គាល់ថា មានសកម្មភាព*

នយោបាយនិងញាំញីដោយសង្គ្រាម គាត់(ជនរងគ្រោះ) បានរៀបរាប់ពីការកាប់សម្លាប់មនុស្សស្ថិតក្នុងកណ្តាប់ដៃខ្មាំងដែលគាត់ឃើញផ្ទាល់នឹងភ្នែក ពេលគឺឃើញគេអាករឪពុកបង្កើតនិងអ្នកជិតខាងម្នាក់ជាស្ត្រីមានផ្ទៃពោះ ។ តើគាត់បាននិយាយជាមួយគណៈកម្មការស្វែងរកការពិតដែរឬទេ? ទេគាត់មិនបាននិយាយទេ ។ “ពិបាកនឹងចងចាំណាស់ ។ ចងចាំទៅវានាំឲ្យឈឺចាប់ណាស់” ។ គាត់បន្តទៀតថា “ចងចាំវានាំឲ្យឈឺចាប់ ប៉ុន្តែសំខាន់ត្រូវប្រយុទ្ធដើម្បីធម្មាធិបតេយ្យ” ។

ខ្ញុំយល់ស្របជាមួយទស្សនៈរបស់ ហេន័រ ដែលបញ្ជាក់ថា “ការចងចាំមិនងាយស្រួលទេ ប៉ុន្តែការបំភ្លេចអាចមិនអាចទៅរួច” ។ មានវិធីជាច្រើនសម្រាប់ទប់ទល់ជាមួយនឹងអារម្មណ៍និងផ្លូវចិត្តរបស់អ្នកដែលធ្លាប់ឆ្លងកាត់អំពើរឃោរឃៅបែបនេះ” ។

នៅពេលដែលជនរងគ្រោះមួយចំនួន ដូចជាបុរសជនជាតិអ៊ែលសាវ៉ាឌ័រម្នាក់នេះបានឆ្លើយថា បំភ្លេច មានជនរងគ្រោះដទៃទៀត ដែលហេន័រ បាននិយាយជាមួយបញ្ជាក់ច្បាស់ថា “មានតែចងចាំទេ ទើបអាចចាប់ផ្តើមជាសះស្បើយបាន ។ មានតែការចងចាំនិយាយរឿងរ៉ាវចាស់ និងជ្រាបអំពីរឿងលម្អិតចុងក្រោយទាក់ទងនឹងអ្វីដែលបានកើតឡើង និងអ្នកដែលមានការទទួលខុសត្រូវទេ ទើបអាចចាប់ផ្តើមចាត់ទុកអតីតកាលដោយឡែក” ។ ឧទាហរណ៍ ហេន័រ និយាយទៅកាន់អ្នកស្រី ហាសេ នៅពេលសម្រាកពិសាតែចន្លោះពេលសវនាការជាសាធារណៈចំនួនពីរសប្តាហ៍ថា ក្រោយពេលស្តាប់អតីតនគរបាលសន្តិសុខឡើងស្រាយបំភ្លឺយ៉ាងលម្អិតអស់រយៈពេលបួនថ្ងៃអំពីរបៀបដែលគេបានចាប់ពង្រត់និងសម្លាប់ប្តីអ្នកស្រីនិងបុរសពីររូបទៀតយកទៅដុត អស់រយៈពេលប្រាំមួយម៉ោងរហូតក្លាយទៅជាផេះរួចបំណែកសល់ប៉ុន្មានដែលដុតមិនឆេះយកទៅចោលនៅក្នុងទន្លេ “តើអ្នកស្រីយល់ឃើញយ៉ាងដូចម្តេចចំពោះសវនាការនេះ?” ។ “តើវាមានន័យយ៉ាងដូចម្តេចចំពោះអ្នកស្រី?” ។ អ្នកស្រីអាសេឆ្លើយថា “យ៉ាងហោចណាស់ខ្ញុំដឹងខ្លះ អំពីរឿងរ៉ាវទាំងមូលដឹងវាប្រសើរជាងមិនដឹងពិសេសដឹងពីរបៀបដែលគេយកទៅសម្លាប់” ។

ចំណែកឯអ្នកស្រី ម៉ូនីកា ហ្គោដូឡូហ្ស៊ី ដែលជាស្ត្រីមេម៉ាយមិនសូវជាអត់ឱនប៉ុន្មានទេ ។ ដូចជាអ្នកចូលរួមនៅក្នុងបន្ទប់សវនាការដែលមានសភាពអ៊ូអរ និងមនុស្សកកកុញដែលអ្នកស្រី ម៉ូនីកា និយាយទៅកាន់ ហេន័រ ថា “ខ្ញុំនឹងមិនអត់ឱនឲ្យពួកវាទេ ។ គ្មានអ្វីដែលធ្វើឲ្យខ្ញុំអត់ឱនឲ្យវាឡើយ ។ បើវានិយាយការពិតទើបរួចខ្លួន ។ អ្នកណាក៏ដោយឲ្យតែនិយាយការពិតខ្ញុំអាចអត់ទោសឲ្យបាន ។ ប៉ុន្តែមិនមែនអ្នកដែលភូតកុហកនោះទេ” ។

ក៏ប៉ុន្តែ អ្នកស្រី អាសេ មិនយល់ស្រប ដោយនិយាយថា “តើយើងមិនចង់បានសន្តិភាព សម្រាប់អាហ្វ្រិកខាងត្បូងទេឬ?” ។

តើយើងស្វែងរកសន្តិភាពតាមរបៀបណាប្រសិនបើយើងមិនអត់ឱនឲ្យគ្នាផងនោះ? ប្តីខ្ញុំប្រយុទ្ធដើម្បីសន្តិភាពជូនអាហ្វ្រិកខាងត្បូង ។ តើអ្នកឯងយកកំហុសមកកែកំហុសម្តេចនឹងកើត?” ។ មួយឆ្នាំមុន អ្នកស្រី អាសេ មើលទៅហាក់ដូចជាមានការឈឺចាប់នៅពេលអ្នកស្រីផ្តល់ចម្លើយជាសាក្សីដល់គណៈកម្មការស្វែងរកការពិត លើកទីមួយនៅក្នុងសវនាការលើកដំបូង ។ ដឹងនូវអ្វីដែលបានកើតឡើងចំពោះប្តីអ្នកស្រី ឬយ៉ាងហោចណាស់ដឹងថាអ្នកណាសម្លាប់ប្តីអ្នកស្រី(យកទៅដុតរួចបោះចោល) និងរឿងរ៉ាវលម្អិតផ្សេងៗទៀតទាក់ទងនឹងការស្លាប់របស់ប្តីអ្នកស្រី បានធ្វើឲ្យអ្នកស្រីមានការផ្លាស់ប្តូរ ។ ប៉ុន្តែតាមដែល ហេន័រ សង្កេតឃើញថា ចំពោះតែអ្នកស្រី ហ្គោដូឡូហ្ស៊ី ប៉ុណ្ណោះ គឺមិនទាន់គ្រប់គ្រាន់នៅឡើយទេ ។

អ្នកស្រី ហេន័រ បញ្ជាក់ថា “ស្ត្រីមេម៉ាយអាហ្វ្រិកខាងត្បូង អ្នកចម្ការជនជាតិ អ៊ែល សាវ៉ាឌ័រ និងមន្ត្រីរដ្ឋាភិបាលរ៉ាន់ដាបានបង្ហាញនូវការលំបាកនានារបស់ជនរងគ្រោះជាបុគ្គល និងជាតិទាំងមូលតែម្តងក្រោយពីមានការបង្ក្រាបដោយហេតុផលនយោបាយយ៉ាងឃោរឃៅមួយរយៈមក ។

ហេន័រ ក៏បានបញ្ជាក់បន្ថែមទៀតថា “ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងពីសំណាក់គណៈកម្មការស្វែងរកការពិត និងផ្សះផ្សាក៏ដោយ ក៏ជនជាតិអាហ្វ្រិកខាងត្បូងជាច្រើនរូបនៅតែទាមទារយុត្តិធម៌និងការផ្តន្ទាទោសយ៉ាងតឹងរ៉ឹងទៅលើចារីនៃបទល្មើស ។ ដោយហេតុថាមិនទាន់មានយុត្តិធម៌ តម្រូវការជាអប្បបរមាឲ្យមានការប្រណីទោសដែលគេទទួចហើយទទួចទៀតនោះត្រូវបានប្រាប់ការពិតយ៉ាងពេញលេញ និងដោយស្មោះត្រង់” ។

ឆ្លងកាត់តាមបទពិសោធន៍ដែលខ្លួនមាននៅអាហ្វ្រិកខាងត្បូង អ៊ែល សាវ៉ាឌ័រ និង រ៉ាន់ដា ក៏ដូចជាការធ្វើដំណើរទៅកាន់ប្រទេសមួយចំនួនទៀត ដើម្បីស្វែងយល់ថាតើប្រទេសមួយនិង

ប្រជាជននៃប្រទេសនោះអាចងើបរួចពីសម័យកាលនៃអំពើឃោរឃៅដោយរបៀបណានោះ ហេន័រ មានការចាប់អារម្មណ៍ចំពោះឥទ្ធិពលនៃការស្វែងរកការពិតជាលក្ខណៈផ្លូវការពោលគឺ មានការបោះពុម្ពជាឯកសារសាធារណៈ និងស៊ើបអង្កេតដោយគណៈកម្មការពិសេស ដូចនៅអែលសាវ៉ាឌ័រ និងអាហ្វ្រិកខាងត្បូងយ៉ាងដូច្នោះ ។

នៅក្នុងជំពូក១២ ដែលផ្តោតសំខាន់ទៅលើ «ទុកអតីតកាលមួយឡែក» ហេន័រ បានលើកឡើងអំពីរឿងប្រទេសពីរគឺម៉ូសំប៊ិចនិងកម្ពុជាដោយបានសួរសំណួរថា «ហេតុអ្វីបានជាប្រទេសមួយចំនួនដែលងើបចាកផុតពីសង្គ្រាមស៊ីវិលដ៏គួរឲ្យព្រឺព្រួច ឬអំពើឃោរឃៅទ្រង់ទ្រាយធំ បែរជាមិនចាប់អារម្មណ៍ជីកបុស ជីកគល់ អំពីអតីតកាលដែលទើបតែកន្លងផុតទៅយ៉ាងដូច្នេះ? តើហេតុអ្វីបានជាខ្វះសេចក្តីប្រាថ្នាចង់រកការពិតជាផ្លូវការបែបនេះ? មានហេតុផលបួនយ៉ាងដែលហាក់ដូចជាទូទៅនៅក្នុងប្រទេសទាំងនេះ ។ ១) ខ្វាចក្រែងទទួលលទ្ធផល អវិជ្ជមាន ២) ខ្វះផលប្រយោជន៍នយោបាយ ៣) អាទិភាពបន្ទាន់ផ្សេងៗទៀត ៤) យន្តការផ្សេងៗឬ ការពេញចិត្តផ្សេងៗទៀត ។ ទាក់ទងនឹងកម្ពុជា តើគួរធ្វើអ្វីសម្រាប់សហគមន៍អន្តរជាតិ? ដូចដែលនាង ហេន័រ និយាយរួចហើយថា «ប្រទេសនានាដូចជាកម្ពុជា និងម៉ូសំប៊ិចដែលយ៉ាងហោចណាស់មានការជំទាស់មួយរយៈមិនចង់ឲ្យបើកកកាយរឿងអតីតកាលគឺកម្រមានណាស់» ។

ហេតុដូចនេះសៀវភៅនេះមានបំណងជួយភ្ជាប់គ្នារវាងទ្រឹស្តីនិងការអនុវត្ត ចង់បង្ហាញនូវបទពិសោធន៍របស់ជនរងគ្រោះបង្ហាញអំពីសេចក្តីសង្ឃឹមសម្រាប់អ្នកគាំទ្រសិទ្ធិមនុស្ស ការលំបាកពិបាកអារកាត់របស់អ្នកគាក់តែងនយោបាយនៅពេលដែលខ្លួនអនុវត្ត ឬចូលរួមនៅក្នុងដំណើរការទាំងនេះ ។ សេចក្តីសម្រេចក្នុងការជីកកកាយរឿងអតីតកាលដ៏លំបាកលំបិនវាសម្រេចតែទៅលើប្រទេសមួយ និងប្រជាជនរបស់ខ្លួនចំណែកឯប្រទេសមួយចំនួនប្រហែលជាមានហេតុផលរបស់ខ្លួនក្នុងការទុកអតីតកាលមួយឡែកដោយមិនអើពើ ។ **ឌួង សុភារិទ្ធ**

## សេចក្តីជូនដំណឹងរបស់សមាគមអ្នកនិពន្ធខ្មែរ

សមាគមអ្នកនិពន្ធខ្មែរសូមជម្រាបដល់ប្រជាជនកម្ពុជាគ្រប់រូបថាសមាគមបានរៀបចំ **«វេទិកាថែរក្សាប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ»** ក្រោមកិច្ចសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ វេទិកានេះមានគោលបំណងសំខាន់ៗដូចជា÷

- រួមជាចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់កូនចៅជំនាន់ក្រោយឲ្យបានដឹងនិងសិក្សារៀនសូត្រ ។
- ជាវិធីមួយដើម្បីរំងាប់អារម្មណ៍ដោយយកហេតុការណ៍ សេចក្តីទុក្ខ ការខឹងគុំគួន មកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។
- ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀតនៅក្នុងសង្គមមនុស្ស ។
- ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម និងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

សមាគមអ្នកនិពន្ធខ្មែរសូមអំពាវនាវដល់ប្រជាជនកម្ពុជាចូលរួមសរសេរអត្ថបទទាំងឡាយអំពី÷ ១) រឿងរ៉ាវផ្ទាល់ខ្លួន ២) ព្រឹត្តិការណ៍ដែលលោកអ្នកធ្លាប់បានជួបប្រទះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង ៣) ផ្តល់ដំណោះស្រាយចំពោះបញ្ហាប្រវត្តិសាស្ត្រនេះ ។ ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។

សមាគមអ្នកនិពន្ធខ្មែរនិងមជ្ឈមណ្ឌលឯកសារកម្ពុជានឹងមានកិត្តិយសដោយចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្តី «ស្វែងរកការពិត» ព្រមទាំងផ្តល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ ការចូលរួមរបស់លោកអ្នកគឺជាការរួមចំណែកលើកស្ទួយតម្លៃនៃការសរសេរនិងចំណេះដឹង ។

សូមផ្ញើអត្ថបទរបស់លោកអ្នកមកសមាគមអ្នកនិពន្ធខ្មែរទីស្នាក់ការៈវត្តបទុមវតី ភ្នំពេញ ឬទាក់ទងតាមទូរស័ព្ទលេខ ០១២ ៨៨៣ ០៧២ និង០១២ ៩៨៨ ១៧៦ ចាប់ពីថ្ងៃទី២០ ខែឧសភា រហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៣ ។

សូមអរគុណ ។

# មនុស្សកាឡែសត្វ

ក្នុងន័យនេះជាទស្សនាទានបានបង្ហាញពីទស្សនៈមួយជ្រុងដើម្បីពិចារណាឲ្យឃើញធាតុពិតរបស់ពួកអតីតមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ យើងមិនបានវិភាគហេតុការណ៍ឲ្យគ្រប់ជ្រុងជ្រោយទាំងអស់ទេ ក្នុងរយៈពេលដែលអ្នកទាំងអស់នោះគ្រប់គ្រងប្រទេស ។ យើងខ្ញុំគ្រាន់តែបញ្ជាក់មួយជ្រុងថា មេដឹកនាំខ្មែរក្រហម និងខ្មែរក្រហមមិនមែនជាមនុស្សសុទ្ធទេ ពួកគេជាមនុស្សកាឡែសត្វ មានន័យថា សត្វពាក់កណ្ដាល មនុស្សពាក់កណ្ដាល ។ ហេតុអ្វីបានជាយើងនិយាយដូច្នេះ? ជាការពិតមានតែត្រីឆ្តោទេដែលស៊ីកូនឯង សម្លាប់កូនឯង បើនិយាយអំពីសត្វខ្លាវិញវាសាហាវមែនពិត ក៏ប៉ុន្តែវាមិនដែលស៊ីកូនឯងទេ ។ ក្នុងន័យនេះនរណាក៏បានដឹងច្បាស់ថាក្នុងសម័យខ្មែរក្រហមរបបប្រល័យពូជសាសន៍ ពួកវាបានសម្លាប់ជនជាតិ សញ្ជាតិខ្មែរគ្នាឯងមិនរើសមុខអស់រាប់លាននាក់ ។

ទាក់ទងនឹងបញ្ហាខាងលើ ខ្ញុំលើកយកករណីមួយដែលពួកខ្មែរក្រហមបានសម្លាប់យុទ្ធជនពិការដែលសម្រាកព្យាបាលជំងឺនិងរបួសនៅមន្ទីរពេទ្យមួយឈ្មោះថាមន្ទីរពេទ្យ វិទ្យាល័យបវេល ដែលបច្ចុប្បន្នជាវិទ្យាល័យបវេល ស្រុកបវេល ខេត្តបាត់ដំបង ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមយកទីតាំងនេះធ្វើជាមន្ទីរពេទ្យតំបន់៣ ស្ថិតក្នុងស្រុក៧០ (ស្រុកបវេល) ក្បែរមន្ទីរសន្តិសុខគុកតំបន់៣ ដែលជាគុកដ៏ធំមួយរបស់ខ្មែរក្រហម ។ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៧៨ យើងបានទៅជួបលោក តាប់តោ ជាមេឃុំបវេល បានផ្ដល់ព័ត៌មានឲ្យដឹងថា នៅចុងឆ្នាំ១៩៧៨ និងដើមឆ្នាំ១៩៧៩ ពួកខ្មែរក្រហមបានបាញ់រះសម្លាប់យុទ្ធជនអស់៤០០នាក់ ដែលយុទ្ធជនទាំងនោះជាកងទ័ពពិការនៅពេលចុះទៅសមរភូមិ ហើយបានមកសម្រាកព្យាបាលនៅមន្ទីរពេទ្យនោះ ។ នៅខាងក្រោយបរិវេណមន្ទីរពេទ្យនេះមានឡសម្រាប់ដុតសាកសពមួយដើម្បីយកឆ្អឹងទៅធ្វើជី ។

យើងមានការងឿងឆ្ងល់ណាស់ ហេតុអ្វីក៏ពួកមេដឹកនាំខ្មែរក្រហមសម្លាប់គ្នាឯង សម្លាប់ជាតិឯង ចម្លើយនេះនៅតែអាថ៌កំបាំងនៅឡើយ ។ ជាក់ស្ដែងយុទ្ធជនដែលជាកងទ័ពនិងជាសរសរទ្រូងរបស់ខ្លួនដែលបានក្លាយទៅជាជនពិការដោយសារតែចូលរួមចំណែកបម្រើបដិវត្តរបស់អង្គការខ្មែរក្រហម លទ្ធផលចុងក្រោយអ្នកទាំងអស់នោះត្រូវស្លាប់យ៉ាងអណោចអធ័មបំផុត ។ ហេតុអ្វីបានពួកខ្មែរក្រហមធ្វើដូច្នេះ? យើងបានដឹងថា ក្នុងរបបគ្រប់គ្រងខ្មែរក្រហមពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ គ្មានតុលាការគ្មានច្បាប់សម្រាប់ជំនុំជម្រះទោសនិងរកយុត្តិធម៌ឲ្យជនរងគ្រោះឲ្យបានត្រឹមត្រូវនោះទេ ។ ការវិនិច្ឆ័យទោសគឺធ្វើឡើងតាមរយៈតែទិតៀន-ស៊ុយទិតៀន និងការសង្ស័យប៉ុណ្ណោះ ។

ដូច្នេះយើងកត់សម្គាល់ថា ពួកអតីតមេដឹកនាំខ្មែរក្រហមបានចាត់ទុកដូចមនុស្សកាឡែសត្វ មិនស្គាល់អ្វីថាខុសមិនស្គាល់អ្វីថាត្រូវ ឬមិនដឹងអំពើណាមានប្រយោជន៍ និងឥតប្រយោជន៍នោះទេ ។ ទាក់ទងដល់បញ្ហាខាងលើ ខ្ញុំសូមលើកយកអត្ថបទទ្រឹស្ដីផ្លូវធម៌នៅក្នុងគម្ពីរមនុស្សធម្មកថាមកបំភ្លឺថា ប្រភេទមនុស្សមានបួនយ៉ាង ទី១)មនុស្សោគឺមនុស្សសុទ្ធ ទី២)មនុស្សតិរច្ឆានោ គឺមនុស្សកាឡែសត្វតិរច្ឆាន ទី៣)មនុស្សនេរយិកោ គឺមនុស្សកាឡែនរក និងទី៤)មនុស្សបេតោ គឺមនុស្សកាឡែប្រេត ។ តើសម្គាល់សញ្ញាអ្វីខ្លះដែលដឹងថាមនុស្សសុទ្ធឬមនុស្សកាឡែសត្វ?

នៅក្នុងន័យមានសញ្ញាសម្គាល់បួន ទី១)ជីវិតសញ្ញាបកស្រាយថា មនុស្សលោក សត្វលោក ដកដង្ហើមចូលនិងចេញដើម្បីចង់រស់ដូចគ្នា ទី២)អាហារសញ្ញាបកស្រាយថា មនុស្សលោក សត្វលោក បរិភោគអាហារដើម្បីបំបាត់ការស្រេកឃ្លានដូចៗគ្នា ទី៣)កាមសញ្ញាបកស្រាយថា មនុស្សលោក សព្វលោកមានកាមរាគៈ ហើយសេពសន្ធវៈដូចៗគ្នា និងទី៤)ធម្មសញ្ញាបកស្រាយថាជាសញ្ញាសម្រាប់សម្គាល់មនុស្សសុទ្ធ ដែលមិនមែនមនុស្សកាឡែសត្វ ដែលពាក្យបាលីហៅថា “មនុស្សោ” មនុស្សប្រភេទនេះ គឺជាមនុស្សដែលដឹងខុស ដឹងត្រូវ ដឹងច្បាប់ផ្លូវលោកនិងផ្លូវ

ធម៌ ។ ឯមនុស្សដែលមានសញ្ញាសម្គាល់ទីពីរ ជាមនុស្សកាឡៃសត្វតិរិច្ឆាន ។ ដូចនេះមានតែមនុស្សដែលមានសញ្ញាសម្គាល់ទីបួនទេ ដែលឲ្យតម្លៃនិងលើកកិត្តិនាមថា ជាបណ្ឌិតដែលជាអរិយជនដ៏ប្រសើរ ។ ការកត់សម្គាល់ម្យ៉ាងទៀត មនុស្សសុទ្ធគឺយើងពិនិត្យទៅលើគុណធម៌ និង គុណវិបត្តិនៃមនុស្សនោះ ។ ឯគុណធម៌មានបីយ៉ាងៈ ទី១) សុចិន្តិតចិន្តី បកស្រាយថា មានគំនិតល្អជាប្រក្រតី ទី២) សុភាសិតភាសី បកស្រាយថា មានសម្តីនិយាយល្អជាប្រក្រតី ទី៣) សុកតកម្មការី មានការធ្វើអំពើល្អជាប្រក្រតី ។ មនុស្សមានគុណធម៌ទាំងបីយ៉ាងនេះ ហៅថាមនុស្សសុទ្ធ មនុស្សពិតអាចហៅបណ្ឌិត ឬអរិយជន ។ ធម៌ដែលបណ្ឌិតសរសើរនិងប្រតិបត្តិនោះគឺសុចរិតធម៌ ធម៌ដែលបណ្ឌិតតិះដៀលនិងលះបង់ចោលគឺទុច្ចរិតធម៌ ជនណាដឹងការត្រូវនិងដឹងការខុសនេះ ជននោះហៅថា "មនុស្ស" ។

ការលើកយកទង្វើរបស់មនុស្សទៅឆ្លុះបញ្ចាំងនិងទ្រឹស្តីព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធបរមគ្រូដែលទ្រង់បានចងក្រងទុកគឺជាទស្សនៈបង្ហាញឲ្យដឹងថា មនុស្សកាឡៃសត្វដូចម្តេច មនុស្សសុទ្ធដូចម្តេច ដើម្បីជាពន្លឺមួយឲ្យបណ្តាជនទូទៅពិចារណា និងធ្វើដំណើរតាមវិថីនៃជីវិតឲ្យបានត្រឹមត្រូវតាមច្បាប់ផ្លូវលោកនិងផ្លូវធម៌ប្រយោជន៍ដើម្បីឈានទៅរកសេចក្តីសុខសាន្តផ្ទាល់ខ្លួនម្នាក់ៗក្នុងគ្រួសារនិងប្រទេសជាតិ ។

យើងធ្វើការកត់សម្គាល់នូវប្រភេទមនុស្សនិងសញ្ញាសម្គាល់របស់មនុស្សនេះគឺដើម្បីឆ្លុះបញ្ចាំងទៅនឹងពួកមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនូវសកម្មភាពនិងទង្វើរបស់ពួកគេ គឺមិនត្រឹមត្រូវតាមច្បាប់ផ្លូវលោក ផ្លូវធម៌ឡើយ ។ ពួកនេះត្រូវបានចាត់ទុកនៅក្នុងប្រភេទមនុស្សកាឡៃសត្វ ។ ម្យ៉ាងទៀតយើងឆ្លុះបញ្ចាំងនេះមានបំណងចង់បង្ហាញជាទស្សនៈសម្រាប់ឲ្យមនុស្សទូទៅគ្រប់ស្រទាប់វណ្ណៈ ទោះបីមានតួនាទីខ្ពង់ខ្ពស់ ឬប្រជារាស្ត្រសាមញ្ញ ឬឧត្តមភេទជាសង្ឃភេទក្តី ប្រសិនបើគ្មានសញ្ញាសម្គាល់ទី៤ទេ និងគ្មានគុណធម៌បីយ៉ាងដូចមានលើកឡើងខាងលើទេ គឺមនុស្សទាំងនោះប្រៀបបានទៅនឹងមនុស្សកាឡៃសត្វ (មនុស្សតិរច្ឆាន) ។ ដូច្នេះបើយើងពិនិត្យនូវទង្វើរបស់ពួកអតីតមេដឹកនាំខ្មែរក្រហមចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ វិញបង្ហាញថាពួកខ្មែរក្រហមទាំងនោះមិនមែនជាមនុស្សសុទ្ធឡើយគឺជាមនុស្សកាឡៃដោយសត្វ ។ ជាក់ស្តែងក្រោមការដឹកនាំរបស់ពួកខ្មែរក្រហមបានសម្លាប់ប្រជាជាតិ ប្រជាជនខ្មែរខ្លួនឯង រួមទាំងកម្មាភិបាលដែលសង្ស័យ និងយុទ្ធជនយុទ្ធនារីកងទ័ព ដែលអ្នកទាំងអស់នោះបានចូលរួមបម្រើបដិវត្តន៍ដែរ ។ នេះជាទង្វើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍យ៉ាងសាហាវព្រៃ-ផ្សៃបំផុតក្នុងរយៈកាលនៃការគ្រប់គ្រងបីឆ្នាំ ប្រាំបីខែ និងម្ភៃថ្ងៃ ។ តាមទស្សនៈកម្មផល ធ្វើល្អបានផលល្អ ធ្វើអាក្រក់បានផលអាក្រក់ ។


វាយ១០ រាប់តែ១រំពាត់ វាទាត់ វាធាក់ វាយទះកំផ្លៀង ខ្ញុំថ្ងង់ត្រចៀកដល់សព្វថ្ងៃ

**ឆុម ឆិទា**

# រស់ទាំងអស់សង្ឃឹម



ខ្ញុំមានស្រុកកំណើតនៅភូមិព្រែកសំរោង ឃុំកោះធំ ស្រុកកោះធំ ខេត្តកណ្តាល ។ ខ្ញុំកើតនៅឆ្នាំ១៩៨០ ពោលគឺ ក្រោយពេលដែលរបបព្រៃផ្សៃនៅប្រទេសកម្ពុជាវិនាសសាបសូន្យទៅ ។ ទោះបីជាខ្ញុំកើតមិនទាន់និងមិនបានឃើញនូវសោកនាដកម្មនៃរបបនោះដោយផ្ទាល់ក៏ដោយ ក៏ឯកសារនានានិងឪពុកម្តាយខ្ញុំបានប្រាប់ខ្ញុំឲ្យដឹងថា នៅឆ្នាំ១៩៧៥របបកម្ពុជាប្រជាធិបតេយ្យ បាននាំមកនូវមហាវិនាសកម្មយ៉ាងច្រើនឥតគណនាសម្រាប់ប្រជាជនកម្ពុជាទាំងមូល ។

ប្រជាជនកម្ពុជាស្លូតត្រង់ប្រមាណជិត២លាននាក់បានស្លាប់ដោយអត់អាហារ ជំងឺតម្កាត់ ធ្វើការងារច្រើនម៉ោងក្នុងមួយថ្ងៃៗ ការធ្វើទារុណកម្ម និងការសម្លាប់ដោយគ្មានការជំនុំជម្រះ ។ ឪពុកម្តាយរបស់ខ្ញុំក៏ស្ថិតក្នុងចំណោមជនរងគ្រោះរបស់របបនេះដែរ ។

មុនសម័យ ប៉ុល ពត ឪពុកម្តាយរបស់ខ្ញុំរស់នៅភ្នំពេញ ម្តុំផ្សារប៉េសេលេខ៤ ភូមិទំនប់ថ្មី ឃុំបឹងទំពុន ។ លុះដល់ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានវាយដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ ហើយគាត់ក៏ដូចប្រជាជនដទៃទៀតបានត្រូវខ្មែរក្រហមជម្លៀសចេញពីទីក្រុង ។ ពេលនោះខ្មែរក្រហមនិយាយថា សូមពុកម៉ែចេញតែបីថ្ងៃទេដើម្បីសម្អាតទីក្រុង ដូច្នេះមិនបាច់យកអ្វីច្រើនទៅជាមួយទេ ។ ក្នុងពេលជម្លៀសចេញនោះមានមនុស្សយ៉ាងច្រើនកកកុញនៅតាមដងផ្លូវនានា ឪពុកម្តាយរបស់ខ្ញុំធ្វើដំណើរពេញមួយយប់បានតែចម្ងាយជាងមួយគីឡូម៉ែត្រប៉ុណ្ណោះ គឺចាប់ពីផ្សារប៉េសេលេខ៤ ទៅដល់វង់មូលក្បាលថ្នល់ ។ នៅព្រឹកថ្ងៃបន្ទាប់ គាត់ត្រូវបានខ្មែរក្រហមតម្រូវឲ្យធ្វើដំណើរទៅត្រើយខាងកើតទន្លេ លុះដល់នៅម៉ោង៨យប់ គាត់បានទៅដល់វត្តឫស្សីជ្រោយ ។ ព្រឹកឡើង គាត់ក៏បន្តដំណើរឆ្ពោះទៅកាន់ស្រុកកំណើតរបស់គាត់ នៅភូមិព្រែកសំរោង ឃុំកោះធំ ស្រុកកោះធំ ខេត្តកណ្តាល ។ នៅស្រុកកំណើតបានរយៈពេល១ខែ ដោយភ័យខ្លាចខ្មែរក្រហមដេញឲ្យចុះទៅមុខទៀត គាត់ក៏ភៀសខ្លួនទៅនៅភូមិប្រាសាទ ឃុំប្រាសាទ ស្រុកស្អាង ខេត្តកណ្តាល ជាស្រុកកំណើតរបស់ឪពុកខ្ញុំ ។ នៅភូមិប្រាសាទបានជាង១ខែ ឪពុកខ្ញុំក៏សុំប្រធានភូមិវិលមកកោះធំវិញ ហើយម្តាយរបស់ខ្ញុំក៏បានសម្រាលបានកូនស្រីម្នាក់ដែលត្រូវជាបងស្រីទីមួយរបស់ខ្ញុំ នៅក្នុងឆ្នាំ១៩៧៥ ។ ម្តាយខ្ញុំប្រាប់ថា តែ២០ថ្ងៃគត់ក្រោយពីគាត់សម្រាលបងស្រីរបស់ខ្ញុំ ប្រធានក្រុមបានដាក់ទិសឲ្យចេញពីស្រុកទៅលើ ។ គ្រាន់តែឮដំណឹងថា ឪពុកម្តាយខ្ញុំត្រូវគេដាក់ទិសឲ្យទៅលើ ជីតាខាងម្តាយ ខ្ញុំក៏ទៅសុំអង្វរគេសុំពន្យារពេលបាន ១០ថ្ងៃ ។ ក្រោយមកប្រធានក្រុមមកប្រាប់ម្តងទៀតថា ស្អែកត្រូវទៅលើហើយ ។

ស្អែកឡើង ឪពុកម្តាយរបស់ខ្ញុំបានធ្វើដំណើរដោយរថភ្លើងឆ្ពោះទៅកាន់ខេត្តបាត់ដំបង ។ ទៅដល់ទីនោះ គាត់ទាំងពីរនាក់បានទទួលបញ្ជាឲ្យរស់នៅបាក់អង្រែក ។ ខ្មែរក្រហមក៏បានចាត់តាំងឲ្យឪពុកខ្ញុំឲ្យទៅកាប់ព្រៃនៅចាក់អង្ករ ។ ចំណែកម្តាយខ្ញុំវិញ ខ្មែរក្រហមឲ្យទៅប៉ះបាវ និង កើបអង្កាម ។ នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានចែកដីឲ្យឪពុកម្តាយខ្ញុំ ទំហំទទឹង១០ម៉ែត្រនិងបណ្តោយ១៥ម៉ែត្រ ។ គាត់បានដាំដំឡូងអំពៅ និងបន្លែបង្ការជាច្រើនមុខទៀតនៅលើដីនោះ ។ នៅចុងឆ្នាំ១៩៧៧ ឪពុកខ្ញុំបានធ្លាក់ខ្លួនឈឺ មិនអាចធ្វើការបានជាហេតុធ្វើឲ្យខ្មែរក្រហមកាត់របបអាហាររបស់គាត់ ដោយសំអាងថាគាត់មិនមកធ្វើការ ដូច្នេះគ្មានរបបអាហារទេ ។ ដោយក្តីស្រេកឃ្លាន ឪពុកខ្ញុំបានលួចស្ងោរដំឡូង និងចៀនគល់ចេកដែលគាត់បានដាំនៅលើដីមកធ្វើជាអាហារ ។ ពីមួយថ្ងៃទៅមួយថ្ងៃជំងឺរបស់ឪពុកខ្ញុំកាន់តែធ្ងន់ទៅៗ រហូតដល់ដើរកាន់ឈើច្រត់ ។ ដោយមិនឃើញឪពុកខ្ញុំទៅធ្វើការ

យូរពេក មេកងម្នាក់បានជិះកង់មកតាមលបមើលដល់ផ្ទះដោយសង្ស័យថាគាត់ឈឺសតិអារម្មណ៍គេចមិនធ្វើការងារ ។ នៅក្នុងផ្ទះឪពុកខ្ញុំដើរបានលុះត្រាតែមានស្នូដើម្បីគោង បើមិនដូច្នោះទេមិនអាចដើរបានឡើយ ។ ឃើញជាក់នឹងភ្នែកបែបនេះ មេកងនោះក៏ត្រឡប់ទៅវិញ មួយសន្ទុះក្រោយមក ក៏នាំពេទ្យមកចាក់ថ្នាំឲ្យមួយម្ជុល ។ ចាប់ពីនោះមក ឪពុកខ្ញុំបានជាសះស្បើយវិញជាបណ្តើរៗ ។ គ្រាន់តែបានធូរស្រាលបន្តិច ស្អែកឡើងខ្មែរក្រហមក៏ចាត់ឪពុកខ្ញុំទៅប្រមូលកណ្តាប់ស្រូវដាក់រទេះ ។ នៅដើមឆ្នាំ១៩៧៨ នៅបាក់អង្រែក ឪពុកម្តាយខ្ញុំនៅធ្វើស្រែមិនបានប៉ុន្មាន ខ្មែរក្រហមក៏បញ្ជូនគាត់ទៅព្រៃកតួចព្រៃកដីរ ជាកន្លែងដែលខ្វះត់ហូបណាស់ ។ គាត់ហូបតែស្លឹកឈើដូចជាស្លឹកដំឡូងជាដើម ។ នៅធ្វើស្រែនៅទីនោះ មិនទាន់ទាំងបានប្រមូលផលផង ស្រាប់តែមានត្រាក់ទ័រមួយមកដឹកយកទៅស្រុកត្របែកដូនទ្រី ។ ចៃដន្យនៅយប់នោះគាត់ទាំងពីរនាក់បានឮសូរកម្មាភិបាលខ្មែរក្រហមនិយាយគ្នាថា យកពុកម៉ែទៅឲ្យស៊ីស្មៅ! ។ គ្រាន់តែឮដូច្នោះភ្លាម ឪពុកម្តាយខ្ញុំក៏មានការភិតភ័យមិនចង់ទៅទេ ហើយក៏រៀបចំឥវ៉ាន់ប្រញាប់-ប្រញាល់រត់គេចខ្លួន ។

នៅយប់នោះខែរះព្រាងៗ ម្តាយខ្ញុំទូលអីវ៉ាន់ផង ពកូនផងចំណែកឯឪពុកខ្ញុំរែកអីវ៉ាន់ ។ គាត់ទាំងពីរធ្វើដំណើរពេញមួយយប់មកដល់កាច់រទេះ ជាកន្លែងដែលយោធាសម្លាប់មនុស្សយ៉ាងច្រើន ។ គាត់រិតតែភិតភ័យជាខ្លាំងឡើង ព្រោះនៅពេលភ្លឺឡើងនៅចំកន្លែងកាច់រទេះនេះ ។ ដូចមានការណាត់ទុកជាមុនអ៊ីចឹង នៅកាច់រទេះនោះមិនដឹងជាយោធាម្នាក់លេចចេញមកពីច្រកណាទេ បានដឹកក្របីសំដៅមកជិតគាត់ទាំងពីរ ហើយសួរទៅកាន់គាត់ថា "ពុកម៉ែទៅណា?" ។ ពេលនោះម្តាយខ្ញុំឆ្លើយទាំងញញើញញ័រថា អង្គការឲ្យខ្ញុំទៅច្រូតស្រូវនៅទួលថាន់ រួចច្រូតនៅក្បាលថ្ម ហើយទៅរង្កាលទៀត ។ ឮដូចនេះឈ្លបក៏មិនសួរនាំអ្វីទៀតដែរ ។ នៅទួលថាន់ រដូវភ្ជួរស្រែបានមកដល់ ខ្មែរក្រហមឲ្យឪពុកខ្ញុំទៅភ្ជួរនៅវត្តបញ្ញោ ។ ម្តាយខ្ញុំនៅក្នុងសហករណ៍មើលកូនក្មេងនិងធ្វើចុងភៅ ។ ជាអកុសល បងស្រីទីមួយរបស់ខ្ញុំ ដែលមានអាយុ៣ឆ្នាំ បានស្លាប់ដោយសារជំងឺកញ្រ្ជិល ។ បន្ទាប់ពីបងស្រីរបស់ខ្ញុំស្លាប់ទៅ ម្តាយខ្ញុំត្រូវគេចាត់ចូលជាកម្លាំងទី១ ដោយចាប់ស្ទូងពីម៉ោង៣ទៀបភ្លឺ ។ នៅពាក់កណ្តាលឆ្នាំ១៩៧៨ ខ្មែរក្រហមក៏ឲ្យគាត់មកសហករណ៍បាក់អង្រែកវិញ ។ ដូនពេលនោះទឹកជន់លិចផលដំណាំ ខ្មែរក្រហមក៏លើកទាំងសហករណ៍មកនៅភ្នំសំពៅ តំបន់៤វិញ ។ នៅភូមិពពាលខែ ធ្វើស្រែនៅទីនោះ រដូវច្រូតកាត់បានចូលមកដល់ស្រាប់តែឮសូរគ្រាប់បែកទម្លាក់នៅពោធិ៍សាត់ ។ មិនបានប៉ុន្មានថ្ងៃផង ស្រាប់តែឮសូរទម្លាក់គ្រាប់បែកនៅផ្សារបាត់ដំបងទៀត ។ តាមការរៀបរាប់របស់គាត់ថា ទោះបីជាមានការប្រយុទ្ធគ្នានៅផ្សារបាត់ដំបងក៏ដោយ ក៏នៅពពាលខែគ្មានការរំជើបរំជួលអ្វីទេ ព្រោះកងទ័ពរំដោះមិនទាន់ទៅដល់ ។ មួយខែក្រោយមកទើបចុះមករំដោះបាន ។

ក្រោយពីការរំដោះ ពួកកងទ័ពបានប្រាប់ប្រជាជនជម្លៀសថា គេនឹងជូនបងប្អូនត្រឡប់ទៅស្រុកកំណើតវិញ ។ ដូច្នេះសូមបងប្អូនទៅជួបជុំគ្នានៅស្ថានីយ៍រថភ្លើង



ក្រុមគ្រួសាររបស់ លី សុខឃៀង ក្នុងឆ្នាំ១៩....

បាក់អង្គ្រែក ។ ការទន្ទឹងរង់ចាំនៅស្ថានីយ៍ចេះតែយូរទៅៗ គាត់ទាំងពីរក៏បានសម្រេចគ្នាទិញរទេះមួយដើម្បីដាក់អីវ៉ាន់អូសត្រឡប់មកស្រុកវិញ ព្រោះបើរង់ចាំរថភ្លើងមិនដឹងជាអង្កាល់ទេ ។ ការធ្វើដំណើរពីខេត្តបាត់ដំបងដើម្បីត្រឡប់មកកាន់ស្រុកកំណើតនៅកោះធំវិញ មានរយៈពេលបីខែគត់ ។

នេះជាដំណើរជីវិតដ៏លំបាកលំបិនមួយដែលឪពុកម្តាយខ្ញុំបានឆ្លងកាត់ ។ គាត់ទាំងពីររស់ទាំងក្តីអស់សង្ឃឹម ដោយគិតថាគាត់ប្រហែលជាគ្មានឱកាសនឹងវិលត្រឡប់ទៅកាន់ស្រុកកំណើតវិញទេ ហើយប្រាកដជាចោលឆ្អឹងនៅស្រុកគេមិនខានឡើយ ។ ភាពសោកសង្រេងទាំងនេះមិនគ្រាន់តែកើតមានចំពោះតែឪពុកម្តាយរបស់ខ្ញុំប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងចំពោះប្រជាជនកម្ពុជាទាំងមូល ។ ជាក់ស្តែងបងស្រីរបស់ខ្ញុំម្នាក់ក៏បានស្លាប់នៅក្នុងរបបនេះដែរ ។ ចំណែកអ្នកខ្លះទៀត ស្លាប់ និងអ្នកខ្លះព្រាត់ឪពុកម្តាយកូនចៅ បងប្អូន មាមីង និងសាច់សារលោហិតរបស់ខ្លួនដូចគ្នា ។ ដូច្នេះហើយ យើងមិនគួរទុកឲ្យជនទាំងឡាយដែលប្រព្រឹត្តអំពើប្រកបដោយវិនាសកម្មនេះរួចខ្លួនឡើយ ។

ក្នុងន័យនេះ ខ្ញុំសូមសំណូមពរទៅដល់អង្គការសហប្រជាជាតិក៏ដូចជារដ្ឋាភិបាលកម្ពុជាចាំបាច់ត្រូវតែសហការគ្នាឲ្យបានខ្លាំងក្លាសំដៅធ្វើការកាត់ទោសថ្នាក់ដឹកនាំរបបដ៏ព្រៃផ្សៃនេះឲ្យត្រឹមត្រូវនិងយុត្តិធម៌ដើម្បីធ្វើឲ្យជនរងគ្រោះនិងព្រលឹងជនស្លូតត្រង់ដែលបានស្លាប់បានស្ងប់និងបិទភ្នែកជិត ។

ជាពិសេសជាងនេះទៀត ការដាក់ទោសពួកអ្នកទទួលខុសត្រូវទាំងនេះគឺមានសារសំខាន់បំផុត ព្រោះថាវាជាគំរូមួយសម្រាប់កូនចៅជំនាន់ក្រោយកុំឲ្យដើរតាមគន្លងដ៏គួរឲ្យស្អប់ខ្ពើមនេះ ។

**លី សុខឃាង**

# រងទាំងកាយ រងទាំងចិត្ត



ខ្ញុំចម្រើនវ័យនៅក្នុងភូមិស្វាយមាស ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។ កាលពីខ្ញុំនៅក្មេងឲ្យតែដល់ខែរងាជាទម្លាប់រៀងរាល់ព្រឹកព្រលឹម ខ្ញុំតែងឃើញអ្នកស្រុកនាំគ្នាបំពក់ភ្លក់ភ្លើងដើម្បីកំដៅខ្លួនបន្ថយភាពរងា ។ ខ្ញុំនិងក្មេងៗដទៃទៀតនៅក្នុងភូមិរត់ប្រឡែងគ្នាលេងជុំវិញភ្លក់ភ្លើងដោយមានកាន់បាយកកអង្ករក្រហមមួយដុំជាមួយនឹងអំបិលញាំជាអាហារពេលព្រឹក ។ ជាញឹកញាប់ជម្លោះតែងតែកើតមានឡើងរវាងរូបខ្ញុំនិងក្មេងទាំងនោះ ។ ខ្ញុំអាចតតាំងនឹងពួកវាស្ទើរតែគ្រប់រឿងទាំងអស់ ។ ប៉ុន្តែនៅពេលគេហៅខ្ញុំថា "កូនអត់ឪ" ខ្ញុំគ្មានពាក្យអ្វីតបតនឹងគេវិញឡើយ ។ នៅពេលខ្ញុំដឹងក្តីចេះបំពេញប្រវត្តិរូបចូលសិក្សាខ្លួនឯងបានហើយ នៅពេលណាបំពេញដល់កន្លែងឈ្មោះ ឪពុកនិងមុខរបរ ខ្ញុំត្រូវដាក់ថា "ស្លាប់" ។ ខ្ញុំតែងតែនឹកស្រមើស្រមៃដល់ឪពុករបស់ខ្ញុំថាតើគាត់មានរូបរាងយ៉ាងដូចម្តេច ប្រសិនបើគាត់នៅមានជីវិតរស់នៅតើភាពកក់ក្តៅរបស់ខ្ញុំនឹងមានលើសពីនេះកម្រិតណា? តើម្តាយខ្ញុំត្រូវទទួលការរ៉ាប់រងក្នុងការចិញ្ចឹមកូនៗយ៉ាងលំបាកបែបនេះ ឬយ៉ាងណា?

ឪពុកខ្ញុំបានស្លាប់នៅក្នុងរបបខ្មែរក្រហម ។ របបនេះត្រូវបានស្គាល់ដោយប្រជាជនខ្មែរគ្រប់រូប ទោះជាមិនបានឆ្លងកាត់ផ្ទាល់ក៏បានដឹងតាមរយៈការនិយាយប្រាប់ដែរ ។ ក្រុមគ្រួសារខ្មែរទាំងអស់ សុទ្ធតែជាជនរងគ្រោះនៃរបបនេះ ។

ខ្មែរក្រហមបានចាប់ផ្តើមគ្រប់គ្រងប្រទេសកម្ពុជាពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥រហូតដល់ថ្ងៃទី៦ មករា ឆ្នាំ១៩៧៩ ។ ឪពុកម្តាយខ្ញុំត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញទៅកាន់ភូមិស្វាយមាស ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដោយមិនបានយកអ្វីទៅជាមួយទេ ព្រោះទាហានខ្មែរក្រហមប្រាប់ថា គ្រាន់តែជម្លៀសទៅតែបីថ្ងៃប៉ុណ្ណោះ ប៉ុន្តែបីថ្ងៃ ក្លាយទៅជាថ្ងៃរងទុក្ខអស់រយៈពេល បីឆ្នាំ ប្រាំបីខែ និងម្ភៃថ្ងៃ ។

នៅទីនោះឪពុកម្តាយខ្ញុំត្រូវបានបញ្ជូនឲ្យធ្វើការជាទម្ងន់ ។

ម្តាយខ្ញុំជាកូនកាត់ចិន គាត់មិនចេះការងារធ្វើស្រែចម្ការទេ ។ ខ្មែរក្រហមបានបញ្ជូនឲ្យម្តាយខ្ញុំទៅកាប់ព្រៃទន្ទ្រានដីធ្វើស្រែចម្ការ កាប់បង្គោលសង់រោង ដកស្ទូង ច្រូតកាត់ បោកបែនស្រូវ រោយស្រូវ ដឹកជញ្ជូនស្រូវដាក់ឃ្លាំងវត្តវិហារសួគ៌ ព្រោះខ្មែរក្រហមយកធ្វើឃ្លាំងដាក់ស្រូវ ។ ផុតពីរដូវធ្វើស្រែចម្ការ ម្តាយខ្ញុំត្រូវទៅដកកក់យកមកកួតហាលធ្វើកន្ទេល ។ ខ្មែរក្រហមបានដាក់ទិសឲ្យម្តាយខ្ញុំត្បាញកន្ទេលឲ្យបាន៥ក្នុងមួយថ្ងៃ ។ នៅថ្ងៃមួយម្តាយខ្ញុំឈឺភ្នែក ប្រធានក្រុមមិនឲ្យគាត់សម្រាកហើយថែមទាំងបញ្ជូនឲ្យធ្វើការរហូតទាល់តែឈឺខ្លាំងមើលអ្វីមិនឃើញ ។ គាត់វារចេញពីស្រែស្ទើរតែមិនរួច ។ ម្តាយខ្ញុំត្រូវដឹកដោយកៀវទឹមក្របីមកផ្ទះវិញ ។ ព្រឹកថ្ងៃបន្ទាប់ ម្តាយខ្ញុំពុំបានទៅស្ទូងទេ ប៉ុន្តែប្រធានក្រុមយកកូនក្មេងតូចៗបីនាក់ ឲ្យគាត់មើលជំនួសការទៅធ្វើស្រែ ។ ម្តាយខ្ញុំបាននិយាយទៀតថា គាត់ធ្វើការច្រើន តែបានទទួលរបបអាហារបន្តិចបន្តួចប៉ុណ្ណោះ ។ ទោះបីជាមានការហេវហត់អស់កម្លាំងយ៉ាងណាក៏ដោយ ក៏ម្តាយខ្ញុំមិនហ៊ាននិយាយអ្វីទាំងអស់ ។

ឪពុករបស់ខ្ញុំត្រូវខ្មែរក្រហមចាត់ឲ្យទៅចាំក្របីនិងភ្ជួរស្រែ ។ ថ្ងៃមួយគាត់ភ្ជួរប៉ះចំគល់ឈើធ្វើឲ្យបាក់នង្គ័ល គណៈឃុំយកគាត់ទៅប្រជុំកសាងអស់មួយយប់ ។ នៅចុងឆ្នាំ១៩៧៨ ឪពុកខ្ញុំមានជំងឺគ្រុនចាញ់ គាត់អត់បានទៅភ្ជួរទេ ហើយអង្គប្រជុំចោទថាគាត់ខ្ជិលទម្រន់ ហើយបានបញ្ជូនឲ្យគាត់ទៅធ្វើការដូចសព្វដង ។ មិនដល់មួយខែផង ឪពុករបស់ខ្ញុំទទួលអនិច្ចកម្មទៅ ។ ពេលខ្ញុំទើបនឹងចាប់កំណើតក្នុងផ្ទៃម្តាយរបស់ខ្ញុំបានពីរខែ ។ ដូច្នេះខ្ញុំអាចស្គាល់និងឃើញឪពុករបស់ខ្ញុំតែតាមរយៈរូបថតសខ្មៅពាក់កណ្តាលខ្លួនដែលគាត់បានបន្សល់ទុកប៉ុណ្ណោះ ។



ក្រុមគ្រួសាររបស់ ព្រាំ ដល្លា ក្នុងឆ្នាំ១៩...

បងប្រុសច្បងរបស់ខ្ញុំនៅក្នុងកងចល័ត ។ គាត់លើកទំនប់ និងឃ្វាលគោ ។ ថ្ងៃមួយប្រធានកងបានឲ្យគាត់ឃ្វាលគោដោយឥតមានខ្សែដោយខ្លាចគោស៊ីស្រូវ គាត់បានយកខ្សែគោអ្នកដទៃមកចង ម្ចាស់គេឃើញក៏ប្តឹងទៅប្រធានកង ។ ប្រធានកងក៏បានចាប់បងប្រុសរបស់ខ្ញុំបម្រុងចងបណ្តើរអាក្រោស ប៉ុន្តែត្រូវអាក់ខានទៅវិញដោយសារឪពុករបស់ខ្ញុំយកកាំបិតផ្គាក់មកកាប់ដៃស្តាំបងប្រុសរបស់ខ្ញុំហូរឈាមស្រោក់ដោយបន្សល់ស្លាកស្នាមមកដល់បច្ចុប្បន្ន ។ រឿងនេះធ្វើឲ្យឪពុកម្តាយខ្ញុំមានទំនាស់នឹងគ្នារហូតដល់កើតមានការប្រវាយប្រតប់គ្នា ។ នៅដើមឆ្នាំ១៩៧៩ បងប្រុសរបស់ខ្ញុំទៅកាប់ពោត ។ ម្តាយខ្ញុំដឹងថា ខ្មែរក្រហមពិតជាបញ្ឆោតបងប្រុសខ្ញុំយកទៅសម្លាប់ហើយ ព្រោះគាត់ធ្លាប់ឃើញអ្នកទៅកាប់ពោតពុំដែលមានអ្នកណាត្រឡប់មកវិញឡើយ ។ ពេលនោះមានបុរសម្នាក់ប្រាប់បងប្រុសខ្ញុំឲ្យរត់គេចខ្លួន បងខ្ញុំក៏រត់ចូលព្រៃបាត់ បានរយៈពេលបីថ្ងៃ តំបន់នោះក៏ត្រូវបានរំដោះ ។ ដោយសារតែព្រឹត្តិការណ៍នេះម្តាយរបស់ខ្ញុំដាក់ឈ្មោះបងប្រុសខ្ញុំថា វាសនា ។ ម្តាយរបស់ខ្ញុំគាត់ក៏ហៀបនឹងអស់ជីវិតដែរ ដោយសារថាអ្នកមូលដ្ឋានចោទ

គាត់ថា ជាយួន ប៉ុន្តែប្រធានភូមិបានដឹងថាគាត់ជាកូនកាត់ចិន ទើបម្តាយរបស់ខ្ញុំ អាចមានជីវិតរស់រហូតមកដល់សព្វថ្ងៃនេះ ។

បងស្រីរបស់ខ្ញុំដែលមានអាយុ៦ឆ្នាំ ជាកងកុមារចាំចាប និងរើសអាចម៍គោ ។ ពេលណាគាត់អត់ទៅចាំចាប ឬរើសអាចម៍គោ គាត់មិនបានទទួលរបបអាហារទេ ព្រោះអង្គការបានកំណត់ថាបើមិនធ្វើការគឺអត់បាយហូប ។ បងៗរបស់ខ្ញុំពុំបានទទួលការអប់រំរៀនសូត្រទេនៅក្នុងសម័យនោះ ក្រៅពីធ្វើការធ្ងន់ៗ ។ សិទ្ធិទទួលការអប់រំបណ្តុះបណ្តាលនិងសិទ្ធិរីកធំធាត់គឺជាសិទ្ធិដ៏សំខាន់សម្រាប់កុមារ តែសិទ្ធិទាំងនេះត្រូវបានដកពីបងៗខ្ញុំ ក៏ដូចជាកុមារដទៃទៀតដែរនៅក្នុងរបបខ្មែរក្រហម ។

ម្តាយខ្ញុំបានបន្ថែមទៀតថា នៅក្នុងសម័យនោះគ្មានលុយ គ្មានផ្សារផ្សា គ្មាសកម្មភាពដោះដូរអ្វីទាំងអស់ បើមានគឺមានដោយលួចលាក់រវាងរបស់នឹងរបស់តែប៉ុណ្ណោះ ។

ការបាត់បង់ឪពុករបស់ខ្ញុំធ្វើឲ្យម្តាយរបស់ខ្ញុំទទួលរងបន្ទុកយ៉ាងធ្ងន់ធ្ងរនៅក្នុងគ្រួសារ ។ ខ្ញុំក្លាយទៅជាកូនកំព្រាឪពុកតាំងពីខ្ញុំនៅក្នុងផ្ទៃម្តាយ ខ្ញុំពីរខែម៉្លេះ ។ បងៗរបស់ខ្ញុំក្លាយទៅជាអនក្ខរជនធ្វើឲ្យប៉ះពាល់ដល់ជីវិតរស់នៅរបស់គាត់សព្វថ្ងៃ ។ ប៉ុន្តែរហូតមកដល់ពេលនេះគ្រួសាររបស់ខ្ញុំពុំទាន់បានទទួលនូវសំណងអ្វីដែលសមស្របនៅឡើយទេ ចំពោះការបាត់បង់នេះ ។ អ្វីដែលគ្រួសាររបស់ខ្ញុំចង់បាននោះគឺ យុត្តិធម៌ដែលជាការទទួលខុសត្រូវរបស់ខ្មែរក្រហមដែលបានប្រព្រឹត្តមកលើគ្រួសាររបស់ខ្ញុំ ។ នៅទីបំផុតអ្វីដែលជាការទន្ទឹងរង់ចាំរបស់គ្រួសារខ្ញុំ ក៏ដូចជាប្រជាជនខ្មែរគ្រប់រូបបានឈានមកដល់តាមរយៈការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលបានចុះហត្ថលេខាព្រមព្រៀងគ្នារវាងរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិក្នុងការបង្កើតឲ្យមានដំណើរការតុលាការមួយកាលពីថ្ងៃទី៦ ខែមិថុនា ឆ្នាំ ២០០៣កន្លងទៅនេះ ដែលបានប្រារព្ធឡើងនៅសាលមហោស្រពចតុមុខ ។

អតីតកាលនឹងជ្រះស្រឡះពីអារម្មណ៍របស់ប្រជាជនដែលជាឱកាសក្នុងការកសាងប្រទេសតទៅទៀត ។ ការអភិវឌ្ឍអាចប្រព្រឹត្តទៅបានលុះត្រាណាតែមានសន្តិភាព ហើយសន្តិភាពក៏មិនអាចខ្វះយុត្តិធម៌ដែរ ។ **ព្រុំ ផល្លា**

## ការស៊ើបអង្កេតកោសល្យវិច័យនៅលើអដ្ឋិធាតុនៅតាមបូជនីយដ្ឋាននិងរណ្តៅសាកសពនៅក្នុងព្រះរាជាណាចក្រកម្ពុជា

មជ្ឈមណ្ឌលឯកសារកម្ពុជាដោយបានសហការជាមួយសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងនឹងអនុវត្តការស៊ើបអង្កេតបែបកោសល្យវិច័យនាំមុខមួយទៅលើបូជនីយដ្ឋាននិងរណ្តៅសាកសពមួយចំនួននៅក្នុងព្រះរាជា-ណាចក្រកម្ពុជា ។ ក្រុមស៊ើបអង្កេតត្រូវបានចូលរួមដោយអ្នកឯកទេសផ្នែកកោសល្យវិច័យមកពីប្រទេសកាណាដា បញ្ញាជនកម្ពុជាមួយរូបមកពីសហរដ្ឋអាមេរិក និងបុគ្គលិកមជ្ឈ-មណ្ឌលឯកសារកម្ពុជា ។ ការងារស៊ើបអង្កេតនេះទទួលបានការអនុញ្ញាតពីក្រសួងមហាផ្ទៃ ។

ទីតាំងសម្រាប់ធ្វើការស៊ើបអង្កេតនឹងត្រូវបានជ្រើសរើសតាមរយៈព័ត៌មានដែលមជ្ឈមណ្ឌលឯកសារកម្ពុជាប្រមូលបាននៅក្នុងពេលអនុវត្តគម្រោងបង្កើតផែនទីរណ្តៅសាកសព ។ គោលបំណងចម្បងនៃការស៊ើបអង្កេតកោសល្យវិច័យនេះគឺជីកកកាយយកសំណល់សាកសពពីរណ្តៅសពមួយកន្លែងដើម្បីយកមកវិភាគតាមបែបវិទ្យាសាស្ត្រកោសល្យវិច័យ ។ អដ្ឋិធាតុដែលទើបនឹងគាស់បានថ្មីៗ និងភ័ស្តុតាងផ្សេងទៀតដែលមានតម្កល់ទុកនៅតាមបូជនីយដ្ឋាននឹងត្រូវបានសិក្សាវិភាគតាមវិធីសាស្ត្រគំរូនានាដែលនិយមប្រើប្រាស់នៅក្នុងនរវិទ្យាកោសល្យ-វិច័យនិងរោគសាស្ត្រកោសល្យវិច័យ ។

ការចាប់ផ្តើមអនុវត្តការងារនេះគឺជំហានទីមួយនៃការស៊ើបអង្កេតទូលំទូលាយបន្ថែមទៀតនៅក្នុងប្រទេសកម្ពុជា ។ ក្រុមការងារសង្ឃឹមថានឹងប្រមែប្រមូលនិងចងក្រងជាឯកសារនូវព័ត៌មានទាក់ទិនទៅនឹងអាយុនិងភេទរបស់សាកសពនិងស្លាកស្នាមរបួសដែលមាននៅលើអដ្ឋិធាតុ ។

ជំហានដំបូងនៃគម្រោងកោសល្យវិច័យនេះទទួលបានការឧបត្ថម្ភពីការិយាល័យទទួលបន្ទុកប្រជាធិបតេយ្យសិទ្ធិមនុស្សនិងពលកម្មនៃក្រសួងការបរទេសសហរដ្ឋអាមេរិក ។

**ឆាំង យុ**

# ដើម្បីផ្សះផ្សាជាតិ ឈានទៅរកភាពរីកចម្រើន

ឆ្លងតាមការតាមដានគ្រប់ទស្សនាវដ្តីស្វែងរកការពិត និងឆ្លងតាមការស្រាវជ្រាវសៀវភៅជាច្រើនពាក់ព័ន្ធនឹងរបបប្រល័យពូជសាសន៍ នាងខ្ញុំយល់ឃើញតាមទស្សនៈខ្លួនឯងផ្ទាល់ថា វីរបុរសដឹកនាំក្នុងរបបប្រល័យពូជសាសន៍ដ៏មហិមា មហាអស្ចារ្យ មហាលោតផ្លោះនោះឆ្លើយថា គាត់មិនបានដឹងថាមានការកាប់សម្លាប់វង្កាល និងប្រជាជនទូទាំងប្រទេស អត់បាយក្រហាយទឹកស្លាប់ដោយជំងឺ ដោយគ្មានការគាំពារសុខភាពសូម្បីតែបន្តិចក៏គ្មានដែរ ។ សួរថា ខ្លួនដឹកនាំប្រទេសយ៉ាងម៉េច? បើខ្លួនក្តាប់ផែនការ និងក្តាប់មនុស្សក្រោមបង្គាប់មិនបាននោះ! ខ្លួនអួតអាងថា របបដឹកនាំកាន់តាមប្រជាធិបតេយ្យ តើប្រជាធិបតេយ្យនៅកន្លែងណា? បើនាងខ្ញុំមិនបានឆ្លងកាត់របបនោះ ទើបខ្ញុំជឿបានខ្លះថា ប្រជាធិបតេយ្យ តែខ្ញុំឆ្លងកាត់ខ្លួនឯងផ្ទាល់ ខ្ញុំរង ខ្ញុំជួប ខ្ញុំប្រទះគ្រប់បែបយ៉ាងទាំងអស់ដូចប្រជាជនទូទាំងប្រទេសដែរ ប្រជាធិបតេយ្យ ឬក៏ប្រជានរក? សមមិត្ត ឌុច ដែលជាមេគុកដ៏មហិមា ក៏ឆ្លើយថា គាត់អត់បានប្រព្រឹត្តដែរ! តើនរណាជាអ្នកប្រព្រឹត្ត? បើអ្នកទោសដែលរួចខ្លួន និងកងកម្លាំងដែលនៅរស់ដល់សព្វថ្ងៃជាសាក្សីនោះ តើគាត់នៅតែបដិសេធទៀត ឬយ៉ាងណា?

នាងខ្ញុំបានអានសៀវភៅដឹកម្ពុជា បានសិក្សាពាក្យទាំងឡាយក្នុងនោះយល់ឃើញនយោបាយនេះ សុទ្ធតែអ្នកស្នេហាជាតិតស៊ូរំដោះប្រជាជននិងប្រទេសជាតិឲ្យចេញរួចពីនឹមបរទេសទាំងអស់ គ្រាន់តែមេដឹកនាំខុសៗគ្នាតែប៉ុណ្ណោះ ប៉ុន្តែសុទ្ធតែមាននិន្នាការរំដោះជាតិដូចៗគ្នា ។ លុះដល់ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥មក គេប្រមូលធ្វើការទាំងអស់គ្នា គ្រាន់តែមហិច្ឆតារបស់បុគ្គលវាខុសៗគ្នា ដូចនេះខ្ញុំយល់ឃើញថា ក្នុងរបបនោះប្រាកដជាមានការបាក់បែកគ្នា ហើយនឹងមានថ្ងៃរលាយជាមិនខាន ។ ឆ្លងកាត់របបនោះឃើញថាមានរយៈពេលខ្លីមែនពិត ប៉ុន្តែខ្លីក្នុងរបបនោះតែបីឆ្នាំ ប្រាំបីខែ និងម្ភៃថ្ងៃ ចំពោះនាងខ្ញុំហាក់ដូចជាវែងណាស់ យើងទាំងអស់គ្នារងទុក្ខទោសសព្វបែបយ៉ាង ដូចរស់ក្នុងឋាននរកប្រាំបីជាន់អវិចីង គឺរស់ក្នុងរបបមួយដែលគ្មានសិទ្ធិនិយាយស្តី គ្មានសិទ្ធិដើរហើរ គ្មានសិទ្ធិហូបចុក គ្មានសិទ្ធិការពារខ្លួន គ្មានសិទ្ធិគាំពារសុខភាព គ្រួសាររស់នៅបែកបាក់គ្នា ឪពុកម្តាយឆ្ងាយពីកូន សុខទុក្ខមិនដឹង ប្តីប្រពន្ធនៅដោយឡែកពីគ្នា បងប្អូនព្រាត់គ្នា ធ្វើឲ្យគំនិតស្មារតីទន់ខ្សោយ ឈឺថ្កាត់ឈប់សម្រាកមិនបាន ទាំងអស់នេះជាប្រជាធិបតេយ្យ ឬលទ្ធិផ្តាច់ការនិយម? ដូច្នេះនាងខ្ញុំគ្រាន់តែចង់បានតុលាការមួយដ៏ត្រឹមត្រូវ ហើយយុត្តិធម៌បំផុតឲ្យបុគ្គលដែលបានប្រព្រឹត្ត ហើយព្រមទទួលស្គាល់កំហុសរបស់ខ្លួន កុំឆ្លើយថាមិនដឹង មិនឮដូច្នេះវាមិនសមទេ បើហ៊ានប្រព្រឹត្តត្រូវតែហ៊ានទទួលខុសត្រូវ ទើបសមជាមនុស្សពេញលក្ខណៈជាមនុស្សបានសិក្សារៀនសូត្រ ។ អស់លោកទាំងនោះសុទ្ធតែបានរៀននៅមហាវិទ្យាល័យធំៗ នៅបរទេសទៀតផង ដោយឡែកនាងខ្ញុំជាមនុស្សសាមញ្ញធម្មតាម្នាក់មិនបានចូលមហាវិទ្យាល័យ ហើយក៏គ្មានសញ្ញាប័ត្រអ្វីធំដុំដែរ ប៉ុន្តែគ្រាន់មានឧត្តមគតិជាមនុស្សម្នាក់ដែលមានសភាវគតិ ចេះគិត ចេះពិចារណា អ្វីដែលខុស អ្វីដែលត្រូវ ហើយយល់ថា អ្វីដែលនាំឲ្យរីកចម្រើន ។ នាងខ្ញុំមិនទាមទារឲ្យកាត់ទោសប្រហារជីវិតឧក្រិដ្ឋជនទាំងនោះទេ គ្រាន់តែបុគ្គលទាំងឡាយណាដែលពាក់ព័ន្ធសុំសារភាព ហើយសុំទោសប្រជាជនទូទាំងប្រទេស នោះជាការស្រេចដូចក្នុងធម៌ព្រះក៏បានសម្តែង សំខាន់បើខ្លួនខុសហើយចេះសារភាព ហើយកែខ្លួនដើរតាមផ្លូវត្រូវវិញជាការស្រេច ។ ឧទាហរណ៍ៈ អង្គុលីមារ ដែលបានកាត់ម្រាមដៃមនុស្សបាន ៩៩៩ ហើយខ្វះតែមួយទៀតគ្រប់ ១០០០ តែរកមិនបានសោះដល់ប្រទះព្រះសម្មណគោត្តម ក៏ប្រឹងដេញតាមកាត់ម្រាមដៃគម្រប់ តែដេញមិនទាន់ ក៏បានព្រះពុទ្ធប្រោសពេលនោះទៅ ហើយក៏ចូលខ្លួនបួសបានត្រាសជាព្រះអរហន្ត នេះជាគំរូផ្លូវល្អមួយដែលព្រះលោកបានសម្តែងទុកមក ដូច្នេះ

*វាសំខាន់នៅលើបុគ្គល តើទទួលឬមិនទទួល? បើទទួលគឺបានរួចក្នុងផ្លូវលោក តែផ្លូវធម៌វិញមិនអាចរួចខ្លួនឡើយ ព្រោះអ្នកណាប្រព្រឹត្ត អ្នកនោះជាអ្នកទទួលផលនៅអំពើទាំងឡាយដែលបានសាង ។*

*នាងខ្ញុំនៅមានចម្ងល់មួយទៀត សូមសួរទៅនាយកមជ្ឈមណ្ឌលឯកសារកម្ពុជាថា តើអង្គការសហប្រជាជាតិមានគំនិតបែបណា ដែរក្នុងរបបដឹកនាំដោយ ប៉ុល ពត និង អៀង សារី? ក្នុងឋានៈនិងតួនាទីរបស់អង្គការសហប្រជាជាតិ តើមានសិទ្ធិថ្កោលទោសឧក្រិដ្ឋជន ដែរឬទេ? បើមានសិទ្ធិ តើសិទ្ធិនោះធ្វើបានត្រឹមណា? ហេតុអ្វីបណ្តែតបណ្តោយឲ្យប្រជាជនកម្ពុជាស្លាប់រាប់លាននាក់ ដោយមិនធ្វើ ដឹងឮអ្វីសោះក្នុងសម័យនោះ? នាងខ្ញុំបានអានច្រើនហើយពត៌មានទាំងឡាយ មិនមែនសហរដ្ឋអាមេរិក និងអង្គការសហប្រជាជាតិមិន ដឹងទេ គឺដឹងតាមរយៈអ្នកយកពត៌មានដែលនៅកម្ពុជារត់ទៅរួច ឬតាមរយៈអង្គការនានាដែលចុះមកតាមព្រំដែនកម្ពុជា-ថៃដែរ? តែហាក់ដូចធ្វើមិនដឹង មិនឮ តើបណ្តាលពីហេតុអ្វី? ហើយសព្វថ្ងៃនេះទៀតសោត ហាក់ដូចជាដឹងឮ ហើយថែមទាំងឈឺឆ្អាលថែមទៀត ផង តើមូលហេតុអ្វីដែរ? ហើយនាងខ្ញុំឆ្ងល់ថែមទៀតថា ក្នុងសង្គមខ្មែរសព្វថ្ងៃនេះទៀតសោត ក៏ដូច្នេះដែរ អ្នកធំៗទាំងអស់ហេតុអ្វី ក៏មានមហិច្ឆតាលោភលន់ខ្លាំងម្ល៉េះ គិតតែពីដណ្តើមតួនាទីគ្នា មិនគិតខំពួតដៃគ្នាកសាងប្រទេសឲ្យរីកចម្រើនជឿនលឿនដូចប្រទេស ដែលនៅជិតខាងយើង ហើយខ្ញុំនៅតែឆ្ងល់ទៀតថា ម្នាក់ៗអួតសុទ្ធតែស្នេហាជាតិ តែបើតាមខ្ញុំយល់ថា ស្នេហាតែមាត់ទេ ការពិតមកចូលរួមដើម្បីចង់បានតួនាទីនិងអំណាចតែប៉ុណ្ណោះ បើជាខ្ញុំវិញគេដឹកនាំបានសេចក្តីសុខហើយ យើងត្រូវពួតគ្នាជាកម្លាំង ដើម្បីប្រទេសយើងតែមួយ យើងមិនត្រូវឈ្លោះគ្នាទេ ខ្មាសគេជិតខាង ។ អ្នកណាកាន់អំណាចក៏បានដែរ សំខាន់តើអ្នកនោះស្រឡាញ់ ជាតិឬទេ? សំខាន់ឧត្តមគតិមានឬទេ? សំខាន់មនសិកាជាតិមាតុភូមិមានឬអត់?*

*សំខាន់ជាងនេះទៅទៀត នាងខ្ញុំសូមស្ញើចសរសើរលោកនាយកនិងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាទាំងអស់ ដែលបាន យកអស់កម្លាំងកាយចិត្ត ខិតខំរុករក ស្រាវជ្រាវឯកសារទាំងឡាយដែលពាក់ព័ន្ធនឹងរបបប្រល័យពូជសាសន៍មកបំភ្លឺមហាជនឲ្យកាន់ តែយល់ ថាតើនរណាជាអ្នកប្រព្រឹត្ត? ហើយម្យ៉ាងវិញទៀតម្នាក់ៗខិតខំណាស់ ពិសេសលោកនាយកឈ្លុះឈ្លុលដើម្បីផ្សះផ្សាជាតិ ឈានទៅរកភាពរីកចម្រើន ហើយរក្សាទុកជាឯកសារប្រវត្តិសាស្ត្រសម្រាប់ជំនាន់ក្រោយៗទៀត ។*

*នាងខ្ញុំសូមប្រសិទ្ធិពរជ័យ សិរីមង្គលដល់លោកនាយក និងបុគ្គលិកទាំងអស់ឲ្យជួបប្រទះតែជោគជ័យគ្រប់ពេលវេលាដើម្បី ជាតិមាតុភូមិយើង និងស្ញើចសរសើរចំពោះឧត្តមគតិស្នេហាជាតិមាតុប្រទេសរបស់លោកនាយក ។*

*ធ្វើនៅភ្នំពេញ, ថ្ងៃច័ន្ទទី៩ ខែមីនា ឆ្នាំ២០០៣*

*ត្រូវនឹងថ្ងៃ១០កើត ខែជេស្ឋ ឆ្នាំមមែ បញ្ចស័ក ព.ស២៥៤៧.*

**អ. លឹម ស្រីផល្លា**



# ខ្ញុំបានយល់ដឹងអំពីអ្វីៗដែលកើតមានឡើងក្នុងសម័យនោះ

ខ្ញុំបាទឈ្មោះ យិន ណូត អនុប្រធានមន្ទីរសាលាស្រុកកំពង់ត្រាច ខេត្តកំពត សូមថ្លែងអំណរគុណដល់លោកនាយក និងសហការី ដែលបានយកចិត្តទុកដាក់ក្នុងការផ្សព្វផ្សាយ ក៏ដូចការផ្ញើទស្សនាវដ្តី «ស្វែងរកការពិត» ដល់សាលាស្រុកយើងខ្ញុំគ្រប់លេខ ។ ខ្ញុំបាទ ក៏ដូចមន្ត្រីរាជការដទៃទៀត បានអានតាមដានយកចិត្តទុកដាក់នូវខ្លឹមសារនៃអត្ថបទនីមួយៗ ម្នាក់ៗមានអារម្មណ៍ហាក់ដូចជាកំពុងស្ថិតក្នុងរបបដ៏ឃោរឃៅនេះ ។ នៅក្នុងគ្រួសារខ្ញុំមាន ឪពុក ប្អូនស្រី និងសាច់ញាតិជាច្រើន បានត្រូវស្លាប់ដោយវេទនាបំផុតក្នុងរបបខ្មែរក្រហម ។ បន្ទាប់ពីបានអានជាប់ជាប្រចាំទស្សនាវដ្តីនេះមក ខ្ញុំបានយល់ដឹងអំពីអ្វីៗដែលកើតមានឡើងក្នុងសម័យនោះ រួចកាន់តែចង់ស្វែងយល់ដឹងបន្ថែមទៀត ។ ការចង់ដឹងរបស់ខ្ញុំបាទ គឺរឿងមួយដែលកើតមានឡើងក្នុងរបបលោក លន់ ណុល មានអាកាសយានិកម្នាក់ឈ្មោះ ស ភុត្រា ត្រូវជាអតីតស្វាមីក្សត្រីបុទុមបុប្ផា បានទម្លាក់គ្រាប់បែកនៅចំការមន (កន្លែងធ្វើការរបស់លោក លន់ ណុល) ក្រោយមកទៀត នៅពេលជិតបែកទីក្រុងភ្នំពេញ មានអាកាសយានិកម្នាក់ទៀតឈ្មោះ ខៀវ យសសាវ៉ាត បានទម្លាក់គ្រាប់បែកនៅ Etat Major Général (E.M.G) ។ ខ្ញុំបាទចង់សួរលោកនាយកក្រែងមានឯកសារ ថាតើវ៉ាសនាលោកទាំងពីរជាអាកាសយានិកត្រូវពួកខ្មែរក្រហមយកទុកនៅទីណា? ចុះយន្តហោះ តេ-២៨ទាំងពីរគ្រឿងនោះ ចុះចតនៅទីណាបច្ចុប្បន្ននៅឬទេ? សូមលោកនាយកមេត្តាជួយស្រាវជ្រាវដោយអនុគ្រោះផង ។ សូមលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។ កំពង់ត្រាច,ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៣, **យិន ណូត**





កសិណីសាក្សីឈ្មោះ វ៉ាន់ ថន បង្ហាញអដ្ឋិធាតុជនរងគ្រោះដែលបានស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងស្រុកក្រឡាញ់ ខេត្តសៀមរាប

ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនីងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ ក្នុងមួយច្បាប់តម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ពត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@online.com.kh. Thank you.

**A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 42, June 2003.**
**Funded by Norway, Sweden, Switzerland, the Netherlands, Canada and USA.**